ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា



# ផែនការយុទ្ធសាស្ត្រវិស័យអប់រំ
# ឆ្នាំ ២០០៩-២០១៣

ខែ កញ្ញា ឆ្នាំ ២០១០

# អារម្ភកថា

ដើម្បីធានាសង្គតិភាពនៃឋានានុក្រម តួនាទី ខ្លឹមសារ និងលំដាប់លំដោយនៃការអនុវត្តរវាងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ ជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ ត្រូវបានពិនិត្យឡើងវិញ សំដៅកែលម្អសេវាអប់រំឱ្យកាន់តែប្រសើរថែមទៀត។

ការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ នេះ បានបង្ហាញអំពីបម្រែបម្រួល និង បង្ហាញពីដំណាក់កាលការងារដ៏សំខាន់មួយរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបន្តអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡានៅកម្ពុជា ស្របតាមកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល។ ក្នុងរយៈពេល ៥ ឆ្នាំនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំកន្លងមកនេះ ក្រសួងនិងដៃគូអភិវឌ្ឍបានធ្វើឱ្យមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ក្នុងការផ្តល់ការអប់រំប្រកបដោយសមធម៌ ការកែលម្អគុណភាពនិងប្រសិទ្ធភាពសេវាអប់រំ និងការគ្រប់គ្រងសេវាអប់រំ ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ ត្រូវបានរៀបរៀងឡើង ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងរវាងគោលនយោបាយនិងយុទ្ធសាស្ត្រអប់រំ ជាមួយនឹងកម្មវិធីនិងសកម្មភាពអភិវឌ្ឍនានា ព្រមទាំងការផ្សារភ្ជាប់ផែនការទៅនឹងថវិកា។ នៅក្នុងដំណាក់កាលនេះ ក្រសួងនៅតែបន្តផ្តល់អាទិភាពខ្ពស់លើការចូលរៀនប្រកបដោយសមធម៌និងមានគុណភាពខ្ពស់ ជាពិសេសការអប់រំកម្រិតមូលដ្ឋាន ដែលនឹងឈានទៅសម្រេចផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នានៅឆ្នាំ ២០១៥ ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-១៣ ក៏បានផ្តោតការយកចិត្តទុកដាក់ខ្ពស់ផងដែរលើការពង្រីកការអប់រំកុមារតូច ការពង្រីកការងារអប់រំក្រៅប្រព័ន្ធ ការអប់រំបច្ចេកទេសវិជ្ជាជីវៈ ការពង្រីកឱកាសទទួលសេវាអប់រំមធ្យមសិក្សា និងក្រោយមធ្យមសិក្សា តាមរយៈបន្តអនុវត្តគោលការណ៍ភាពជាដៃគូ ឱ្យបានកាន់តែប្រសើររវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មាតាបិតាសិស្ស។ លើសពីនេះទៀតត្រូវធានាថា ការចំណាយលើវិស័យអប់រំពិតជាទទួលបាននូវផលប៉ះពាល់ជាអតិបរមា ជាពិសេសផ្តោតការយកចិត្តទុកដាក់ទៅលើការអប់រំសម្រាប់កុមារនិងយុវជនបាត់បង់ឱកាស តាមរយៈការរៀបចំឲ្យមានវិធានការច្បាស់លាស់ ដែលធានាដល់ប្រសិទ្ធភាពនៃការចំណាយថវិកាអប់រំ។ ការពង្រឹងការអនុវត្តច្បាប់ស្តីពីការអប់រំ ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និង អភិបាលកិច្ចល្អ ក៏ជាកិច្ចការមួយដែលត្រូវយកចិត្តទុកដាក់ឲ្យបានខ្លាំងក្លា។ ស្របពេលជាមួយគ្នានេះ ការលើកទឹកចិត្ត និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំនៅគ្រប់កម្រិតសម្រាប់អនុវត្តវិមជ្ឈការអប់រំ ក៏ជាសមាសភាគដ៏សំខាន់ផងដែរ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ បានរៀបចំឡើងដោយមានយន្តការការងារច្បាស់លាស់ ការសិក្សា ការពិគ្រោះយោបល់ និងការចូលរួមបានទូលំទូលាយពីសំណាក់ អ្នកពាក់ព័ន្ធ

នានា ជាពិសេសក្រុមការងារវិស័យអប់រំ។ ក្រសួងសង្ឃឹមយ៉ាងមុតមាំថា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៩-២០១៣ នឹងកំណត់ផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពសំដៅជំរុញវិស័យអប់រំឲ្យលឿនទៅមុខ ដើម្បីជាគុណប្រយោជន៍ដល់ប្រជាជនកម្ពុជាគ្រប់រូប។

ក្រសួងអប់រំ យុវជន និងកីឡា សូមសំដែងនូវអំណរគុណដ៏ស្មោះស្ម័គ្រ ចំពោះបុគ្គលិកអប់រំ អ្នកបច្ចេកទេសដែលមានការពាក់ព័ន្ធទាំងអស់ និងដៃគូអភិវឌ្ឍនានាដែលបានរួមចំណែកយ៉ាងធំធេងក្នុងការកសាងផែនការនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០

**អ៊ឹម សិទ្ធី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

# មាតិកា


| | |
|---|---|
| **១. សេចក្ដីផ្ដើម៖ ទស្សនវិស័យនៃការអភិវឌ្ឍរបស់វិស័យអប់រំ** | ១ |
| ១.១ ការឆ្លើយតបទៅនឹងគោលនយោបាយ និងអាទិភាពនៃការអភិវឌ្ឍជាតិ | ១ |
| ១.២ ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា | ៣ |
| ១.៣ ដំណើរការកសាងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ | ៤ |
| **២. ការបំពេញការងារវិស័យអប់រំឆ្នាំ២០០៦-២០១០** | **៥** |
| ២.១ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ | ៥ |
| ២.២ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ | ៩ |
| ២.៣ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ | ១៣ |
| **៣. ក្របខណ្ឌយុទ្ធសាស្ត្ររបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-២០១៣** | **១៧** |
| **៤. គោលនយោបាយអប់រំ យុទ្ធសាស្ត្រ សូចនាករ និងចំណុចដៅសំខាន់ៗ** | **១៩** |
| ៤.១ គោលនយោបាយអប់រំ | ១៩ |
| ៤.២ សូចនាករសំខាន់ចាំបាច់សម្រាប់សម្រេចគោលនយោបាយ | ២០ |
| ៤.៣ យុទ្ធសាស្ត្រជាអាទិភាពសម្រាប់ឆ្នាំ ២០០៩-២០១៣ | ២២ |
| **៥. កម្មវិធីនិងអនុកម្មវិធីនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-២០១៣** | **២៧** |
| ៥.១ កម្មវិធីទី ១៖ ការអភិវឌ្ឍអប់រំចំណេះទូទៅ និងអប់រំក្រៅប្រព័ន្ធ | ២៧ |
| អនុកម្មវិធី ១.១៖ ការពង្រីកការអប់រំកុមារតូច | ២៧ |
| អនុកម្មវិធី ១.២៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា | ៣១ |
| អនុកម្មវិធី ១.៣៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា | ៣៧ |
| អនុកម្មវិធី ១.៤៖ ការចូលរៀនប្រកបដោយសមធម៌និងផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាក | ៤១ |
| អនុកម្មវិធី ១.៥៖ ការពង្រីកការអប់រំក្រៅប្រព័ន្ធ | ៤៤ |
| អនុកម្មវិធី ១.៦ ៖ ការពង្រឹង និងពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា | ៤៩ |
| អនុកម្មវិធី ១.៧៖ ការងារតម្រង់ទិសវិជ្ជាជីវៈ | ៥២ |
| ៥.២ កម្មវិធីទី ២៖ ការអភិវឌ្ឍការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសឧត្ដមសិក្សា និងស្រាវជ្រាវវិទ្យាសាស្ត្រ | ៥៦ |
| អនុកម្មវិធី ២.១៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅឧត្ដមសិក្សា | ៥៦ |
| អនុកម្មវិធី ២.២៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និង បណ្ឌិត | ៦១ |
| ៥.៣ កម្មវិធីទី៣៖ ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា | ៦៤ |
| ៥.៤ កម្មវិធីទី៤៖ ការអភិវឌ្ឍយុវជន | ៦៩ |
| ៥.៥ កម្មវិធីទី ៥៖ កម្មវិធីគាំទ្រ ការគ្រប់គ្រងសេវាអប់រំ និងអភិបាលកិច្ចល្អ | ៧២ |
| អនុកម្មវិធី ៥.១៖ ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងប្រព័ន្ធផែនការអប់រំ | ៧២ |
| អនុកម្មវិធី ៥.២៖ ការអភិវឌ្ឍការងារបណ្ដុះបណ្ដាល និងវិក្រឹតការគ្រូបង្រៀន | ៧៦ |
| អនុកម្មវិធី ៥.៣៖ ការអភិវឌ្ឍសម្ភារៈ និងសៀវភៅសិក្សា | ៨១ |

| | |
|---|---|
| អនុកម្មវិធី ៥.៤ ៖ ការគ្រប់គ្រង និងពង្រឹងប្រសិទ្ធភាពធនធានមនុស្ស | ៨៥ |
| អនុកម្មវិធី ៥.៥៖ ការអភិវឌ្ឍសមត្ថភាពការងារគ្រប់គ្រងផែនការហិរញ្ញវត្ថុនិងមូលដ្ឋានសម្ភារៈ | ៨៨ |
| អនុកម្មវិធី ៥.៦ ៖ ពង្រឹងការងារសវនកម្មផ្ទៃក្នុង | ៩១ |
| អនុកម្មវិធី ៥.៧ ៖ ការពិនិត្យតាមដាននិងវាយតម្លៃការបំពេញការងារវិស័យអប់រំទាំងមូល | ៩៤ |
| អនុកម្មវិធី ៥.៨ ៖ អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ | ៩៦ |
| អនុកម្មវិធី ៥.៩ ៖ ការអភិវឌ្ឍការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ | ៩៨ |
| អនុកម្មវិធី ៥.១០ ៖ ការពង្រឹងការងារនីតិកម្មសម្រាប់វិស័យអប់រំ | ១០០ |
| អនុកម្មវិធី ៥.១១ ៖ ការពង្រឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ | ១០៣ |
| អនុកម្មវិធី ៥.១២ ៖ ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ | ១០៦ |
| អនុកម្មវិធី ៥.១៣ ៖ ការអភិវឌ្ឍ និងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រងរដ្ឋបាលអប់រំ | ១០៨ |
| **៦. ផែនការ និងការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ជួយគាំទ្រដល់ជនក្រីក្រ** | **១១១** |
| ៦.១ ការព្យាករណ៍ថវិកាសម្រាប់វិស័យអប់រំ | ១១១ |
| ៦.២ ការព្យាករណ៍តម្រូវការហិរញ្ញវត្ថុ និងធនធានដែលមាន | ១១៤ |
| ៦.៣ ការកែលម្អប្រព័ន្ធគ្រប់គ្រងនិងពិនិត្យតាមដានហិរញ្ញវត្ថុ | ១១៦ |
| **៧. ការពិនិត្យតាមដាន និងការពិនិត្យឡើងវិញការបំពេញការងារផ្អែកលើលទ្ធផល** | **១១៧** |
| ៧.១ ការកែលម្អការពិនិត្យតាមដានវិស័យផ្អែកលើលទ្ធផល | ១១៧ |
| ៧.២ ការពង្រឹងដំណើរការពិនិត្យឡើងវិញការបំពេញការងារប្រចាំឆ្នាំរួមគ្នា | ១១៩ |
| ៧.៣. ការលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ | ១២៣ |
| ឧបសម្ព័ន្ធទី ១ ៖ ចំណោលតម្រូវការអប់រំ | ១២៧ |
| តារាង ក ៖ ចំណោលសិស្ស តម្រូវការគ្រូ និងបន្ទប់រៀន | ១២៧ |
| តារាង ខ ៖ ថវិកាសរុបសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា | ១២៩ |
| តារាង គ ៖ តម្លៃឯកតានៃថវិកាចរន្ត | ១៣២ |
| តារាង ឃ ៖ ថវិកាសម្រាប់បៀវត្សនិងមិនមែនបៀវត្សនៅក្នុងថវិកាចរន្តរបស់ក្រសួង អយក. | ១៣៣ |
| តារាង ង ៖ ផែនការហិរញ្ញវត្ថុ ស្របទៅនឹងចំណោលម៉ាក្រូសេដ្ឋកិច្ច | ១៣៤ |
| តារាង ច ៖ ការគ្រោង និង ព្យាករណ៍ចំណាយថវិកាកម្មវិធីសម្រាប់ឆ្នាំ ២០១១-២០១៣ | ១៣៥ |
| ឧបសម្ព័ន្ធទី ២ ៖ សូចនាករបំពេញការងារក្នុងវិស័យអប់រំពីឆ្នាំសិក្សា២០០៩-២០១០ដល់ឆ្នាំសិក្សា២០១៣-២០១៤ | ១៣៧ |
| ឧបសម្ព័ន្ធទី ៣ ៖ តារាងម៉ាទ្រិកសកម្មភាពគោលនយោបាយ ឆ្នាំ ២០១០-២០១៣ | ១៤០ |
| ឧបសម្ព័ន្ធទី ៤ | ១៨២ |
| | |

| **បញ្ជីរូបភាព** | |
|---|---|
| រូបភាពទី ១ ៖ អត្រាពិតនៃការសិក្សានៅបឋមសិក្សានៅឆ្នាំសិក្សា២០០៦-២០០៧ និង ២០០៩-២០១០ | ៧ |
| រូបភាពទី ២ ៖ អត្រាត្រួតថ្នាក់នៅបឋមសិក្សា នៅឆ្នាំសិក្សា ២០០៥-២០០៦ និង ២០០៨-២០០៩ | ១១ |
| រូបភាពទី ៣ ៖ អត្រាបោះបង់ការសិក្សានៅបឋមសិក្សា នៅឆ្នាំសិក្សា ២០០៥-២០០៦ និង ២០០៨-២០០៩ | ១១ |
| រូបភាពទី ៤ ៖ រចនាសម្ព័ន្ធពិនិត្យតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ | ១២២ |
| **បញ្ជីតារាង** | |
| តារាងទី ១ ៖ លទ្ធផលសម្រេចបានជាក់ស្តែងធៀបនឹងចំណុចដៅ - សមធម៌នៃការចូលរៀន | ៨ |
| តារាងទី ២ ៖ លទ្ធផលសម្រេចបានជាក់ស្តែងធៀបនឹងចំណុចដៅ - គុណភាពនិងប្រសិទ្ធភាពនៃការអប់រំ | ១១ |
| តារាងទី ៣ ៖ លទ្ធផលសម្រេចបានជាក់ស្តែងធៀបនឹងចំណុចដៅ - អភិវឌ្ឍស្ថាប័ននិងសមត្ថភាព | ១៤ |
| តារាងទី ៤ ៖ សូចនាករសំខាន់ចាំបាច់សម្រាប់សម្រេចគោលនយោបាយ និងចំណុចដៅ | ២០ |
| តារាងទី ៥ ៖ ការងារសាងសង់អគាររដ្ឋបាល និងអគារសិក្សាពីឆ្នាំ ២០១១ ដល់ ២០១៣ | ១០៤ |
| តារាងទី ៦ ៖ ចំណែកថវិកាសម្រាប់វិស័យអប់រំ និងការព្យាករណ៍ចំណាយសម្រាប់ឆ្នាំ២០១១-២០១៣ | ១១១ |
| តារាងទី ៧ ៖ តម្រូវការធនធានសម្រាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៩-២០១៣ | ១១២ |
| តារាងទី ៨ ៖ តម្រូវការធនធាន និងធនធានដែលមាន | ១១៤ |
| តារាងទី ៩ ៖ សូចនាករសំខាន់ៗរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ | ១១៨ |

# បញ្ជីអក្សរកាត់

| ឈ្មោះ | អក្សរកាត់ |
|---|---|
| នាយកដ្ឋានអប់រំកុមារតូច | អកត |
| នាយកដ្ឋានបឋមសិក្សា | បស |
| នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ | មចទ |
| នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | អកប |
| នាយកដ្ឋានសុខភាពសិក្សា | សស |
| នាយកដ្ឋានឧត្តមសិក្សា | ឧស |
| នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | ស.វ |
| អគ្គនាយកដ្ឋានកីឡា | អកឡ |
| អគ្គនាយកដ្ឋានយុវជន | អយជ |
| នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | បវ |
| នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | អកស |
| នាយកដ្ឋានបុគ្គលិក | បល |
| នាយកដ្ឋានហិរញ្ញវត្ថុ | ហវ |
| នាយកដ្ឋានសវនកម្មផ្ទៃក្នុង | សវ |
| អធិការដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | អរហ |
| នាយកដ្ឋានសំណង់សិក្សា | សណ |
| នាយកដ្ឋាននីតិកម្ម | ន.ក |
| នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | សទរ |
| នាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន | ពអស៊ |
| នាយកដ្ឋានរដ្ឋបាល | រប |
| នាយកដ្ឋានផែនការ | ផក |
| នាយកដ្ឋានអប់រំកាយកីឡា | អកឡ |
| នាយកដ្ឋានអប់រំកាយសិស្សនិស្សិត | អកស |
| មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | មជ.ហឡ |
| នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | តទវ |



# សេចក្តីផ្តើម៖
# ទស្សនវិស័យនៃការអភិវឌ្ឍរបស់វិស័យអប់រំ

# ១. សេចក្តីផ្តើម៖ ទស្សនវិស័យនៃការអភិវឌ្ឍរបស់វិស័យអប់រំ

## ១.១ ការឆ្លើយតបទៅនឹងគោលនយោបាយនិងអាទិភាពនៃការអភិវឌ្ឍជាតិ

នៅឆ្នាំ ២០០៨ រាជរដ្ឋាភិបាលក្នុងនីតិកាលទី ៤ របស់សភាជាតិបានពិនិត្យមើលឡើងវិញលើផែនការនានារបស់ខ្លួន ដើម្បីអនុវត្តគោលនយោបាយអាទិភាពនៃយុ ទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ ដោយរក្សាទុក "ការពង្រឹងគុណភាពអប់រំ" ជាមុំទី ១ ក្នុងចតុកោណទី ៤ ដែលមាន "ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស" ជាស្នូល។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងកិច្ចប្រជុំលើកដំបូងរបស់គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលថ្មីបានគូសបញ្ជាក់ថា

> *រាជរដ្ឋាភិបាល ក៏បានទទួលស្គាល់នូវភាពចាំបាច់នៃការធានាសង្គតិភាពនៃឋានានុក្រម តួនាទីខ្លឹមសារ និង លំដាប់លំដោយនៃការអនុវត្តរវាងយុទ្ធសាស្ត្រចតុ កោណ ជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏ដូចជាជាមួយនឹងយុទ្ធសាស្ត្រអភិ វឌ្ឍតាមវិស័យ ព្រមទាំងជាមួយនឹងឯកសារដែលមានលក្ខណៈជាផែនការ គោលនយោបាយ និងកម្មវិធីវិនិយោគ និងថវិកាជាតិ។ ប្រការនេះ តម្រូវឲ្យរាជរដ្ឋាភិបាលពិនិត្យឡើងវិញនូវសង្គតិភាពនៃអាណត្តិរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាមួយនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដែលមានយុទ្ធសាស្ត្រចតុកោណជារបៀបវារៈគោលនយោបាយ សង្គម-សេដ្ឋកិច្ច ។*
>
> (យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ - កឋាខណ្ឌទី ៥ ទំព័រទី ១៧)

ដើម្បីជំរុញការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ឲ្យមានប្រសិទ្ធភាពខ្ពស់ របៀបវារៈកំណែទម្រង់សំខាន់ៗក្នុងវិស័យអប់រំ ត្រូ វបានផ្តោតទៅលើការអនុវត្តកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ ដោយរួមបញ្ចូលទាំងការអនុវត្តវិមជ្ឈការ និងវិសហ-មជ្ឈការនៅថ្នាក់ក្រោមជាតិជាជំហានៗ។ ជាមួយនោះ ក្រសួងខិតខំលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការក្នុងវិស័យអប់រំ ដោយពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលនានា។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានជ្រើសរើសឲ្យសាកល្បងអនុវត្តថវិកាកម្មវិធី និង រៀបចំផែនការយុទ្ធសាស្ត្រថវិការយៈពេលមធ្យម ដែលបាននិង កំពុងបង្ហាញពីការបំពេញការងារប្រសើរជាងមុនពីមួយឆ្នាំទៅមួយឆ្នាំ។ តាមរយៈការអនុវ ត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ គោលនយោបាយអភិវឌ្ឍស្ថាប័ននិងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ បាននិងកំពុង ពង្រឹង និងយកចិត្តទុកដាក់ខ្ពស់។ កិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ក៏បានយកចិត្តទុកដាក់ជាពិសេសតាមរយៈការអនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងបារីស និង ផែនការសកម្មភាព

ទីក្រុងអាក្រា ដែលបានជួយដល់ការធ្វើសុខុដុមនីយកម្ម និងការតម្រឹមរាល់ធនធានរបស់ដៃគូអភិវឌ្ឍ ឲ្យស្របតាមទិសដៅគោលនយោបាយអភិវឌ្ឍរបស់ប្រទេសជាតិ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ បានឆ្លើយតបទៅនឹងតម្រូវការរបស់រាជរដ្ឋាភិបាល ដើម្បីជំរុញកំណើន បង្កើតការងារ ធានាសមធម៌ និងប្រសិទ្ធភាព ឲ្យស្របតាមនិន្នាការរីកចម្រើនរបស់សកលលោក។ ដើម្បីឆ្លើយតបទៅនឹងអាទិភាពនិងគោលនយោបាយអភិវឌ្ឍជាតិ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ ត្រូវបានកសាងឡើង ដើម្បីបង្កើនកិច្ចប្រឹងប្រែងរបស់វិស័យអប់រំ ឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និង ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ ២០០៣-២០១៥ ជាពិសេសដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

## ១.២ ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា

**ចក្ខុវិស័យ**របស់ក្រសួងអប់រំ យុ វជន និង កីឡាគឺ កសាង និង អភិវឌ្ឍធនធានមនុស្សប្រកប ដោយគុណភាព និងគុណធម៌ប្រ សើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាង សង្គមកម្ពុជាឲ្យក្លាយជាសង្គម រីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

ដើម្បីសម្រេចបានតាមចក្ខុវិស័យខាងលើ ក្រសួងអប់រំ យុវជន និង កីឡាមាន **បេសកកម្ម** ដឹកនាំ គ្រប់គ្រង និងអភិ វឌ្ឍវិស័យអប់រំ យុវជន និង កីឡានៃ ព្រះរាជាណាចក្រកម្ពុជា ឲ្យឆ្លើយតបទៅនឹង តម្រូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌ របស់កម្ពុជា និ ងការរីកចម្រើននៅក្នុងតំបន់ និង សកល លោក ។

វត្ថុបំណងរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និង កីឡា គឺការអភិវឌ្ឍយុវជនកម្ពុជា លើ គ្រប់វិស័យ និងបណ្តុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូប ឱ្យមានមោទនភាពជាតិ មានសីលធម៌ល្អ និង គុណធម៌ខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន ។

វត្ថុបំណងចំពោះមុខរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺធានាថា យុវជន និងកុមារកម្ពុជាគ្រប់ រូបមានឱកាសស្មើភាពគ្នាក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព ស្របតាមរដ្ឋធម្ម នុញ្ញ និង ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារ ពោលគឺ គោលការណ៍មិនរើសអើងអំពីស្ថានភាពសង្គមគ្រួសារ ទីតាំងភូមិសាស្ត្រ ពូជសាសន៍ សាសនា ភាសា យេនឌ័រ និងកាយសម្បទា ។ ក្រសួងសង្ឃឹម មទុកថា នៅពេលដែលសិស្ស និស្សិត បានបញ្ចប់ការសិក្សា របស់ខ្លួន ពួកគេនឹងមានចំណេះដឹងស្របតាមស្តង់ដាមួយសមស្រប ព្រមទាំងអាចប្រកួតប្រជែងនៅលើ ទីផ្សារការងារក្នុងតំបន់ និងលើ សកលលោក និង អាចក្លាយជាកម្លាំងស្នូលសម្រាប់ជំរុញការអភិវឌ្ឍ សង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ ។

ដើម្បីសម្រេចបានជោគជ័យតាមវត្ថុបំណង និងចក្ខុវិស័យខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់គោលនយោបាយអាទិភាពជាចម្បងៗដូចខាងក្រោម ៖

- ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ
- អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ។

## ១.៣ ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣

អនុវត្តតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំ និងធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៩-២០១៣ ឲ្យមានសង្គតិភាពជាមួយអាណត្តិរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៩-២០១៣ ដោយមានការពិគ្រោះយោបល់ទូលំទូលាយជាមួយក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងតំណាងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

នៅខែកក្កដា ឆ្នាំ ២០០៩ ក្រសួងអប់រំ យុវជន និ ងកីឡា និងដៃគូអភិវឌ្ឍបានរៀបចំ ធាតុចូលសម្រាប់ធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែលអាចជាមូលដ្ឋាន សម្រាប់ធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ បានដើរតួនាទីដ៏សំខាន់មួយក្នុងការពង្រឹងយន្តការភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងដៃគូ អភិវឌ្ឍនៅក្នុងវិស័យអប់រំ។ ក្រុមការងារនេះ បានរៀបចំកិច្ចប្រជុំរបស់ខ្លួនយ៉ាងទៀងទាត់ និងបានចាត់ទុកថាការប្រជុំក្រុមការងារបច្ចេកទេស ចម្រុះជាវេទិកាដ៏សំខាន់សម្រាប់ពិគ្រោះយោបល់ និងធ្វើការសម្រេចចិត្តកម្រិតគោលនយោបាយរបស់វិស័យអប់រំ។ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំបានរៀបចំអង្គវិបស្សនាមួយស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ ដោយមានការចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍដែលកំពុងជួយដល់វិស័យអប់រំ។

កិច្ចប្រជុំនេះបានព្រមព្រៀងរក្សាទុកគោលនយោបាយអប់រំបច្ចុប្បន្នទាំងបី សម្រាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ និងបានកំណត់ផែនទីបង្ហាញផ្លូវមួយដែលមានវិសាលភាពរហូតដល់ឆ្នាំ ២០១៥ ។ ផែនទី បង្ហាញផ្លូវនោះ បានកំណត់ឲ្យមានសកម្មភាពមួយចំនួន ដូចជាការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនិងថ្នាក់តំបន់ និងការបង្កើត តអនុក្រុមការងារដើម្បីសិក្សាវិភាគលើប្រធានបទ៖ ការរៀនត្រួតថ្នាក់និងការបោះបង់ការសិក្សា ការធ្វើចំណោលសិស្ស និងតម្រូវការចាំបាច់ក្នុងវិស័យអប់រំ ការអប់រំតម្រង់ទិសវិជ្ជាជីវៈនិងបច្ចេកទេស ការអប់រំកម្រិតឧត្តមសិក្សា និងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។

ក្នុងដំណើរការសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ ក្រសួងអប់រំ យុវជន និងកីឡា បានអញ្ជើញមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្រសួង ស្ថាប័នពាក់ព័ន្ធនានារួមមាន ក្រសួងផែនការ ក្រុមប្រឹក្សាអភិ វឌ្ឍន៍កម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និង តំណាងដៃគូអភិវឌ្ឍមួយចំនួននៃក្រុមការងារវិស័យអប់រំមកចូលរួមផ្តល់យោបល់យ៉ាងសកម្មនិងទូលំទូលាយនៅក្នុងកិច្ចពិភាក្សា ។ លទ្ធផលនៃការពិភាក្សាគឺជាទុន និងជាធាតុចូ លដ៏សំខាន់របស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំក្នុងដំណាក់កាលឆ្នាំ ២០០៩-២០១៣ ខាងមុខ។



# ការបំពេញការងារវិស័យអប់រំ

# ឆ្នាំ ២០០៦-២០១០

# ២. ការបំពេញការងារវិស័យអប់រំឆ្នាំ ២០០៦-២០១០

នៅក្នុងផ្នែកនេះ នឹងមានអធិប្បាយដោយសង្ខេបអំពីសមិទ្ធផលរបស់វិស័យអប់រំ ដែលសម្រេចបានតាមគោលនយោបាយដែលបានកំណត់ទុកក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-២០១០ ដូចខាងក្រោមៈ ១).ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ ២).លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ ៣). អភិវឌ្ឍស្ថាប័ននិងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ការធ្វើវិមជ្ឈការ។

## ២.១ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌

ចំនួនសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ បានកើនឡើងគួរឲ្យកត់សម្គាល់ ពោលគឺពី ៨៦២៨ សាលានៅឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ១០១១៥ សាលា នៅឆ្នាំសិក្សា ២០០៩-២០១០។ ការកើនឡើងនៅកម្រិតសិក្សានីមួយៗមានដូចតទៅៈ សាលាបឋមសិក្សាកើនពី ៦២៧៧ សាលានៅឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ៦៦៦៥ សាលា នៅឆ្នាំសិក្សា ២០០៩-២០១០។ សាលាមធ្យមសិក្សាបឋមភូមិកើនពី ៩១១ សាលានៅឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ១១៧២ សាលានៅឆ្នាំសិក្សា ២០០៩-២០១០។ សាលាមធ្យមសិក្សាទុតិយភូមិកើនពី ២៥២ សាលានៅឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ៣៨៣ សាលា នៅឆ្នាំសិក្សា ២០០៩-២០១០។

ស្ថានភាពដែលទទួលបានជាវិជ្ជមាននេះ គឺអាស្រ័យដោយប្រមុខរាជរដ្ឋាភិបាលដាក់ចេញគោលនយោបាយកសាងហេដ្ឋារចនាសម្ព័ន្ធសាលារៀននៅទូទាំងប្រទេស ដោយធ្វើឲ្យសាលារៀនកាន់តែខិតទៅជិតលំនៅដ្ឋានរបស់ប្រជាជន។

ក្រសួងអប់រំ យុវជន និងកីឡាបាន និងកំពុងជំរុញលើកទឹកចិត្តឲ្យមានការពង្រីកកម្មវិធីអប់រំកុមារតូចតាមគ្រប់រូបភាព។ តាមរយៈរបាយការណ៍បូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាកាលពីខែមីនា ឆ្នាំ ២០១០ កន្លងទៅនេះ ចំនួនកុមារមត្តេយ្យសិក្សាគ្រប់រូបភាពអាយុពី ០ ដល់ ៥ ឆ្នាំសរុប ១៨៦០៨៦ នាក់ ក្នុងនោះកុមារី ៩៣៧២៥ នាក់ ។ កុមារ ដែលមានអាយុចាប់ពី ៣ ដល់ ៥ ឆ្នាំ បានចុះឈ្មោះចូលរៀននៅក្នុងកម្មវិធីអប់រំកុមារតូចបានកើនឡើងពី ១២០០៩៨ នាក់ (ត្រូវជា ១៣.៦% នៃប្រជាជនអាយុពី ៣ ដល់ ៥ ឆ្នាំ) ក្នុងឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ១៧១៧៦៨ នាក់ (ត្រូវជា ២០% នៃប្រជាជនអាយុពី ៣ ដល់ ៥ ឆ្នាំ) នៅក្នុងឆ្នាំសិក្សា ២០០៩-២០១០ ។ ក្នុងចំណោមកុមារដែលបានចូលរៀន ១៧១៧៦៨ នាក់នោះ កុមារមត្តេយ្យសិក្សារដ្ឋមានតែ ៥៨% ប៉ុណ្ណោះ ។ ក្នុងឆ្នាំសិក្សា ២០០៩-២០១០ កុមារអាយុ ៥ ឆ្នាំ បាន ទទួលការអប់រំចំនួន ១១០២១០ នាក់ ស្មើនឹង ៣៩.៨% ធៀបនឹងចំណុចដៅ ៥០% ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ តាមការកត់សម្គាល់ការផ្តល់សេវាអប់រំសម្រាប់កុមារអាយុ ៥ ឆ្នាំទទួលបានលទ្ធផលល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារសាលាមត្តេយ្យសិក្សារដ្ឋផ្តល់អាទិភាពដល់ពួកគេ ដើម្បីត្រៀមខ្លួនចូលរៀនថ្នាក់ទី ១ ។

ចំនួនសិស្សសរុបនៅបឋមសិក្សាបានថយចុះពី ២៥៥៨៩៦៧ នាក់ នៅឆ្នាំសិក្សា ២០០៥-២០០៦ មកនៅត្រឹម ២២៣៩៧៥៧ នាក់ នៅឆ្នាំសិក្សា ២០០៩-២០១០ ។ ការថយចុះនេះគឺ ដោយសារចំនួនប្រជាជនក្នុងវ័យសិក្សានៅបឋមសិក្សាថយចុះ។ អត្រាកំណើនប្រជាជនប្រចាំឆ្នាំបានថយ ចុះពី ២.៨% មកនៅត្រឹម ១.៥៤% ( ជំរឿនប្រជាជនឆ្នាំ ២០០៨)។ ចំនួនសិស្សនៅមធ្យមសិក្សាបឋមភូមិបានថយចុះពី ៥៨៨៣៣៣ នាក់ នៅឆ្នាំសិក្សា ២០០៥-២០០៦ មកនៅត្រឹម ៥៨៥១១៥ នាក់ នៅឆ្នាំសិក្សា ២០០៩-២០១០។ ចំនួនសិស្សនៅមធ្យមសិក្សាទុតិយភូមិបានកើនឡើងពី ២០៩៩២៥ នាក់ នៅឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ៣២៣៥៨៣ នាក់ នៅឆ្នាំសិក្សា ២០០៩-២០១០ ។

អត្រាពិតនៃការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សាទុតិយភូមិ បានកើនឡើងគួរឲ្យកត់សម្គាល់។ អត្រាពិតនៃការសិក្សានៅបឋមសិក្សាបានកើនឡើងពី ៩១.៣% នៅឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ៩៤.៨% នៅឆ្នាំសិក្សា ២០០៩-២០១០។ អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិបានកើនពី ១១.៣% នៅឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ១៩.៣% នៅឆ្នាំសិក្សា ២០០៩-២០១០ ។ ដោយឡែក អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិបានកើនឡើងពី ៣១.៣% នៅឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ៣១.៩% នៅឆ្នាំសិក្សា ២០០៩-២០១០ ។

លទ្ធផលខាងលើនេះ គឺបានមកពីការខិតខំយកចិត្តទុកដាក់ដល់ការផ្តល់សេវាអប់រំ រៀន សូត្រពីសំណាក់រាជរដ្ឋាភិបាលតាមគ្រប់រូបភាព និងការឧបត្ថម្ភគាំទ្រពីដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមរបស់សហគមន៍ក្នុងការជំរុញឲ្យកុមារបានចូលរៀន និងបានបន្តការរៀនសូត្រចប់ភូមិសិក្សា។

បើធៀបនឹងចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-២០១០ អត្រាពិតនៃការសិក្សានៅបឋមសិក្សាក្នុងឆ្នាំសិក្សា ២០០៩-២០១០ នៅទូទាំងប្រទេសសម្រេចបាន ៩៤.៨% សម្រាប់សិស្សសរុប គឺប្រហាក់ប្រហែលនឹងចំណុចដៅដែលបានកំណត់ (៩៤.៦% សម្រាប់សិស្សស្រី)។ ក្រសួងកំពុងខិតខំរិះរកវិធានការសមស្របថែមទៀត ដើម្បីសម្រេចចំណុចដៅដែលបានកំណត់។ ប្រការ ដែលគួរឲ្យកត់សម្គាល់នោះ មានខេត្តចំនួន ៨ សម្រេចបានលើសចំណុចដៅដែលបានកំណត់ ៩៦% *(រូបភាពទី ១ និង តារាងទី ១ ខាងក្រោម)*។ អត្រាពិតនៃការសិក្សានៅតំបន់ជនបទក៏មានការកើនឡើងគួរឲ្យកត់សម្គាល់ផងដែរក្នុងដំណាក់កាលផែនការ ២០០៦-២០១០។ បើ ប្រៀបធៀបតួលេខឆ្នាំសិក្សា ២០០៥-២០០៦ ជាមួយនឹងតួលេខឆ្នាំសិក្សា ២០០៩-២០១០ ឃើញថាអត្រាពិតនៃការសិក្សាបានកើនឡើង ៣.៦% នៅតំបន់ជនបទ និងកើនឡើងប្រមាណ ១% នៅតំបន់ទីក្រុង *(ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ)*។

រូបភាពទី ១ ៖ អត្រាពិតនៃការសិក្សានៅបឋមសិក្សានៅឆ្នាំសិក្សា ២០០៦-២០០៧ និង ២០០៩-២០១០

ឆ្នាំសិក្សា ២០០៦-២០០៧




ឆ្នាំសិក្សា ២០០៩-២០១០




ពណ៌ក្រហម ៖ តិចជាង ៩០%          ឆ្នូតពណ៌លឿង ៖ ៩០ ទៅ ៩៧%          ឆ្នូតពណ៌បៃតង៖ ច្រើនជាង ៩៧%

តាមរបាយការណ៍ស្ថិតិអប់រំឆ្នាំសិក្សា ២០០៩-២០១០ ចំនួនសិស្សនៅមធ្យមសិក្សាមាន ៩០៨៦៩៨ នាក់ ។ ចំនួននេះនៅទាបជាងចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-២០១០ ។ អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិបានកើនពី ៣១.៣% នៅក្នុងសិក្សា ២០០៥-២០០៦ ទៅ ៣១.៩% នៅឆ្នាំសិក្សា ២០០៩-២០១០ ពោលគឺកើនបានតែ 0.៦% ប៉ុណ្ណោះ។ លទ្ធផលនេះបង្ហាញថានៅទាបជាងចំណុចដៅដែលបានគ្រោងទុក ៥៣% *(របាយការណ៍ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ)*។ អត្រាពិតនៃការសិក្សានៅតំបន់ជនបទបានកើនឡើងបន្តិចបន្តួចគឺពី ២៨.៦% នៅក្នុងឆ្នាំសិក្សា ២០០៥-២០០៦ ទៅ ២៨.៨% នៅឆ្នាំសិក្សា ២០០៩-២០១០ ។ ក្នុងចំណោមឃុំ សង្កាត់ចំនួន ១៦២១ មានតែឃុំសង្កាត់ចំនួន ១១៧២ ប៉ុណ្ណោះ ដែលមានសាលាមធ្យមសិក្សាបឋមភូមិ។ នៅមធ្យមសិក្សាទុតិយភូមិ ការពង្រីកការចូលរៀនមានវឌ្ឍនភាពល្អ គឺអត្រាពិត នៃការសិក្សាបានកើនឡើង ៨.១% នៅរយៈពេល ៥ ឆ្នាំ ចុងក្រោយនេះ។

ការអប់រំក្រៅប្រព័ន្ធបានដាក់ឲ្យអនុវត្តកម្មវិធីនានាដែលរួមមាន៖ កម្មវិធីអក្ខរកម្មដែលមានសិស្សចូលរៀនចំនួន ៥២០៧៨ នាក់ (ស្រី ៣៩៣២៨ នាក់ ស្មើនឹង ៦៦%) ក្នុងនោះសិស្សចំនួន ១២៦២៤ នាក់ ស្មើនឹង ២៤% គាំទ្រដោយអង្គការជាតិ និងអន្តរជាតិមួយចំនួន។

មជ្ឈមណ្ឌលសិក្សាសហគមន៍មានចំនួន ១៩៧ កន្លែង និងមានថ្នាក់រៀនចំនួន ២៧០ ថ្នាក់ មានសិស្សចំនួន ៨៣៩៧ នាក់ (ស្ត្រី ២៥៧៩ នាក់) ដែលបានទទួលការបណ្តុះបណ្តាលលើ ១២ មុខជំនាញ។

កម្មវិធីចូលរៀនឡើងវិញមានថ្នាក់រៀនចំនួន ១៥៤១ ថ្នាក់ និងមានសិស្សចំនួន ២៦៦៤៩ នាក់ ក្នុងនោះមានស្ត្រីចំនួន ៤៦.៦% ។ សិស្សចំនួន ២៣៨៤៥ នាក់ ស្មើនឹង ៩៥.៤% បានចូលរៀនតាមសាលាបឋមសិក្សាក្នុងប្រព័ន្ធវិញ ។ បើប្រៀបធៀបតួលេខឆ្នាំសិក្សា ២០០៥-២០០៦ និងឆ្នាំសិក្សា

២០០៩-២០១០ ចំនួនសិស្សចូលរៀននៅក្នុងកម្មវិធីចូលរៀនឡើងវិញបានថយចុះចំនួន ១៥%។

កម្មវិធីសមមូល/បំពេញវិជ្ជាមានសាលាបំពេញវិជ្ជាក្រៅម៉ោងធ្វើការចំនួន ២២ ដែលមានសិស្សមធ្យមសិក្សាបឋមភូមិចំនួន ៩០៤ នាក់ ក្នុងនោះស្រី ២៧.៨% ។ សិស្សមធ្យមសិក្សាទុតិយភូមិមានចំនួន ៩៦២៦ នាក់ ក្នុងនោះស្រី ៣៥.៣%។ កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធដែលអនុវត្តដោយអង្គការជាតិ និងអន្តរជាតិនានាមានសិស្សសរុបចំនួន ៦៥៦៩ នាក់ ស្រី ៥៦.៤%។

តម្រូវការសិក្សានៅកម្រិតឧត្តមសិក្សាមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ អាស្រ័យដោយបរិមាណសិស្សបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិកើនឡើង ។ ជាក់ស្តែង ក្នុងឆ្នាំសិក្សា ២០០៩-២០១០ គ្រឹះស្ថានឧត្តមសិក្សាសរុបមានចំនួន ៧៦ ក្នុងនោះគ្រឹះស្ថានសិក្សាសាធារណៈ ៣៣ និងគ្រឹះស្ថានសិក្សាឯកជន ៤៣ ។ គ្រឹះស្ថានឧត្តមសិក្សាដែលស្ថិតក្រោមចំណុះក្រសួងអប់រំ យុវជន និងកីឡាមានចំនួន ៥១ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សាសាធារណៈចំនួន ៨។

នៅក្នុងឆ្នាំសិក្សា ២០០៩-២០១០ និស្សិតចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សាសរុបមានចំនួន ១៩៥៥៩៦ នាក់ ក្នុងនោះស្រី ៥១៥៩៦ នាក់។ និស្សិតឧត្តមសិក្សាសរុបកើនឡើងបាន ៦០% ស្រីកើនឡើងបាន ៨០% បើប្រៀបធៀបនឹងឆ្នាំសិក្សា ២០០៥-២០០៦ ។ ទោះជាយ៉ាងណា ក៏ដោយ ក៏ចំនួននិស្សិតរៀននៅឧត្តមសិក្សានៅតែទាបជាងចំណុចដៅដែលបានកំណត់ នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ លទ្ធផលសម្រេចបានទាបជាងចំណុចដៅ គឺដោយសារតែធនធានថវិការបស់ផ្នែកឧត្តមសិក្សានៅមានកម្រិត ។ រាជរដ្ឋាភិបាលបាននិងកំពុងខិតខំស្វែងរកប្រភពធនធានបន្ថែមទៀត ដើម្បីពង្រីកចំនួនអាហារូបករណ៍ឲ្យបានកាន់តែច្រើនឡើងដល់និស្សិតក្រីក្រ និងពូកែរៀនសូត្រ សំដៅធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌។

ខាងក្រោមនេះ ជា លទ្ធផលក្នុងឆ្នាំសិក្សា ២០០៩-២០១០ ដែលក្រសួងអប់រំ យុវជន និងកីឡាសម្រេចបាន ធៀបទៅនឹងចំណុចដៅសូចនាករបំពេញការងារក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-២០១០។

តារាងទី ១ ៖ លទ្ធផលសម្រេចបានជាក់ស្តែងធៀបនឹងចំណុចដៅ សមធម៌នៃការចូលរៀន

| | សូចនាករ | ជាក់ស្តែង | | ចំណុចដៅ | | ជាក់ស្តែង | |
|---|---|---|---|---|---|---|---|
| | | 2005/06 | | 2009/10 | | 2009/10 | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 1 | ចម្ងាយផ្លូវឆ្ងាយបំផុតពីភូមិទៅសាលារៀន(គិតជា គ.ម) | | | | | | |
| | បឋមសិក្សា | n.a | | n.a | | 11.1 | |
| | មធ្យមសិក្សាបឋមភូមិ | n.a | | n.a | | 10.5 | |
| 2 | ចំនួនកុមារអាយុ ៥ ឆ្នាំក្នុងកម្មវិធី អប់រំកុមារតូចតាមគ្រប់រូបភាព | 27.3% | 27.9% | 50.0% | 50.0% | 39.8% | 40.5% |
| 3 | អត្រាពិតចូលរៀនថ្មី | 82.6% | 81.8% | 92.8% | 94.0% | 92.4% | 92.7% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 4 | អត្រាពិតនៃការសិក្សា | | | | | | |
| | ទូទាំងប្រទេស | 91.3% | 89.7% | 96% | 96% | 94.8% | 94.6% |
| | បឋមសិក្សា-តំបន់ប្រជុំជន | 91.2% | 89.7% | 97% | 98% | 92.2% | 92.2% |
| | បឋមសិក្សា-តំបន់ជនបទ | 91.7% | 90.1% | 94% | 95% | 95.3% | 95.0% |
| | បឋមសិក្សា-តំបន់ដាច់ស្រយាល | 83.7% | 80.1% | 94% | 93% | n.a | n.a |
| | ម.បឋមភូមិ- ទូទាំងប្រទេស | 31.3% | 30.4% | 43% | 45% | 32.6% | 34.6% |
| | ម.បឋមភូមិ- តំបន់ប្រជុំជន | 50.1% | 50.3% | 69% | 71% | 49.1% | 50.5% |
| | ម.បឋមភូមិ- តំបន់ជនបទ | 28.6% | 27.4% | 40% | 41% | 29.4% | 31.5% |
| | ម.បឋមភូមិ- តំបន់ដាច់ស្រយាល | 6.0% | 6.0% | 15% | 15% | n.a | n.a |
| | ម.ទុតិយភូមិ- ទូទាំងប្រទេស | 11.3% | 9.9% | 18% | 17% | 19.4% | 19.4% |
| 5 | ចំនួននិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈនិងឯកជន | 90,607 | 29,000 | 162,000 | 57,700 | 145,265 | 51,596 |
| 6 | ភាគរយសិស្សមកពីគ្រួសារក្រីក្រនៅ (តួលេខនៅក្នុងឆ្នាំសិក្សា២០០៨-២០០៩) | | | | | | |
| | បឋមសិក្សា | n.a | | n.a | | 77.2% | |
| | មធ្យមសិក្សាបឋមភូមិ | n.a | | n.a | | 16.9% | |
| | មធ្យមសិក្សាទុតិយភូមិ | n.a | | n.a | | 7.3% | |

## ២.២ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ

ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ គឺជាគោលនយោបាយមួយក្នុងចំណោមគោលនយោបាយចម្បងៗក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-២០១០។ ក្រសួងបានខិតខំកែលម្អគុណភាពសេវាអប់រំ តាមរយៈការលើកកម្ពស់សមត្ថភាពគ្រូបង្រៀន គ្រប់រូបភាព អំពីវិធីសាស្ត្ររៀននិងបង្រៀននៅគ្រប់ភូមិសិក្សា។ ក្រ សួងបានកែលម្អ និង ធ្វើទំនើបកម្មកម្មវិធី និងសៀវភៅសិក្សាជាបន្តបន្ទាប់ ព្រមទាំងខិតខំផ្តល់សៀវភៅសិក្សាឲ្យបានដល់ដៃសិស្សប្រហែល ៥០% តាមនិយាមសិស្សម្នាក់សៀវភៅសិក្សាមួយក្បាលក្នុងមួយមុខវិជ្ជានៅកម្រិតអប់រំមូលដ្ឋាន និងបានប្រហែល ៣០% តាមនិយាមសិស្សពីរនាក់ សៀវភៅសិក្សាមួយក្បាលក្នុងមួយមុខវិជ្ជានៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ ដោយឡែក ក្រសួងកំពុងខិតខំ ឈានទៅសម្រេចគោលដៅផ្តល់សៀវភៅសិក្សាដល់សិស្សមធ្យមសិក្សាទុតិយភូមិក្នុងតំបន់ដាច់ស្រយាល និងជួបការលំបាកឲ្យបានតាមនិយាមសិស្សម្នាក់សៀវភៅសិក្សា មួយក្បាលដូចនៅកម្រិតអប់រំមូលដ្ឋានដែរ។ ជាមួយនោះ ក្រសួង បានខិតខំអនុវត្តវិមជ្ឈការការងារមួយចំនួនទៅឲ្យថ្នាក់ក្រោមជាតិ។ ជាក់ស្តែង ក្រសួងបាន ផ្តល់ថវិកាដំណើរការសាលារៀនដល់សាលារៀនទាំងអស់និងគ្រប់ភូមិសិក្សាក្នុងទូទាំងប្រទេស។ ក្នុងរយៈពេលកន្លងមកនេះ សហគមន៍ មាតាបិតាសិស្ស អាជ្ញាធរ ដៃនដី និងអង្គការ រជាតិ អន្តរជាតិក៏បានចូលរួមយ៉ាងសកម្មក្នុងការងារអប់រំ ដើម្បីរួមចំណែកលើកកម្ពស់គុណភាពអប់រំផងដែរ។

នៅក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ ក្រសួងអប់រំ យុវជន និងកីឡាបាន ផ្សព្វផ្សាយនិងអនុវត្ត គោលនយោបាយអប់រំមួយចំនួនដូចជា: គោលនយោបាយសាលាកុមារមេត្រី គោលនយោបាយសម្រាប់ការអប់រំកុមារពិការ គោលនយោបាយសុខភាពសិក្សា និងគោលនយោបាយ គាំពារនិងអភិវឌ្ឍកុមារតូចព្រមទាំងផែនការមេសម្រាប់ការអប់រំកុមារពិការ។ លើសពីនេះ បានដាក់ចេញបទបញ្ជាផ្ទៃក្នុងសាលាបឋមសិក្សារដ្ឋជុំវិញការត្រួតថ្នាក់ និងការបោះបង់ការសិក្សាដើម្បីកែលម្អប្រសិទ្ធភាពនៃការអប់រំ។

ទាក់ទងនឹងការលើកកម្ពស់ប្រសិទ្ធភាពអប់រំ ក្រសួងបានខិតខំអនុវត្តយ៉ាងសកម្មលើការងារបច្ចេកទេសអប់រំ ដោយបានកាត់បន្ថយការរៀនត្រួតថ្នាក់ និងការបោះបង់ការសិក្សា ក៏ដូចជាខិតខំបង្កើនអត្រាបញ្ចប់ការសិក្សាតាមភូមិសិក្សានីមួយៗផងដែរ។ ជាមួយនោះដែរ ចំពោះការងារសង្គមវិញ ក្រសួងខិតខំបើកយុទ្ធនាការចុះឈ្មោះចូលរៀនដោយឥតបង់ថ្លៃ និងយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីតម្លៃនៃការអប់រំដល់មាតាបិតាសិស្ស។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅមានបញ្ហាសេសសល់ជាច្រើនដែលត្រូវបន្តដោះស្រាយ ដូចជា ប្រព័ន្ធសម្រាប់វាយតម្លៃស្តង់ដាការសិក្សារបស់សិស្សមិនទាន់បានអនុវត្តពេញលេញនៅឡើយ។ ជាក់ស្តែង សូចនាករមួយចំនួនបានបង្ហាញថា វឌ្ឍនភាពនោះគឺនៅ ទាបជាងចំណុចដៅដែលបានកំណត់។ តារាងទី ២ ខាងក្រោមបង្ហាញពីការសម្រេចបានសូចនាករគន្លឹះទាក់ទងទៅនឹងគុណភាព និងប្រសិទ្ធភាពការអប់រំ ធៀបនឹងចំណុចដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-២០១០។

នៅតាមរាជធានី ខេត្ត ស្ថានភាពទាំងនេះក៏ត្រូវបានកែលម្អ ដូចគ្នាក្នុងរយៈពេល ៥ ឆ្នាំនេះផងដែរ។ ចំនួនខេត្តដែលមានអត្រាត្រួតថ្នាក់ច្រើនជាង ១០% ត្រូវបានកាត់បន្ថយពី ១៨ ខេត្ត នៅឆ្នាំសិក្សា ២០០៥-២០០៦ មកនៅត្រឹម ១០ ខេត្តនៅឆ្នាំសិក្សា ២០០៨-២០០៩។ អត្រាបោះបង់ការសិក្សាជាមធ្យមគឺ ៨.៣% នៅឆ្នាំសិក្សា ២០០៨-២០០៩ នៅទូទាំងប្រទេស។ បើប្រៀបធៀបតួលេខឆ្នាំសិក្សា ២០០៨-២០០៩ ជាមួយនឹងតួលេខឆ្នាំសិក្សា ២០០៥-២០០៦ អត្រាបោះបង់ការសិក្សាបានថយចុះ ៣.៣%។ ខេត្តដែលមានអត្រាបោះបង់ការសិក្សាច្រើនជាង ១០% បានថយចុះពី ២១ ខេត្តនៅឆ្នាំសិក្សា ២០០៥-២០០៦ មកនៅត្រឹម ១០ ខេត្តនៅឆ្នាំសិក្សា ២០០៨-២០០៩ ។

អត្រាត្រួតថ្នាក់នៅមធ្យមសិក្សាមានកម្រិតទាប ប៉ុន្តែអត្រាបោះបង់ ការសិក្សាវិញស្ថិតក្នុងកម្រិតខ្ពស់។ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិគឺស្ទើរតែសម្រេចបានតាមចំណុចដៅ ហើយអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ គឺសម្រេចបានច្រើនជាងចំណុចដៅ។

រូបភាពទី២ ៖ អត្រាត្រួតថ្នាក់នៅបឋមសិក្សា នៅឆ្នាំសិក្សា ២០០៥-២០០៦ និង ២០០៨-២០០៩

ឆ្នាំសិក្សា ២០០៥-២០០៦ ឆ្នាំសិក្សា ២០០៨-២០០៩



ពណ៌បៃតង ៖ តិចជាង ៥% ពណ៌លឿង ៖ ៥ ទៅ ១០% ឆ្នូតពណ៌ក្រហម ៖ ច្រើនជាង ១០%

រូបភាពទី៣ ៖ អត្រាបោះបង់ការសិក្សានៅបឋមសិក្សា នៅឆ្នាំសិក្សា ២០០៥-២០០៦ និង ២០០៨-២០០៩

ឆ្នាំសិក្សា២០០៥-២០០៦ ឆ្នាំសិក្សា ២០០៨-២០០៩



ពណ៌បៃតង ៖ តិចជាង ៥% ពណ៌លឿង ៖ ៥ ទៅ ១០% ឆ្នូតពណ៌ក្រហម ៖ ច្រើនជាង ១០%

តារាងទី២ ៖ លទ្ធផលសម្រេចបានជាក់ស្តែងធៀបនឹងចំណុចដៅ គុណភាពនិងប្រសិទ្ធភាព នៃការអប់រំ

| | សូចនាករ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង |
|---|---|---|---|---|
| | | 2005/06 | 2009/10 | 2009/10 |
| 7[1] | ផលធៀបសិស្ស-គ្រូ | | | |
| | **បឋមសិក្សា** | 50.8 | 45 | 49.2 |
| | **មធ្យមសិក្សាបឋមភូមិ** | 31.7 | 28.5 | 24.4 |

[1] លេខរៀងក្នុងតារាងគឺរាប់តាមលំដាប់សូចនាករបំពេញការងារក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-២០១០

| | | | | | | | |
|---|---|---|---|---|---|---|---|
| | **មធ្យមសិក្សាទុតិយភូមិ** | 29.5 | | | | 32.2 | |
| 8 | អត្រាត្រួតថ្នាក់* | **សរុប** | **ស្រី** | **សរុប** | **ស្រី** | **សរុប** | **ស្រី** |
| | **បឋមសិក្សា** | 11.0% | 9.8% | 2% | 2% | 8.9% | 7.8% |
| | **មធ្យមសិក្សាបឋមភូមិ** | 2.5% | 24.9% | 1% | 1% | 2.3% | 1.5% |
| | **មធ្យមសិក្សាទុតិយភូមិ** | 3.3% | 15.5% | 2% | 2% | 2.8% | 1.7% |
| 9 | អត្រាបោះបង់ការសិក្សា* | | | | | | |
| | **បឋមសិក្សា** | 11.6% | 11.9% | 6% | 5% | 8.3% | 7.9% |
| | **មធ្យមសិក្សាបឋមភូមិ** | 22.8% | 24.9% | 13% | 14% | 18.8% | 19.4% |
| | **មធ្យមសិក្សាទុតិយភូមិ** | 15.9% | 15.5% | 8% | 7% | 11.2% | 10.8% |
| 10 | អត្រាគង់វង្ស | | | | | | |
| | ថ្នាក់ទី ១ ដល់ ទី ៦ | 49.3% | 48.9% | 75% | 76% | 61.7% | 63.8% |
| | ថ្នាក់ទី ១ ដល់ ទី ៩ | 26.3% | 24.3% | 54% | 54% | 37.2% | 37.9% |
| 11 | អត្រាបញ្ចប់ការសិក្សា | | | | | | |
| | **បឋមសិក្សា** | n.a | n.a | 90% | 90% | 83.2% | 83.6% |
| | **មធ្យមសិក្សាបឋមភូមិ** | n.a | n.a | 51% | 49% | 48.7% | 47.3% |
| | **មធ្យមសិក្សាទុតិយភូមិ** | n.a | n.a | 23% | 20% | 26.1% | 22.5% |
| 12 | ចំនួនសិស្សចូលរៀនឡើងវិញ នៅថ្នាក់ទី ៣ ដល់ ទី ៩ | 27,796 | | 30,000 | | 23,845 | |
| 13 | ចំនួនសាលារៀនមិនគ្រប់កម្រិត | 1,719 | | 1,200 | | 1,203 | |
| 14 | ផលធៀបសៀវភៅសិក្សា-សិស្ស នៅបឋមសិក្សា (១ សម្រាប់មាន ៥ ក្បាល) | 3.0 | | 4.0 | | 3.3 | |
| 15 | ភាគរយសិស្សសម្រេចបានតាមស្តង់ដាការសិក្សាលើមុខវិជ្ជា ភាសាខ្មែរ ដោយផ្អែកលើតេសនៅ | | | | | | |
| | - ថ្នាក់ទី ៣ | n.a | | n.a | | n.a | |
| | - ថ្នាក់ទី ៦ | n.a | | n.a | | n.a | |
| | - ថ្នាក់ទី ៩ | n.a | | n.a | | n.a | |
| | ភាគរយសិស្សសម្រេចបានតាមស្តង់ដាការសិក្សាលើមុខវិជ្ជា គណិតវិទ្យា ដោយផ្អែកលើតេសនៅ | | | | | | |
| | - ថ្នាក់ទី ៣ | n.a | | n.a | | n.a | |
| | - ថ្នាក់ទី ៦ | n.a | | n.a | | n.a | |
| | - ថ្នាក់ទី ៩ | n.a | | n.a | | n.a | |
| 16 | ភាគរយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជន គោរពតាមលក្ខខណ្ឌនៃការបង្កើត | n.a | | 100% | | 55% | |

* សូចនាករទី ៨ ទី ៩ និងទី ១០ ជាលទ្ធផលក្នុងឆ្នាំសិក្សា ២០០៨-២០០៩

## ២.៣ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ

ការអភិវឌ្ឍស្ថាប័ននិងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំ គឺជាការចាំបាច់សម្រាប់អនុវត្តកំណែទម្រង់វិស័យអប់រំ ប្រកបដោយភាពស័ក្តិ សិទ្ធិ។ ក្នុងរយៈពេលនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក្រសួងទទួលបានសមិទ្ធផលសំខាន់ៗ ដូចជា៖

- ច្បាប់ស្តីពីការអប់រំ បានប្រកាសឱ្យប្រើប្រាស់កាលពីថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧។ ក្រសួងកំពុងបន្តរៀបចំផែនការសកម្មភាពសម្រាប់កែលម្អលិខិតបទដ្ឋានដែលពាក់ព័ន្ធដទៃទៀត។
- ក្រសួងបានកសាងផែនការយុទ្ធសាស្ត្របញ្ញាបយេនឌ័រឆ្នាំ ២០០៦-២០១០ និង បានបើកវគ្គបំប៉នដល់មន្ត្រីគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់។
- ក្រសួងបានអនុវត្តថវិកាកម្មវិធីចាប់ពីឆ្នាំ ២០០៧ ជំនួសឲ្យការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព ដើម្បីរួមចំណែកអនុវត្តកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឲ្យបានជោគជ័យ ជាពិសេសផ្តោតការគ្រប់គ្រងលើលទ្ធផល។ ជាក់ស្តែង ក្រសួង បានចេញសេចក្តីណែនាំ ស្តីពីមុខងារភារកិច្ចនិង ការរៀបចំឯកសារលិខិតយុត្តិការរបស់អង្គភាពដែលគ្រប់គ្រង និងប្រើប្រាស់ថវិកាកម្មវិធីនៅរដ្ឋបាលកណ្តាល និងនៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត។
- ក្រសួងបានរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំពីឆ្នាំ ២០០៨ ដោយឆ្លុះបញ្ចាំងរាល់សកម្មភាព កម្មវិធីទាំងអស់។ ចាប់ពីឆ្នាំ ២០០៩ មកផែនការប្រត្តិប្រចាំឆ្នាំរបស់ក្រសួងបានរួមបញ្ចូលសកម្មភាពកម្មវិធីដែលគាំទ្រថវិកាដោយដៃគូអភិវឌ្ឍផងដែរ ដើម្បីឆ្លើយតបតាមផែនការសកម្មភាពសុខុដុមនីយកម្ម ការតម្រឹម និងលទ្ធផល។
- ក្រសួងបានរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បី អនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- ក្រសួងបានដាក់ឲ្យអនុវត្តអនុក្រឹត្យលេខ ១២៦ អនក្រ.បក ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពី ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន។
- ក្រសួងបានដាក់ឲ្យអនុវត្តអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- ក្រសួងបានរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រសម្រាប់វិមជ្ឈការការងារអប់រំ ។
- ក្រសួងកំពុងខិតខំប្រឹងប្រែងថែមទៀត ជាពិសេសក្នុងការពង្រឹងប្រព័ន្ធពិនិត្យតាមដាន។
- ក្រសួងបានរៀបចំរួចរាល់និងចាប់ផ្តើមដំណើរការប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស។

ក្នុងរយៈពេលនៃការអនុវត្តផែនការកន្លងមក ពិនិត្យឃើញថាចំណែកថវិកាសម្រាប់វិស័យអប់រំក្នុងថវិកាជាតិបានថយចុះពី ១៨.៥% ក្នុងឆ្នាំ ២០០៦ មកនៅត្រឹម ១៧.% នៅឆ្នាំ ២០០៩ ថ្វីបើជាបរិមាណមានការកើនឡើងជារៀងរាល់ឆ្នាំក៏ដោយ។ អត្រានៃការចំណាយថវិកាកម្មវិធីសម្រេចបានត្រឹមតែ ៥០% ក្នុងឆ្នាំ ២០០៧ ជាពេលដែលទើបអនុវត្តដំបូង ប៉ុន្តែបានកើនឡើង ជាលំដាប់រហូតដល់ ៨៨.៧% នៅឆ្នាំ ២០០៩។ ការងារសវនកម្មផ្ទៃក្នុង ពុំមានវឌ្ឍនភាពនៅឡើយ ដោយសារមានការកែសម្រួលឯកសារស្តីពីសវនកម្មផ្ទៃក្នុង។ ជំនួយបច្ចេកទេសមិនបានកាត់បន្ថយតាមការគ្រោងទុកទេ ដោយសារមានការដាក់ឲ្យអនុវត្តបន្តនូវគម្រោងធំៗ ក្នុងអំឡុងពេលនេះ។ សូចនាករស្តីពីបុគ្គលិកជាស្ត្រីមិនទាន់បានបង្ហាញពីវឌ្ឍនភាពល្អប្រសើរនៅឡើយ លើកលែងតែនៅកម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់។

តារាងទី ៣ ខាងក្រោមបង្ហាញពីលទ្ធផលផ្នែកបរិមាណទាក់ទងនឹងការអភិវឌ្ឍស្ថាប័ន និងសមត្ថភាពធៀបទៅនឹងចំណុចដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-២០១០ ដែលភាគច្រើនទាក់ទងនឹងការងារហិរញ្ញវត្ថុ។

តារាងទី ៣ ៖ លទ្ធផលសម្រេចបានជាក់ស្តែងធៀបនឹងចំណុចដៅ - អភិវឌ្ឍស្ថាប័ននិងសមត្ថភាព

| | សូចនាករ | ជាក់ស្តែង 2006 | ចំណុចដៅ 2009 | ជាក់ស្តែង 2009 |
|---|---|---|---|---|
| 17[2] | ចំណែកថវិកាជាតិចរន្តសម្រាប់វិស័យអប់រំ | 18.5% | 20% | 17.0% |
| 18 | ភាគរយចំណាយថវិកាកម្មវិធី ជាក់ស្តែងធៀបនឹងថវិកាកម្មវិធីសរុប | 105% | 100% | 88.7% |
| 19 | ភាគរយអង្គភាពអនុវត្តថវិកាដែលត្រូវធ្វើសវនកម្មផ្ទៃក្នុង ក្នុង ១ ឆ្នាំ | 42.4% | 45% | 16.7% |
| 20 | ភាគរយសាលារៀននិងគ្រឹះស្ថានសិក្សាដែលត្រូវធ្វើសវនកម្មផ្ទៃក្នុង ក្នុង ១ ឆ្នាំ | 9% | 5% | 1.1% |
| 21 | ជំនួយការបច្ចេកទេស (Person-month) ថ្នាក់ជាតិ និងអន្តរជាតិ | 576 | 382.5 | 516 |
| 22 | ភាគរយមន្ត្រីអប់រំជាស្ត្រី | | | |
| | បុគ្គលិកបង្រៀន | 40.6% | 50% | 43.4% |
| | មន្ត្រីគ្រប់គ្រងថ្នាក់មធ្យម(ប្រធាន អនុប្រធាននាយកដ្ឋាន និងមន្ទីរ អយក រាជធានី ខេត្ត) | 23.3% | n.a | 17.59% |
| | ថ្នាក់ដឹកនាំ (ចាប់ពីអគ្គនាយករងឡើងទៅ) | 1.0% | n.a | 7.7% |

ជារួម តាមរយៈការអនុវត្តគោលនយោបាយចម្បងៗទាំងបីខាងលើ វិស័យអប់រំមានការប្រែប្រួលរីកចម្រើនគួរឲ្យកត់សម្គាល់ លើការធានាលទ្ធភាពទទួល បានសេវាអប់រំប្រកបដោយសមធម៌ ដែលអាចឈានទៅសម្រេចបានតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងផែនការជាតិអប់រំ

[2] លេខរៀងក្នុងតារាងគឺរាប់តាមលំដាប់សូចនាករបំពេញការងារក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-២០១០

សម្រាប់ទាំងអស់គ្នានៅឆ្នាំ ២០១៥ ខាងមុខ ទោះបីជាលទ្ធផលសម្រេចបានក្នុងពេលបច្ចុប្បន្នអាចទាបជាងចំណុចដៅខ្លះក៏ដោយ។ គុណភាពនិងប្រសិទ្ធភាពសេវាអប់រំក៏បានលើកកម្ពស់ជាបណ្តើរៗ ជាពិសេស ការសម្រេចបានអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាដែលមាននិន្នាការរីកចម្រើនជាវិជ្ជមានក្នុងដំណាក់កាលនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំកន្លងមកនេះ។ ការអភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីក៏ទទួលបានលទ្ធផលជាវិជ្ជមានផងដែរ ជាពិសេសការពង្រឹងប្រព័ន្ធលិខិតបទដ្ឋានគតិយុត្ត និងសមត្ថភាពមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ក៏បានលើកកម្ពស់។



# ក្របខណ្ឌយុទ្ធសាស្ត្ររបស់
# ផែនការយុទ្ធសាស្ត្រវិស័យអប់រំ
# ឆ្នាំ ២០០៩-២០១៣

## ៣. ក្របខណ្ឌយុទ្ធសាស្ត្ររបស់ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣

ក្នុងនីតិកាលទី ៤ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលនឹងបន្តអនុវត្ត***ផែនការយុទ្ធសាស្ត្រវិស័យអប់រំ*** ដោយផ្តោតលើការផ្តល់ឱកាសស្មើៗគ្នាដល់កុមារនិងយុវជនកម្ពុជាទាំងអស់ ក្នុងការទទួលការ អប់រំមូលដ្ឋាននៅក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដោយមិនប្រកា ន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត និងឋានៈនៅក្នុងសង្គមឡើយ។ ម៉្យាងវិញទៀត ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ត្រូវផ្សារភ្ជាប់នឹងការអប់រំ វប្បធម៌ សន្តិភាព ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ការគោរ ពគោលការណ៍សេរីភាព ប្រជាធិបតេយ្យ និងយុត្តិ ធម៌ ដោយប្រឆាំងនឹងអំពើហិង្សា ប្រឆាំងនឹងការប្រើប្រាស់គ្រឿងញៀន ការជួញ ដូរកុមារនិងស្ត្រី និងការរើសអើងគ្រប់ប្រភេទក្នុងសង្គម ។

រាជរដ្ឋាភិបាលនឹងបន្តយកចិត្តទុកដាក់លើការកែលម្អគុណភាពអប់រំ តាមរយៈ ការលើកទឹកចិត្តគ្រូបង្រៀន ការកែលម្អកម្មវិធីសិក្សា ការលើកទឹកចិត្តសិស្សពូកែ ការបណ្តុះបណ្តាលគ្រូបង្រៀន និងបំប៉នវិធីសាស្ត្របង្រៀន ព្រមទាំងការកែលម្អលក្ខខណ្ឌនៃការសិក្សា និងការផ្គត់ផ្គង់សម្ភារៈសិក្សា ការបង្កើតបណ្ណាល័យ បន្ទប់ពិសោធន៍ជាដើម។ ក្នុងទិសដៅធានាកាលានុវត្តភាពប្រកបដោយសមធម៌ រាជរដ្ឋាភិបាលនឹងបន្តកសាងអន្តេវាសិកដ្ឋានសម្រាប់សិស្ស-និស្សិត ជាពិសេស សម្រាប់សិស្ស-និស្សិតជានារីភេទ និងបន្តសាងសង់ សាលារៀនគ្រប់កម្រិតសិក្សា ជាពិសេស នៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាល និងការបង្កើនអាហារូបករណ៍ សម្រាប់សិស្ស-និស្សិតក្រីក្រ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយគុណភាពឱ្យបានគ្រប់គ្រាន់ និង អនុវត្តគោលនយោបាយពង្រាយគ្រូឱ្យមានប្រសិទ្ធភាព។ រាជរដ្ឋាភិបាលនឹងលើកទឹកចិត្តឱ្យគ្រូបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ និងគ្រូដែលបានបន្តរៀនចប់ប វិញ្ញាបត្របានប្រឡងចូលក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តមដោយគ្មានកំណត់អាយុ និងបង្កលក្ខណ សម្បត្តិឱ្យគ្រូបឋមសិក្សា ដែល មិនទាន់មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានលទ្ធភាពប្រឡងយកសញ្ញាបត្រសមមូលមធ្យមសិក្សាទុតិយភូមិ ដើម្បីផ្តល់ឱកាសឱ្យពួកគាត់មានលទ្ធភាពរៀននៅថ្នាក់ឧត្តមសិក្សា និងផ្លាស់ប្តូរ កាំប្រាក់បៀវត្សរ៍។ លើកកម្ពស់គុណភាពមន្ត្រីគ្រប់គ្រងវិស័យអប់រំ ឲ្យបានសមស្រប។

រាជរដ្ឋាភិបាលនឹងបន្តពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន និងជាមួយសហគមន៍ជាតិ និងអន្តរជាតិ ដើម្បីបង្កើននិងលើកកម្ពស់គុណភាពសេវាអប់រំ ក្នុងនោះមានការយកចិត្តទុកដាក់បន្ថែមលើការបណ្តុះបណ្តាលផ្នែកព័ត៌មានវិទ្យានិងភាសាបរទេស នៅក្នុងគ្រប់កម្រិតមធ្យមសិក្សាចំណេះ ទូទៅ នៅក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេកទេស និង នៅក្នុងកម្រិតឧត្តមសិក្សាឱ្យស្របទៅនឹងស្តង់ដាអន្តរជាតិ និង តម្រូវការអភិវឌ្ឍ របស់ប្រទេស។ ពិសេសជាងនេះទៀត ក្នុងកម្រិតមធ្យមសិក្សាបច្ចេកទេសនិងឧត្តមសិក្សា រាជរដ្ឋាភិបាលនឹងបន្តផ្តោតការយកចិត្តទុកដាក់លើការបណ្តុះបណ្តាលវិស្វករនិងអ្នកបច្ចេកទេសឱ្យបានស្របតាមតម្រូវការទីផ្សារ និងការអភិវឌ្ឍប្រទេស។

រាជរដ្ឋាភិបាលនឹងបន្តពង្រីកការអប់រំក្រៅប្រព័ន្ធ តាមរយៈ កម្មវិធីអក្ខរកម្ម និងអក្ខរកម្មវិជ្ជាជីវៈ បង្កើនការសាងសង់មជ្ឈមណ្ឌលសិក្សាសហគមន៍ ព្រមទាំងអនុវត្តកម្មវិធីសមធម៌។ រាជរដ្ឋាភិបាលនឹងបន្តបង្កើនចំណាយថវិកា និងកៀរគរហិរញ្ញប្បទានឱ្យបានច្រើនថែមទៀត សម្រាប់គាំទ្រការអប់រំ ដើម្បីធានាគុណភាពអប់រំឱ្យកាន់តែមានកម្រិតខ្ពស់ និងប្រកបដោយប្រសិទ្ធភាព។ នៅកម្រិតឧត្តមសិក្សាមានការបង្ហាញអំពីតម្រូវការសម្រាប់និស្សិតបញ្ចប់ការសិក្សានៅឧត្តមសិក្សា ដែលនឹងក្លាយជាអ្នកវិទ្យាសាស្ត្រ និយោជិក និងជាប្រជាពលរដ្ឋដែលអាចគិត ត្រិះរិះបានល្អិតល្អន់ និងធ្វើសេចក្តី សម្រេចចិត្តដោយមានអំណះអំណាងត្រឹមត្រូវ ដែលនឹងជះឥទ្ធិពលទៅលើអនាគតរយៈពេលខ្លី និង រយៈពេលវែងរបស់កម្ពុជា។



# គោលនយោបាយអប់រំ យុទ្ធសាស្ត្រ សូចនាករ និងចំណុចដៅសំខាន់ៗ

# ៤. គោលនយោបាយអប់រំ យុទ្ធសាស្ត្រ សូចនាករ និងចំណុចដៅសំខាន់ៗ

## ៤.១ គោលនយោបាយអប់រំ

ដើម្បីសម្រេចគោលដៅនៃគោលនយោបាយជាអាទិភាពខាងលើនេះ ក្រសួងអប់រំ យុវជន និង កីឡា នឹងបន្តអនុវត្តវិធានការសមស្របនៅក្នុងគោលនយោបាយទាំងបីនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដែលសំដៅ៖

- **ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌** តាមរយៈកិច្ចខិតខំកសាងសាលារៀនឱ្យបានកាន់តែជិតផ្ទះប្រជាពលរដ្ឋ កាត់បន្ថយចំនួនសាលាបឋមសិក្សាមិនគ្រប់កម្រិត ជាមួយនឹងការផ្គត់ផ្គង់ថវិកាដំណើរការគ្រឹះស្ថានសិក្សា ផ្តល់គ្រូបង្រៀនឱ្យបានគ្រប់គ្រាន់គ្រប់ ទីកន្លែង និង សាងសង់ផ្ទះ ស្នាក់នៅរបស់គ្រូបង្រៀន អន្តេវាសិកដ្ឋានសម្រាប់សិស្ស- និស្សិតនៅតាមតំបន់ជួបការលំបាក ជាពិសេសសម្រា ប់សិស្ស-និស្សិតជានារី។ ការ ផ្តល់សេវាអប់រំនឹងត្រូវពង្រីកដល់កុមារក្នុងវ័យសិក្សានៅមត្តេយ្យសិក្សា ក៏ដូចជាកុមារពិការ និងជនជាតិភាគ តិច។ ការធានាឱ្យមានការចូលរួមពីសំណាក់សហគមន៍ និង ផ្នែកឯកជន នៅក្នុងដំណើរការនេះមានសារៈសំខាន់ណាស់សម្រាប់ភាពជោគជ័យរយៈពេលវែង។
- **លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ** តាមរយៈការបង្កើនការផ្គត់ផ្គង់សម្ភារសិក្សា បណ្ណាល័យនិងបន្ទប់ពិសោធន៍ បន្តជំរុញការអនុវត្តកំណែទម្រង់កម្មវិធីសិក្សា និងការបង្កើនម៉ោងសិក្សា ព្រមទាំងផ្តល់អាហា រូបករណ៍ (ជាថវិកានិងស្បៀង) ដល់សិស្ស-និស្សិតក្រីក្រឱ្យបានច្រើនថែមទៀត។ លើកកម្ពស់សមត្ថ ភាពលើការបង្រៀន និងការគ្រប់គ្រង ការពង្រឹងការគោរពក្រមសីលធម៌គ្រូបង្រៀន ការកែលម្អបរិស្ថានសាលារៀន (ការផ្គត់ផ្គង់ទឹកស្អាត និងបង្គន់អនាម័យ) ពង្រីកសកម្មភាពការអប់រំតម្រង់ទិសមុខវិជ្ជាជីវៈ ការបង្កើនសកម្មភាពអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាលហិរញ្ញវត្ថុ និងការធានាគុណភាពអប់រំ ។ ការពង្រឹងប្រព័ន្ធ បណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន ការគ្រប់គ្រងវគ្គបំប៉ន និង ការផ្សារភ្ជាប់ការងារទាំងនោះ ទៅនឹងឱកាសការងារ និងការដំឡើងឋានៈ នឹងជួយជំរុញលើកទឹកចិត្តគ្រូបង្រៀន និងមន្ត្រីគ្រប់គ្រង។
- **អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ** តាមរយៈ ការជំរុញការកែលម្អរចនាសម្ព័ន្ធការងារកសាងច្បាប់ និងលិខិតបទដ្ឋានឱ្យបានគ្រប់គ្រាន់ ។ ជាមួយនោះធ្វើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់។ ការបន្តផ្តោតលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រព័ន្ធសវនកម្មផ្ទៃក្នុង ការកសាងផែនការ ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ នឹងជំរុញដល់ការអភិវឌ្ឍស្ថាប័ន និង សមត្ថភាពដើម្បីគ្រប់គ្រងប្រព័ន្ធទាំងនេះ។

## ៤.២ សូចនាករសំខាន់ចាំបាច់សម្រាប់សម្រេចគោលនយោបាយ

ក្រសួងអប់រំ យុវជន និងកីឡានិងដៃគូអភិវឌ្ឍក្នុងវិស័យអប់រំបានព្រមព្រៀងគ្នាកំណត់សូចនាករសំខាន់ចាំបាច់សម្រាប់ពិនិត្យតាមដានវឌ្ឍនភាពសំខាន់ៗ ដែលត្រូវសម្រេចឲ្យបានក្នុងដំណាក់កាលនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ ។ ជាមួយនោះ ក៏បានជ្រើសរើសសូចនាករបំពេញការងារមួយចំនួនទៀត ដើម្បីពិនិត្យតាមដានអំពីលទ្ធផលបំពេញការងាររបស់វិស័យអប់រំ ក៏ដូចជាការវាយតម្លៃការអនុវត្តផែនការតាមដំណាក់កាលនីមួយៗផងដែរ។

សូចនាករសំខាន់ចាំបាច់សម្រាប់សម្រេចគោលនយោបាយ មានសារ ប្រយោជន៍ជួយឲ្យយល់ដឹងបានអំពីវិសាលភាពនៃមូលហេតុចម្បងៗរបស់សកម្មភាពការងារដែលមិនទាន់សម្រេចបាន និង រកវិធានការជាក់លាក់ ដើម្បីធ្វើការកែលម្អលើស្ថានភាពការងារដែលមិនមានភាពជឿនលឿនទៅមុខ។ សូចនាករសំខាន់ចាំបាច់សម្រាប់សម្រេចគោលនយោបាយ មិនមែនជាសូចនាករសម្រាប់ពិនិត្យលើកិច្ចដំណើរការទេ តែវាជាសូចនាករ ដែលបង្ហាញពីលទ្ធផលការងារ និងជា ផលសម្រេចដែលទទួលបាន។ ហេតុនេះ សូចនាករសម្រាប់ពិនិត្យលើកិច្ចដំណើរការទាំងឡាយ មានបញ្ចូលនៅតាមអនុកម្មវិធីនានា។

ក្នុងគោលនយោបាយនីមួយៗរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ មានសូចនាករសំខាន់ចាំបាច់សម្រាប់សម្រេចគោលនយោបាយចំនួនពីរ។ ទន្ទឹមគ្នានេះមានសូចនាករបំពេញការងារប្រមាណ ២០ ទៀតដែលបានជ្រើសរើសសម្រាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំទាំងមូល។

តារាងខាងក្រោមនេះបង្ហាញពីស្ថានភាពបច្ចុប្បន្ន និងចំណុចដៅ សូចនាករសំខាន់ចាំបាច់សម្រាប់សម្រេចគោលនយោបាយ ។

តារាងទី ៤ ៖ សូចនាករសំខាន់ចាំបាច់សម្រាប់សម្រេចគោលនយោយ និងចំណុចដៅ

| សូចនាករសំខាន់ចាំបាច់សម្រាប់សម្រេចគោលនយោបាយ | ស្ថានភាពបច្ចុប្បន្ន | ចំណុចដៅ ឆ្នាំ ២០១៣ |
|---|---|---|
| គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ | | |
| - ភាគរយកុមារអាយុ ៥ ឆ្នាំ ក្នុងការអប់រំកុមារតូច នៅគ្រប់រូបភាព | 39.8 | 60 |
| - ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់បឋមសិក្សាយ៉ាងតិច ៨០% | 106 | 121 |
| គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ | | |
| - ចំនួនសាលារៀនបឋមសិក្សាគ្រប់កម្រិតដែលមានអត្រាត្រួតថ្នាក់តិចជាង ១០% | 3444 លើ 5462 | 4464 លើ 5462 |
| - ការវាយតម្លៃស្តង់ដាជាតិលើលទ្ធផលសិក្សារបស់សិស្ស | | |
| ថ្នាក់ទី ៣ | n.a | 70% |

| សូចនាករសំខាន់ចាំបាច់សម្រាប់សម្រេចគោលនយោបាយ | ស្ថានភាពបច្ចុប្បន្ន | ចំណុចដៅ ឆ្នាំ ២០១៣ |
|---|---|---|
| ថ្នាក់ទី ៦ | n.a | 80% |
| ថ្នាក់ទី ៩ | n.a | 90% |
| គោលនយោបាយទី ៣ ៖ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ | | |
| - ការដកសាច់ប្រាក់ទាន់ពេលនៃថវិកាកម្មវិធីរបស់សាលារៀន | 95% | 95% |
| - ផែនការប្រតិបត្តិប្រចាំឆ្នាំថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | n.a | 24 |

ដើម្បីធានាបានថា ការអនុវត្តគោលនយោបាយអប់រំកំពុងស្ថិតនៅលើផ្លូវដ៏ត្រឹមត្រូវឆ្ពោះទៅរកគោលដៅដែលបានកំណត់ទុក ក្រសួងអប់រំ យុវជន និងកីឡា នឹងធ្វើការពិនិត្យតាមដានយ៉ាងទៀងទាត់ និងរាយការណ៍តាមកាលកំណត់ អំពីវឌ្ឍនភាពរបស់សូចនាករសំខាន់ចាំបាច់សម្រាប់សម្រេចគោល-នយោបាយនីមួយៗ។ ជាពិសេស សូចនាករទាំងនេះនឹងត្រូវយកមកពិនិត្យពិភាក្សាវាយតម្លៃរួមគ្នាក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិស័យអប់រំ ក្នុងសន្និបាត អប់រំប្រចាំឆ្នាំ និងក្នុងការវាយតម្លៃពាក់កណ្ដាលអាណត្តិផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣។

## ៤.៣ យុទ្ធសាស្ត្រជាអាទិភាពសម្រាប់ឆ្នាំ ២០០៩-២០១៣

យុទ្ធសាស្ត្រដើម្បីសម្រេចលទ្ធផល និងចំណុចដៅនៃគោលនយោបាយរួមមាន ៖

*គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌*

- ពង្រីកកម្មវិធីអប់រំកុមារតូចសម្រាប់កុមារអាយុពី ៣ ទៅ ក្រោម ៦ ឆ្នាំ ដោយផ្តោតមុខសញ្ញាទៅលើឃុំដែលមានអត្រាពិតចូលរៀនថ្មីទាប និងមានអត្រាត្រួតថ្នាក់ខ្ពស់នៅបឋមសិក្សា ។
- ធានាឲ្យកុមារអាយុ ៦ ឆ្នាំបានចូលរៀននៅបឋមសិក្សា រួមបញ្ចូលទាំងក្រុមបាត់បង់ឱកាស[3] ដូចជា កុមារពិការ កុមារជនជាតិភាគតិច ពលករកុមារ ជាដើម។
- កាត់បន្ថយបន្ទុកចំណាយរបស់មាតាបិតាសិស្សគ្រប់ទិដ្ឋភាព ដូចជាចំណាយក្រៅផ្លូវការជាដើម។
- បង្កើនចំនួនអាហារូបករណ៍ (ថវិកាឬស្បៀង) ដល់សិស្សមកពីគ្រួសារក្រីក្រ សិស្សក្រីក្ររៀនពូកែ ជាពិសេស សិស្សស្រី ដើម្បីធានាបានការចូលរៀននៅសាលា បឋមសិក្សា និងមធ្យមសិក្សា។ ធានាកំណត់ឲ្យបានលើមុខសញ្ញាសិស្សបឋមសិក្សាក្រីក្រ ឬសុវត្ថិភាពស្បៀង សម្រាប់កម្មវិធីផ្តល់អាហារូបត្ថម្ភ និង កម្មវិធីអាហារូបករណ៍សម្រាប់សិស្សថ្នាក់ទី ៧-៩ ។
- ផ្តល់ការអប់រំបច្ចេកទេសវិជ្ជាជីវៈ ការអប់រំបំណិនជីវិត និងតម្រង់ទិសវិជ្ជាជីវៈនៅសា លារៀនចំណេះទូទៅ ។
- ពង្រឹងការទទួលបានសេវាពីកម្មវិធីអភិវឌ្ឍយុវជនដល់យុវជនបាត់បង់ឱកាស។
- បង្កើនកាលានុវត្តភាពនៃការចូលរៀនប្រកបដោយសមធម៌នៅឧត្តមសិក្សា តាមរយៈការបង្កើនចំនួនអាហារូបករណ៍សម្រាប់សិស្សអាទិភាព (សិស្សពូកែ សិស្សក្រីក្រ សិស្សមកពីតំបន់ដាច់ស្រយាល និងសិស្សនារី) និងការជំរុញឲ្យមានភាពជាដៃគូរវាងសាធារណៈ ឯកជន និងដៃគូអភិវឌ្ឍ។
- ធានាសនិទានកម្មបុគ្គលិកអប់រំសម្រាប់តំបន់ដាច់ស្រយាល និងជួបការលំបាក ។
- បន្តសាងសង់សាលារៀនថ្មី និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬផ្តល់សម្ភាររូបវន្តបន្ថែមចំពោះសាលារៀនបឋមសិក្សាមិនគ្រប់កម្រិតថ្នាក់។
- ពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធកីឡាគ្រប់ប្រភេទនៅគ្រប់កម្រិត។
- ពង្រីកលទ្ធភាពចូលរួមរបស់ផ្នែកឯកជន និងសហគមន៍នៅគ្រប់ក ម្រិតសិក្សា ជាពិសេស ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

---

[3] ក្រុមបាត់បង់ឱកាស រួមមាន ៖ កុមារក្នុងគ្រួសារក្រីក្រ ពលករកុមារ កុមារក្នុងតំបន់ជួបការលំបាក កុមារពិការ កុមាររងគ្រោះដោយសារមេរោគនិងជំងឺអេដស៍ និងជំងឺឆ្លងផ្សេងៗ ។ល។

- ពង្រីកភាពជាដៃគូរវាងរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍លើការងារអប់រំទាំងក្នុង និងក្រៅប្រព័ន្ធ នៅតាមតំបន់ព្រំដែន តំបន់ដាច់ស្រយាល តំបន់ជួបការលំបាក ព្រមទាំងបង្កើនការគាំទ្រចំពោះការផ្តល់បំណិនជីវិតមូលដ្ឋាន និង ការបំប៉នជំនាញវិជ្ជាជីវៈមុខរបរចាំបាច់ ដែលអាចឆ្លើយតបនឹងតម្រូវការសង្គម និង ទីផ្សារពលកម្ម ។

*គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

- កាត់បន្ថយអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សានៅគ្រប់កម្រិតថ្នាក់។
- កែលម្អគុណភាពនៃការបង្រៀន ការរៀន និងការស្រាវជ្រាវនៅគ្រប់កម្រិតទូទាំងប្រទេស។
- អនុវត្តគោលនយោបាយកម្មវិធីសិក្សាថ្មីទាំងនៅបឋមសិក្សា និង នៅមធ្យមសិក្សាបឋមភូមិ ដោយផ្តោតការយកចិត្តទុកដាក់លើម៉ោងបង្រៀន។
- បង្កើតស្តង់ដានៃការសិក្សារបស់សិស្សនៅថ្នាក់ទី ៣ ទី ៦ និងទី ៩ ទូទាំងប្រទេស ។
- លើកកម្ពស់ការអភិវឌ្ឍគ្រូបង្រៀនទាំងការបណ្តុះបណ្តាល និង វិក្រឹតការ។
- បង្កើនរង្វាន់លើកទឹកចិត្ត និងប្រាក់លាភការជូនគ្រូបង្រៀន ផ្អែកលើលទ្ធផលបំពេញការងារ និងស្តង់ដា។
- បង្កើនគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈ និង ការទទួលខុសត្រូវរបស់គ្រឹះស្ថានសិក្សាក្នុងការប្រើប្រាស់ថវិកា និងការសម្រេចចិត្តលើកម្មវិធីនានា ។
- បង្កើនតម្លាភាព និង កែ លម្អការពិនិត្យតាមដានការបំពេញការងារ និងការទទួលខុសត្រូវរបស់គ្រូបង្រៀន សាលារៀន និង គ្រឹះស្ថានឧត្តមសិក្សា ។
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវា អប់រំបច្ចេកទេសវិជ្ជាជីវៈ ការអប់រំបំណិនជីវិត និងការងារតម្រង់ទិសវិជ្ជាជីវៈ។
- ពង្រឹង និងពង្រីកការងារសុខភាពសិក្សានៅតាមអង្គភាព និងគ្រឹះស្ថានសិក្សាគ្រប់កម្រិត និងគ្រប់លំដាប់ថ្នាក់។
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពកម្មវិធីអប់រំកាយនិងកីឡា។
- លើកកម្ពស់ការយល់ដឹង និងគាំទ្រអំពីសារៈសំខាន់របស់ការងារអប់រំកាយនិងកីឡា។
- បង្កើនគុណភាព និងប្រសិទ្ធភាពនៃកម្មវិធីអភិវឌ្ឍយុវជនតម្រង់ទៅរកការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។

## គោលនយោបាយទី៣៖ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ

- បង្កើនគុណភាព និងប្រសិទ្ធភាពនៃការកសាងផែនការ ពិនិត្យតាមដាន ពិនិត្យឡើងវិញ និងវាយតម្លៃការអនុវត្តផែនការ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ពង្រឹងការតម្រឹម សុខុដុមនីយកម្ម និងការសម្របសម្រួល ក្នុងការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ ដែលដឹកនាំដោយក្រសួងនិងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ។
- រៀបចំលិខិតបទដ្ឋានគតិយុត្ត ឲ្យបានច្បាស់លាស់លើគ្រប់វិស័យ និងអនុវិស័យអប់រំទាំងអស់ស្រប តាមច្បាប់ស្តីពីការអប់រំ ។
- ពង្រឹងការផ្តល់សេវាសាធារណៈសម្រាប់វិស័យអប់រំ។
- កែលម្អមូលដ្ឋានសម្រាប់រៀបចំផែនការហិរញ្ញវត្ថុរយៈពេលមធ្យម និងការគ្រប់គ្រងបែបវិមជ្ឈការព្រមទាំងកែលម្អប្រព័ន្ធច្បាប់ និងអភិបាលកិច្ចល្អ ។
- ធានាថាគ្រប់អង្គភាព និងគ្រឹះស្ថានសិក្សាជាអង្គភាពប្រតិបត្តិប្រកបដោយប្រសិទ្ធភាព ក្នុងការគ្រប់គ្រង និងប្រើប្រាស់ថវិកា។
- កែលម្អការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់ទំនើបកម្ម និង វិមជ្ឈការនៃប្រព័ន្ធរដ្ឋបាល និងត្រួតពិនិត្យ ដែលអាចឈានទៅដល់កម្រិតសាលារៀន ។
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល។
- បង្កើនគុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ ។
- ពង្រឹងប្រព័ន្ធពិនិត្យតាមដានការងារហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ពង្រឹងអភិបាលកិច្ចល្អ លើការគ្រប់គ្រង ការប្រព្រឹត្តតាមការណែនាំ និងការបំពេញការងារ។
- ពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងបុគ្គលិក ប្រព័ន្ធ ព័ត៌មានគ្រប់គ្រងអប់រំ ប្រព័ន្ធព័ត៌មានគ្រប់គ្រងឧត្តមសិក្សា ប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ។
- អភិវឌ្ឍសមត្ថភាពមន្ត្រី និងកែ លម្អការគ្រប់គ្រងស្ថាប័នឧត្តមសិក្សា តាមរយៈការបណ្តុះបណ្តាលការលើកទឹកចិត្ត ការកែទម្រង់ស្ថាប័ន និងការគ្រប់គ្រងហិរញ្ញវត្ថុដែលផ្តល់ស្វ័យភាពប្រតិបត្តិ កាន់តែច្រើនដល់គ្រឹះស្ថានឧត្តមសិក្សា។
- អភិវឌ្ឍរចនាសម្ព័ន្ធគ្រប់គ្រងការងារអប់រំវិជ្ជាជីវៈ និងកសាងសមត្ថភាពមន្ត្រីជំនាញការងារអប់រំវិជ្ជាជីវៈ នៅគ្រប់លំដាប់ថ្នាក់។
- ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់កម្មវិធីអភិវឌ្ឍយុវជន ដើម្បីដោះស្រាយតម្រូវការរបស់យុវជនក្នុងតំបន់។

- ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំអំពីការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- ពង្រឹងប្រព័ន្ធពិនិត្យតាមដាន ការបំពេញការងារវិស័យអប់រំ និងផលប៉ះពាល់ ។
- កាត់បន្ថយវិសមភាពយេនឌ័រនៅក្នុងតំណែងអ្នកគ្រប់គ្រងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ការអនុវត្តយុទ្ធសាស្ត្រខាងលើនឹងត្រូវវាស់វែង តាមរយៈវឌ្ឍនភាពនៃតារាងម៉ាទ្រិកសកម្មភាពគោលនយោបាយដូចមាននៅក្នុងឧបសម្ព័ន្ធ ទី៣។



# កម្មវិធីនិងអនុកម្មវិធីនៅក្នុង ផែនការយុទ្ធសាស្ត្រវស័យអប់រំ ឆ្នាំ ២០០៩-២០១៣

# ៥. កម្មវិធីនិងអនុកម្មវិធីនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣

## ៥.១ កម្មវិធីទី ១ ៖ ការអភិវឌ្ឍអប់រំចំណេះទូទៅ និងអប់រំក្រៅប្រព័ន្ធ

### អនុកម្មវិធី ១.១ ៖ ការពង្រីកការអប់រំកុមារតូច

អង្គភាព ៖ នាយកដ្ឋានអប់រំកុមារតូច

### ១. វត្ថុបំណង

វត្ថុបំណងនៃកម្មវិធីនេះគឺ ពង្រីកសេវាអប់រំកុមារតូចតាមគ្រប់រូបភាពសម្រាប់កុមារអាយុពី ០ ទៅក្រោម ៦ឆ្នាំ ពិសេសកុមារក្រីក្រ កុមារជនជាតិ និងកុមារពិការ និងផ្តល់អាទិភាពដល់សេវាមត្តេយ្យសិក្សាសហគមន៍ និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ។ វត្ថុបំណងមួយទៀតគឺផ្តល់ឱ្យមានការប្រែប្រួលលើផ្នែកគុណភាពក្នុងការទទួលបាននូវសេវាអប់រំប្រកបដោយសមធម៌ ។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌*

- ❖ ពង្រីកកម្មវិធីអប់រំកុមារតូចសម្រាប់កុមារអាយុពី ០៣ ទៅក្រោម ៦ ឆ្នាំ ដោយផ្តោតមុខសញ្ញាទៅលើឃុំដែលមានអត្រាចូលរៀនថ្មីទាប និងមានអត្រាត្រួតថ្នាក់ខ្ពស់នៅបឋមសិក្សា។

សកម្មភាពគោលនយោបាយ:

- សេចក្តីណែនាំស្តីពី ការបង្កើតមត្តេយ្យសិក្សាសហគមន៍តាមរយៈការលើកទឹកចិត្តឱ្យមានការប្រើប្រាស់ថវិកាសម្រាប់សេវាអប់រំកុមារតូចដោយសហការជាមួយក្រសួងមហាផ្ទៃ រៀបចំបាននៅឆ្នាំ ២០១០។
- ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយជាតិ ស្តីពីការគាំពារនិងអភិវឌ្ឍកុមារតូចកសាងបាននៅឆ្នាំ ២០១១ ។
- ផែនការសកម្មភាពពង្រីកថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងការអប់រំ កុមារតូចតាមផ្ទះ និងក្រុមខ្នងផ្ទះ កសាងបាននៅឆ្នាំ ២០១១។
- ផែនការសកម្មភាពសម្រាប់បង្កើនថ្នាក់មត្តេយ្យសិក្សានៅក្នុងសាលាបឋមសិក្សា កសាងបាននៅឆ្នាំ ២០១១។
- សេចក្តីណែនាំស្តីពី ការគ្រប់គ្រងមត្តេយ្យសិក្សាឯកជន រៀបចំបានឆ្នាំ ២០១១។
- ដំណើរការនៃវិមជ្ឈការក្នុងការកែលម្អសេវាកម្ម និងគោលនយោបា យគាំពារ និង អភិវឌ្ឍកុមារតូច បានសិក្សានៅឆ្នាំ ២០១១ ។

- កម្មវិធីអប់រំបញ្ចូលគ្នានិងអប់រំពីរភាសានៅសាលាមត្តេយ្យសិក្សា សាកល្បងអនុវត្តនៅឆ្នាំ ២០១២ ។

❖ ពង្រីកលទ្ធភាពចូលរួមរបស់ផ្នែកឯកជន និងសហគមន៍នៅគ្រប់កម្រិតសិក្សា ជាពិសេស ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

សកម្មភាពគោលនយោបាយៈ

- យុទ្ធនាការផ្សព្វផ្សាយការចុះនិងស្រង់ឈ្មោះកុមារឲ្យទទួលសេវាអប់រំកុមារតូច ចាប់អនុវត្តពី ឆ្នាំ ២០១១។

*គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

❖ កែលម្អគុណភាពនៃការបង្រៀន ការរៀន និងការស្រាវជ្រាវនៅគ្រប់កម្រិតទូទាំងប្រទេស។

សកម្មភាពគោលនយោបាយៈ

- សេចក្តីណែនាំស្តីពីការគ្រប់គ្រងកម្មវិធីអប់រំកុមារតូចឱ្យមានគុណភាព និងប្រសិទ្ធភាព រៀបចំបាននៅឆ្នាំ ២០១០។
- កម្មវិធីសិក្សាសម្រាប់កុមារអាយុ ៣ និង ៤ ឆ្នាំ ផ្អែកលើស្តង់ដាសិក្សា កែលម្អរួចរាល់នៅឆ្នាំ ២០១១ ។
- គោលការណ៍ស្តីពី ការលើកទឹកចិត្តដល់គ្រូមត្តេយ្យសិក្សារដ្ឋ គ្រូមត្តេយ្យសិក្សាសហគមន៍ បណ្តាញក្រុមការងារអប់រំកុមារតូចតាមផ្ទះនិងក្រុមខ្នងផ្ទះដែលមានស្នាដៃល្អ រៀបចំបាននៅឆ្នាំ ២០១២ ។

*គោលនយោបាយទី៣ ៖ ការអភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

❖ ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំ អំពីការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

សកម្មភាពគោលនយោបាយ:

- ផែនការអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំកុមារតូចគ្រប់លំដាប់ថ្នាក់និងគ្រប់កម្មវិធី ដោយឆ្លើយគ្នាទៅនឹងយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា រៀបចំបាននៅឆ្នាំ ២០១២។

## ៣. សូចនាករ និងចំណុចដៅ

- ការចូលរៀនរបស់កុមារតូចអាយុ ៥ ឆ្នាំតាមគ្រប់រូបភាពកើនឡើងពី ៣៩.៨% នៅឆ្នាំសិក្សា ២០០៩-២០១០ ទៅ ៦០% នៅឆ្នាំសិក្សា ២០១៣-២០១៤ ។

- ការចូលរៀនរបស់កុមារតូចអាយុពី ៣ ទៅ ៤ ឆ្នាំ តាមគ្រប់រូបភាពកើនឡើងពី ១៥% នៅឆ្នាំ ២០០៩-២០១០ ទៅ ៣០% នៅឆ្នាំ ២០១៣-២០១៤ ។
- ៧០% នៃគ្រូមត្តេយ្យសិក្សាបានទទួលនិងបញ្ចប់ការបណ្តុះបណ្តាល ដោយមានគុណភាពអំពីការអភិវឌ្ឍកុមារតូចពេញលេញ នៅឆ្នាំសិក្សា ២០១៣-២០១៤ ។

## ៤. កម្មវិធី និងសកម្មភាពចម្បង

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- ពង្រីក និងជំរុញការចូលរៀនចំពោះកុមារអាយុពី ៣ ទៅក្រោម ៦ ឆ្នាំ ពិសេស កុមារអាយុ ៥ ឆ្នាំ ឱ្យមានសមត្ថភាពគ្រប់គ្រាន់ដើម្បីចូលរៀនថ្នាក់ទី ១ ប្រកបដោយគុណភាពនិងប្រសិទ្ធភាព ដោយផ្តោតលើការបំប៉នគ្រូមត្តេយ្យសិក្សា និងរៀបចំកម្មវិធីសិក្សាផ្អែកលើស្តង់ដាសិក្សាផ្នែកអប់រំកុមារតូច ។
- ផ្តល់ថវិកាសម្រាប់ដំណើរការសាលាថ្នាក់កុមារមត្តេយ្យសិក្សាមិនគ្រប់កម្រិត និងកុមារអាយុ ៣ និង ៤ ឆ្នាំ ដើម្បីរក្សានិរន្តភាព។
- ពង្រីកកម្មវិធីគាំពារ និងអភិវឌ្ឍកុមារតូចតាមសហគមន៍ដើម្បីអន្តរាគមន៍ទាំងស្រុងដល់ការអប់រំកុមារតូច ជាពិសេសនៅក្នុងមជ្ឈដ្ឋានដែលមានការលំបាកតាមរយៈមាតាបិតា អាណាព្យាបាលកុមារ និងអ្នកគ្រប់គ្រងនិងថែទាំកុមារ ។
- ផ្តល់ថវិកាប្រតិបត្តិការសម្រាប់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រដល់ការកសាងផែនការ ការគ្រប់គ្រងនិងសកម្មភាពពិនិត្យតាមដាន ដោយបង្កើតបញ្ជីឫតារាងពិនិត្យតាមដានដើម្បីធានាគុណភាពផ្នែកអប់រំកុមារតូច។
- ជំរុញឲ្យមានថវិកាលើកកម្ពស់សមត្ថភាពមន្ត្រីអប់រំកុមារតូចគ្រប់លំដាប់ថ្នាក់ និ ងគ្រូបបមដែលបង្រៀនថ្នាក់មត្តេយ្យសិក្សា ។

៤.២ កម្មវិធីមូលធន

ការវិនិយោគ ៖

- ផ្តល់សម្ភារៈរូបវន្តបានគ្រប់គ្រាន់សមស្របតាមវ័យ និងតម្រូវការរបស់កុមារ ជាពិសេសកុមារពិការនៅសាលាមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍ ដោយមានការសហការពីអាជ្ញាធរដែនដី សប្បុរសជន ឬដៃគូអភិវឌ្ឍនានា ។

កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖

- បំប៉នសមត្ថភាពមន្ត្រីជំនាញគ្រប់លំដាប់ថ្នាក់លើការងាររដ្ឋបាល ការងារបច្ចេកទេស របៀបទាក់ទង និងកិច្ចសហការ ជាមួយថ្នាក់ក្រោមជាតិ និងបណ្តាញក្រុមការងារអប់រំ កុមារតូចនៅតាមសហគមន៍។
- គាំទ្រមន្ត្រីទទួលបន្ទុកការងារអប់រំកុមារតូចនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ លើការបង្កើនគុណភាពតាមផ្នែក ឬតាមតំបន់នីមួយៗដែលពាក់ព័ន្ធ ។

## ៥. ការគ្រប់គ្រង និងពិនិត្យតាមដានកម្មវិធី

នាយកដ្ឋានអប់រំកុមារតូចទទួលខុសត្រូវលើការគ្រប់គ្រង និងពិនិត្យតាមដានកម្មវិធីនេះ។ ក្រសួងអប់រំ យុវជន និងកីឡា នឹ ងពិនិត្យឡើងវិញលើការរៀបចំទទួលខុសត្រូវរបស់ថ្នាក់ក្រោមជាតិ ព្រមទាំងការសម្របសម្រួលផងដែរជាមួយស្ថាប័នពាក់ព័ន្ធផ្សេងទៀត រួមមានគណៈកម្មាធិការជាតិ និងលេខាធិការដ្ឋានអប់រំសម្រាប់ទាំងអស់គ្នា និងគណៈកម្មាធិការជាតិ និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសគាំពារ និងអភិវឌ្ឍកុមារតូច។

ក្រសួងអប់រំ យុវជន និងកីឡាសហការជាមួយក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាល ដើម្បីពង្រឹងគំនិតផ្តួចផ្តើមអំពីការចិញ្ចឹមបីបាច់ និងអប់រំកុមារតូច តាមរយៈកម្មវិធីអប់រំកុមារតូចតាមផ្ទះ កម្មវិធីអប់រំឪពុកម្តាយ និងសហការជាមួយ ក្រសួងមហាផ្ទៃ និងក្រសួងកិច្ចការនារី ដើ ម្បីធ្វើវិមជ្ឈការលើការពង្រីកថ្នាក់មត្តេយ្យសិក្សាសហគមន៍នៅក្នុងវិស័យអប់រំ ។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១. កម្មវិធីចរន្ត** | **5982.0** | **6553.0** | **7130.0** | **7700.0** | **8267.0** |
| - មត្តេយ្យសិក្សាសម្រាប់កុមារ អាយុ ៣ទៅ ៥ឆ្នាំ | 2742.0 | 2945.0 | 3149.0 | 3345.0 | 3539.0 |
| - ការអប់រំកុមារតូចផ្អែកលើសហគមន៍និងតាមខ្នងផ្ទះ | 712.0 | 799.0 | 919.0 | 1039.0 | 1159.0 |
| - ពង្រឹងការគាំទ្រ និងការពិនិត្យ តាមដានកម្មវិធី | 150.0 | 191.0 | 210.0 | 229.0 | 248.0 |
| - ពង្រីកកម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូច | 2378.0 | 2618.0 | 2852.0 | 3087.0 | 3321.0 |
| **២. កម្មវិធីមូលធន** | **3462.0** | **13548.0** | **9784.0** | **6795.0** | **6214.0** |
| ការវិនិយោគ | 0 | 9742.0 | 5517.0 | 2070.0 | 1030.0 |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 3462.0 | 3806.0 | 4267.0 | 4725.0 | 5184.0 |
| **ធនធានសរុប** | **9444.0** | **20101.0** | **16914.0** | **14495.0** | **14481.0** |

## អនុកម្មវិធី ១.២ ៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា

អង្គភាព: នាយកដ្ឋានបឋមសិក្សា

### ១. វត្ថុបំណង

វត្ថុបំណងនៃអនុកម្មវិធីនេះគឺ ១) ប្រមូលកុមារដល់និងក្នុងវ័យសិក្សាបានចូលរៀនទាំងអស់គ្នា។ ២) ផ្តល់ការអប់រំបឋមសិក្សាប្រកបដោយគុណភាព។ ៣) រក្សាកុមារឲ្យរៀនចប់ភូមិសិក្សានិងបានបន្តការសិក្សាទៅភូមិសិក្សាបន្ទាប់ទៀត។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌*

- ❖ ធានាឲ្យកុមារអាយុ ៦ ឆ្នាំបានចូលរៀនបឋមសិក្សា រួមបញ្ចូលទាំងក្រុមបាត់បង់ឱកាសដូចជាកុមារពិការ កុមារជនជាតិភាគតិច ពលករកុមារ ជាដើម។

សកម្មភាពគោលនយោបាយ:

- សេចក្តីណែនាំស្តីពី ការអនុវត្តការពន្លឿនការសិក្សាសម្រាប់ក្រុមគោលដៅពិសេស រៀបចំបាននៅឆ្នាំ ២០១០។
- សេចក្តីណែនាំស្តីពី ការអនុវត្តការអប់រំពីរភាសាសម្រាប់កុមារជនជាតិភាគតិច រៀបចំបាននៅឆ្នាំ ២០១០។
- សេចក្តីណែនាំស្តីពី ការធ្វើដំណើរកុមារតាមភូមិចំណុះឱ្យសាលារៀននិងកសាងផែនទីខ្នងផ្ទះ រៀបចំបាននៅឆ្នាំ ២០១១។
- សេចក្តីណែនាំស្តីពី ការកសាងបរិស្ថានសិក្សាឆ្លើយតបទៅនឹងការការពារកុមារ សុខភាពសិក្សា និង យេនឌ័រ រៀបចំបាននៅឆ្នាំ ២០១២។

- ❖ កាត់បន្ថយបន្ទុកចំណាយរបស់មាតាបិតាសិស្សគ្រប់ទិដ្ឋភាពដូចជាចំណាយក្រៅផ្លូវការ ជាដើម។

សកម្មភាពគោលនយោបាយ:

- សេចក្តីណែនាំស្តីពី ការគ្រប់គ្រងនិងប្រើប្រាស់ថវិកាដំណើរការសាលារៀន និង ប្រាក់វិភាគទានដែលបានមកពីសប្បុរសជន មាតាបិតាសិស្សប្រកបដោយតម្លាភាព រៀបចំបាននៅឆ្នាំ ២០១០។

- ❖ ពង្រីកលទ្ធភាពចូលរួមរបស់ផ្នែកឯកជននិងសហគមន៍នៅគ្រប់កម្រិតសិក្សា ជាពិសេសក្រុមប្រឹក្សាឃុំ-សង្កាត់ ។

សកម្មភាពគោលនយោបាយ:

- សេចក្តីណែនាំនិងផែនការសកម្មភាពសម្រាប់ការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍវិស័យអប់រំ រៀបចំបាននៅក្នុងឆ្នាំ ២០១១។
- ការអនុវត្តអនុក្រឹត្យនិងសារាចរ ស្តីពីការ ផ្តល់អាជ្ញាប័ណ្ណជូនគ្រឹះស្ថានបឋមសិក្សាឯកជន បានពិនិត្យឡើងវិញនិងពង្រឹង នៅឆ្នាំ ២០១២។

❖ បន្តសាងសង់សាលារៀនថ្មី និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬផ្តល់សម្ភារបរិក្ខាបន្ថែមចំពោះសាលារៀនបឋមសិក្សាមិនគ្រប់កម្រិតថ្នាក់ ។

សកម្មភាពគោលនយោបាយ:

- សេចក្តីណែនាំស្តីពីការបង្កើតនិងប្រើប្រាស់សាលារៀន ជាពិសេសសាលារៀនមិនគ្រប់ កម្រិតថ្នាក់ឲ្យមានប្រសិទ្ធភាពនិងនិរន្តរភាព រៀបចំបាននៅឆ្នាំ ២០១២។
- តម្រូវការសាលារៀនថ្មីនៅតាមភូមិ ដែលពុំទាន់មានសាលារៀននិងតំបន់ដែលមានសាលារៀននៅឆ្ងាយពីផ្ទះប្រជាជន បានសិក្សានៅឆ្នាំ ២០១២។

❖ បង្កើនចំនួនអាហារូបករណ៍ (ថវិកាឬស្បៀង) ដល់សិស្សមកពីគ្រួសារក្រីក្រ ជាពិសេសសិស្សស្រី ដើម្បីធានាបានការចូលរៀននៅសាលាបឋមសិក្សា និងមធ្យមសិក្សា។ ធានាកំណត់ ឲ្យបានលើមុខសញ្ញាសិស្សបឋមសិក្សាក្រីក្រ ឬសុវត្ថិភាពស្បៀងសម្រាប់កម្មវិធីផ្តល់អាហារូបត្ថម្ភ និងកម្មវិធីអាហារូបករណ៍សម្រាប់ សិស្សថ្នាក់ទី ៤-៦ ។

សកម្មភាពគោលនយោបាយ:

- សេចក្តីណែនាំនិងផែនការសកម្មភាពផ្តល់អាហារូបត្ថម្ភដល់សិស្សក្រីក្រ និងក្រុមងាយរងគ្រោះនៅបឋមសិក្សា រៀបចំបាននៅឆ្នាំ ២០១២។
- តម្រូវការសេវានានានៅតំបន់ព្រំដែនដាក់លាក់ក្នុងខេត្តចំនួន១៥ បានសិក្សានៅឆ្នាំ២០១២។
- គោលនយោបាយអាហារូបករណ៍ជាតិ ជាពិសេសសម្រាប់សិស្សក្រីក្រនិងក្រុមងាយរងគ្រោះនៅបឋមសិក្សា កសាងបាននៅឆ្នាំ២០១៣ ។
- សេចក្តីណែនាំស្តីពីការផ្តល់អាហារូបករណ៍ដល់សិស្សនៅថ្នាក់ទី៤ដល់ទី៦ នៅតាមតំបន់ព្រំដែនក្នុងខេត្តចំនួន១៥ រៀបចំបាននៅឆ្នាំ២០១៣។

### *គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

❖ កាត់បន្ថយអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សានៅគ្រប់កម្រិតថ្នាក់។

សកម្មភាពគោលនយោបាយ:

- សេចក្ដីណែនាំ ដើម្បីជំរុញការអនុវត្តប្រកាសស្ដីពី បទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានបឋមសិក្សាសាធារណៈត្រង់ប្រការទី១៦ ស្ដីពីការធ្វើតេសឡើងថ្នាក់នៅដើមឆ្នាំនិងចុងឆ្នាំសិក្សា រៀបចំបាននៅឆ្នាំ២០១០។
- សេចក្ដីណែនាំស្ដីពីការពង្រឹងនិងធានាឲ្យបានការអនុវត្តម៉ោងបង្រៀនពី ៨៥០ ម៉ោង ទៅ ១០០០ ម៉ោង រៀបចំបាននៅឆ្នាំ២០១១។

❖ កែលម្អគុណភាពបង្រៀន និង រៀននៅគ្រប់កម្រិតទូទាំងប្រទេស ។

សកម្មភាពគោលនយោបាយៈ

- សេចក្ដីណែនាំអនុវត្តគោលការណ៍ស្ដីពីការកំណត់សាលាកុមារមេត្រីតាមកម្រិត រៀបចំបាននៅឆ្នាំ២០១០។
- ផែនការមេនៃកម្រងសាលារៀន បានពិនិត្យឡើងវិញនៅឆ្នាំ ២០១០។
- សេចក្ដីណែនាំ និងផ្សព្វផ្សាយការអនុវត្តក្រមសីលធម៌គ្រូបង្រៀន រៀបចំបាននៅឆ្នាំ២០១១។
- គោលការណ៍ណែនាំពង្រឹងការអនុវត្តកម្មវិធីសាលាកុមារមេត្រី កម្មវិធី ពន្លឿនការសិក្សា និងកម្មវិធីអប់រំពីរភាសា រៀបចំបាននៅឆ្នាំ ២០១១។
- ផែនការមេសាលាកុមារមេត្រីដោយបញ្ចូលខ្លឹមសារស្ដីពីការអប់រំកុមារពិការ បានពិនិត្យឡើងវិញនៅឆ្នាំ ២០១២។

❖ បង្កើនគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈ និង ការទទួលខុសត្រូវរបស់គ្រឹះស្ថានសិក្សា ក្នុងការប្រើប្រាស់ថវិកា និងការសម្រេចចិត្តលើកម្មវិធីនានា ។

សកម្មភាពគោលនយោបាយៈ

- សេចក្ដីណែនាំស្ដីពីការអនុវត្ត កម្មវិធីអប់រំថ្នាក់ពីរភាសា អប់រំបញ្ចូលគ្នា ពន្លឿនការសិក្សា ការប្រើប្រាស់គ្រូសហគមន៍ និងការប្រើប្រាស់បញ្ជីពិនិត្យតាមដាននៅតាមសាលារៀនឬគ្រឹះស្ថានសិក្សា រៀបចំបាននៅឆ្នាំ ២០១១។

❖ បង្កើនតម្លាភាព និង កែ លម្អការពិនិត្យតាមដានការបំពេញការងារ និងការទទួលខុសត្រូវរបស់គ្រូបង្រៀន និងសាលារៀន។

សកម្មភាពគោលនយោបាយៈ

- សេចក្ដីណែនាំស្ដីពី ការផ្សព្វផ្សាយ លទ្ធផលសិក្សារបស់សិស្សសំដៅជំរុញការសិក្សា និងស្វ័យសិក្សារបស់សិស្ស រៀបចំបាននៅឆ្នាំ២០១២។

- លទ្ធផលនៃការបំពេញការងាររបស់ក្រុមបំប៉ននិងពិនិត្យតាមថ្នាក់ក្រុង ស្រុក ខណ្ឌ បានសិក្សានៅឆ្នាំ ២០១២។

*គោលនយោបាយទី៣ ៖ ការអភិវឌ្ឍស្ថាប័ន និង កសាងសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

❖ ពង្រឹងប្រព័ន្ធពិនិត្យតាមដានការបំពេញការងារវិស័យអប់រំ និង ផលប៉ះពាល់ ។

សកម្មភាពគោលនយោបាយ:

- សេចក្តីណែនាំដល់ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌលើការបំពេញការងារអប់រំបឋមសិក្សារៀបចំបាននៅឆ្នាំ ២០១២ ។

## ៣. សូចនាករ និងចំណុចដៅ

- អត្រាពិតចូលរៀនថ្មីកើនពី ៩១.៩% នៅឆ្នាំសិក្សា ២០០៨-២០០៩ ទៅ ១០០% នៅឆ្នាំសិក្សា ២០១៣-២០១៤។
- អត្រាពិតនៃការសិក្សានៅបឋមសិក្សាកើនពី ៩៤.៤% នៅឆ្នាំសិក្សា ២០០៨-២០០៩ ដល់ ៩៨.0% នៅឆ្នាំ ២០១៣-២០១៤ ។
- អត្រាបញ្ចប់ការសិក្សាកើនពី ៨៥.៥% នៅឆ្នាំសិក្សា ២០០៨-២០០៩ ដល់ ១០០% នៅឆ្នាំសិក្សា ២០១៣-២០១៤។
- អត្រាត្រួតថ្នាក់ថយចុះពី ៨.៩% នៅឆ្នាំសិក្សា ២០០៨-២០០៩ មកត្រឹម៥% នៅឆ្នាំសិក្សា ២០១៣-២០១៤។
- អត្រាបោះបង់ការសិក្សាថយចុះពី ៨.៣% នៅឆ្នាំសិក្សា ២០០៨-២០០៩ មកត្រឹម ៥% នៅឆ្នាំសិក្សា ២០១៣-២០១៤។
- យ៉ាងហោចណាស់ ៧៥% នៃសាលាបឋមសិក្សាទាំងអស់នឹងជាសាលាកុមារមេត្រីនៅឆ្នាំសិក្សា ២០១៣-២០១៤។

## ៤. សកម្មភាព និងកម្មវិធីចម្បងៗ

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- ផ្តល់ថវិកាដំណើរការសាលារៀននៅទូទាំងប្រទេស ដោយផ្អែកលើការព្រមព្រៀងបង្កើនកញ្ចប់ថវិកានិងរូបមន្តបែងចែកថវិកាសម្រាប់សិស្សម្នាក់ៗជារៀងរាល់ឆ្នាំ ពិសេសសម្រាប់សាលារៀនជួបការលំបាក ។
- ពង្រឹង និង ពង្រីក កម្មវិធីសាលាកុមារមេត្រីដែលមានសកម្មភាពបំប៉នសមត្ថភាពដល់ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌនិង កម្មវិធីបណ្ណាល័យ ។

- លើកទឹកចិត្តគ្រូបង្រៀនល្អនិងសាលារៀនល្អ។
- ពិនិត្យតាមដានដំណើរការសាលារៀន។

៤.២ កម្មវិធីមូលធន

*ការវិនិយោគ ៖*

- សាងសង់បង្គន់អនាម័យ អណ្តូងទឹក បន្ទប់ធនធាន បណ្ណាល័យនៅតាមសាលាបឋមសិក្សាពិសេស នៅតំបន់ដាច់ស្រយាល។
- សាងសង់កន្លែងស្នាក់នៅឲ្យគ្រូបង្រៀននៅតាមតំបន់ដាច់ស្រយាល។
- ផ្តល់បន្ទប់រៀនបន្ថែមដល់សាលាមិនគ្រប់កម្រិត សាលាដែលមានសិស្សច្រើន និងសាលាដែលរៀន ៣ វេន។
- ការផ្តល់ឧបករណ៍ជំនួយសម្រាប់កុមារពិការ ឱ្យសមស្របឆ្លើយតបទៅនឹងតម្រូវការការសិក្សា ដូចជា វែនតា រទេះរុញ កាសស្តាប់ជាប់ត្រចៀក ចាប់ពីឆ្នាំ២០០៩។

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- ពង្រឹងសមត្ថភាពមន្ត្រីថ្នាក់កណ្តាល ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់កម្រងសាលាដើម្បីលើកកម្ពស់ការងារផែនការ ការគ្រប់គ្រង និងការពិនិត្យតាមដាននៃសកម្មភាព និងចំណាយប្រតិបត្តិការ ដើម្បីជំរុញការអនុវត្តកម្មវិធីសាលាកុមារមេត្រី។
- គាំទ្រដល់ការបង្កើត និងពង្រឹងក្រុម បំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលនឹងទទួលខុសត្រូវជួយកម្រងសាលារៀន នៅក្នុងការអនុវត្តការពិនិត្យតាមដានតាមបែបវិមជ្ឈការលើការបំពេញការងាររបស់សាលារៀន។
- ពង្រឹងនិងពង្រីកកម្មវិធីសាលាកុមារមេត្រី ដែលមានសកម្មភាពប្រសិទ្ធភាពការរៀននិងបង្រៀន ការសិក្សាចិត្តសង្គម ការអប់រំពិសេស ការអប់រំបញ្ចូលគ្នា ការបង្រៀនថ្នាក់គួប ការអប់រំពីរភាសា ស្តង់ដាកម្មវិធីសិក្សាអប្បរមា កុមារក្រៅសាលា អាន- សរសេរថ្នាក់ទី១ កម្មវិធីបណ្ណាល័យ ជំនាញបំណិនជីវិតតាមតំបន់ ការការពារមេរោគអេដស៍/ជំងឺអេដស៍ បញ្ហាសុខភាពដ៏ទៃទៀត អាហារូបករណ៍ អាហារូបត្ថម្ភ និង កញ្ចប់ថវិកាសម្រាប់កែលម្អសាលារៀន ជាពិសេស នៅតាមតំបន់ព្រំដែន និងតំបន់ត្រីកោណ។
- លើកកម្ពស់ និងផ្សព្វផ្សាយជារៀងរាល់ឆ្នាំពីសារៈសំខាន់នៃការអប់រំដល់សហគមន៍ និងអាជ្ញាធរដែនដី ដើម្បីធានាការអភិវឌ្ឍដែលមានការចូលរួមនៅថ្នាក់តំបន់ជាមួយនឹងចីរភាព និងភាពជាម្ចាស់។

## ៥. ការគ្រប់គ្រងកម្មវិធីនិងពិនិត្យតាមដាន

នាយកដ្ឋានបឋមសិក្សាគ្រប់គ្រងនិងពិនិត្យតាមដានផលសម្រេចរបស់កម្មវិធីនេះ។ ការពិនិត្យតាមដានវឌ្ឍនភាពរបស់កម្មវិធីជាការទទួលខុសត្រូវរបស់ក្រុមគ្រូឧទ្ទេសបង្គោលថ្នាក់ជាតិ និងក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌស្របតាមផែនការការងារ និងផែនការអភិវឌ្ឍសាលារៀនដែលបានឯកភាព។ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ជាអ្នកគ្រប់គ្រងថវិការបស់កម្មវិធីនេះ និង បើកផ្តល់សាច់ប្រាក់ទៅឱ្យសាលារៀន។ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវធ្វើរបាយការណ៍ ប្រចាំខែជូនដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ស្តីពីសកម្មភាពបច្ចេកទេស និងស្ថានភាពហិរញ្ញវត្ថុរបស់កម្មវិធី។

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ទទួលខុសត្រូវក្នុងការពិនិត្យតាមដាន លទ្ធផល និងការរីកចម្រើនទូទៅនៃសកម្មភាពផ្នែកបច្ចេកទេស និងការផ្តល់ហិរញ្ញប្បទាន របស់កម្មវិធីកែលម្អកំហុសឆ្គងពេលចាំបាច់ និងធានាការបញ្ជូនរបាយការណ៍ប្រចាំខែទាន់ពេលវេលា។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាសជូន នាយកដ្ឋានបឋមសិក្សា ទាំងផ្នែកបច្ចេកទេស និង ហិរញ្ញវត្ថុ។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១. កម្មវិធីចរន្ត** | **45038.1** | **43775.4** | **44330.9** | **54269.5** | **60456.2** |
| ថវិកាដំណើរការសាលារៀន | 22641.1 | 23139.3 | 23259.6 | 24499.7 | 24499.7 |
| ការពង្រឹងសកម្មភាពរៀន និងបង្រៀន | 18128.2 | 17666.2 | 16944.7 | 18411.4 | 18411.4 |
| ការពង្រឹងការពិនិត្យតាមដានកម្មវិធី ការកសាងសមត្ថភាពនិងលើកទឹកចិត្ត | 4268.8 | 2969.9 | 4126.6 | 11358.4 | 17545.1 |
| **២. កម្មវិធីមូលធន** | **4268.8** | **2969.9** | **4126.6** | **11358.4** | **17545.1** |
| ការវិនិយោគ | 11.8 | 12.0 | 12.0 | 16.0 | 18.0 |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 4257.0 | 2957.9 | 4114.6 | 11342.4 | 17527.1 |
| **សរុបរួម** | **49306.9** | **46745.3** | **48457.5** | **65627.9** | **78001.3** |

## អនុកម្មវិធី ១.៣ ៖ ការពង្រឹងគុណភាព និង ប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា

អង្គភាព ៖ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

### ១. វត្ថុបំណង

វត្ថុបំណងនៃកម្មវិធីនេះ គឺកាត់បន្ថយឧបសគ្គនៃការចូលរៀន និងកែ លម្អគុណភាព និង ប្រសិទ្ធភាព ដើម្បីបង្កើនអត្រាគង់វង្សពីថ្នាក់ទី ៧ ដល់ទី ៩ និងអត្រាឆ្លងភូមិសិក្សាពីថ្នាក់ទី ៩-១០ ។

វត្ថុបំណងទីពីរគឺ ធានាការចូលរៀនប្រកបដោយសមធម៌នៅមធ្យមសិក្សាទុតិយភូមិក្រោយពីប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ជាពិសេសនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល ដែលជាប្រភពធនធានមនុស្សសម្រាប់ចូលរៀននៅមធ្យមសិក្សាបច្ចេកទេសវិជ្ជាជីវៈ និងឧត្តមសិក្សា។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌*

❖ ពង្រីកលទ្ធភាពចូលរួមរបស់ផ្នែកឯកជននិងសហគមន៍នៅគ្រប់កម្រិតសិក្សា ជាពិសេសក្រុមប្រឹក្សាឃុំ-សង្កាត់។

សកម្មភាពគោលនយោបាយ ៖

- សេចក្តីណែនាំអំពី ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងគ្រឹះស្ថានមធ្យមសិក្សា រៀបចំបាននៅឆ្នាំ ២០១១។

❖ បន្តសាងសង់សាលារៀនថ្មី និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬផ្តល់សម្ភាររូបវន្តបន្ថែមចំពោះសាលារៀនបឋមសិក្សាមិនគ្រប់កម្រិតថ្នាក់។

សកម្មភាពគោលនយោបាយ ៖

- លិខិតបទដ្ឋានស្តីពី តួនាទីនិងភារកិច្ចរបស់វិទ្យាល័យធនធាន រៀបចំបាននៅឆ្នាំ ២០១០។
- លិខិតបទដ្ឋានស្តីពី ការគ្រប់គ្រងវិទ្យាល័យនិងអគារធនធាន រៀបចំបាននៅឆ្នាំ ២០១០។
- ប្រកាសស្តីពី ការទទួលស្គាល់វិទ្យាល័យធនធាន រៀបចំបាននៅឆ្នាំ ២០១១។

*គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

❖ កែលម្អគុណភាពនៃការបង្រៀន ការរៀន និងការស្រាវជ្រាវនៅគ្រប់កម្រិតទូទាំងប្រទេស។

សកម្មភាពគោលនយោបាយ ៖

- លិខិតបទដ្ឋានក្នុងការប្រើប្រាស់គ្រូចូលនិវត្តន៍ឱ្យមកបម្រើការជារបបប្រាក់ម៉ោងបន្ថែម រៀបចំបាននៅឆ្នាំ២០១០។

- សេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីសិក្សាថ្មីនៅមធ្យមសិក្សា បានកែលម្អនៅឆ្នាំ ២០១០។
- បទបញ្ជាផ្ទៃក្នុងនៃសាលាមធ្យមសិក្សាចំណេះទូទៅ បានកែលម្អនៅឆ្នាំ ២០១០។
- លិខិតបទដ្ឋានក្នុងការបង្កើត និងគ្រប់គ្រងបណ្ណាល័យ រៀបចំបាននៅឆ្នាំ ២០១៣។

❖ អនុវត្តគោលនយោបាយកម្មវិធីសិក្សាថ្មីទាំងនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ដោយផ្តោតការយកចិត្តទុកដាក់លើម៉ោងបង្រៀន។

សកម្មភាពគោលនយោបាយ ៖

- សេចក្តីណែនាំស្តីពីការផ្សព្វផ្សាយលទ្ធផលតេសស្តង់ដារបស់សិស្សថ្នាក់ទី ៣ ទី ៦ និង ទី ៩ ទៅអ្នកពាក់ព័ន្ធ រៀបចំបាននៅឆ្នាំ ២០១២។

## ៣. សូចនាករ និងចំណុចដៅ

- អត្រាពិតនៃការសិក្សានៅថ្នាក់ទី ៧-៩ កើនពី ៣២% នៅឆ្នាំសិក្សា ២០០៩-២០១០ ដល់ ៥១% នៅឆ្នាំសិក្សា ២០១៣-២០១៤ ។
- អត្រាឆ្លងភូមិសិក្សានៅថ្នាក់ទី ៩-១០ កើនពី ៧៣% នៅឆ្នាំសិក្សា ២០០៩-២០១០ ដល់ ៨៥% នៅឆ្នាំសិក្សា ២០១៣-២០១៤ ។
- សិស្សសម្រេចបានស្តង់ដាកម្មវិធីសិក្សា មុខវិជ្ជាភាសាខ្មែរថ្នាក់ទី៩ កើនពី៦២% នៅឆ្នាំសិក្សា ២០០៩-២០១០ ដល់ ៨០% នៅឆ្នាំសិក្សា ២០១៣-២០១៤។
- សិស្សសម្រេចបានស្តង់ដាកម្មវិធីសិក្សាមុខវិជ្ជាគណិតវិទ្យាថ្នាក់ទី៩ កើនពី៣២% នៅឆ្នាំសិក្សា ២០០៩-២០១០ ដល់ ៧០% ឆ្នាំសិក្សា២០១៣-២០១៤។
- វិទ្យាល័យធនធានមានចំនួន ៤៥ នៅឆ្នាំសិក្សា ២០១៣-២០១៤។
- អត្រារួមនៃការសិក្សានៅថ្នាក់ទី ១០-១២ កើនពី ៣២% នៅឆ្នាំសិក្សា ២០០៩-២០១០ ទៅ ៤០% នៅឆ្នាំសិក្សា ២០១៣-២០១៤។
- អត្រាបញ្ចប់ការសិក្សាថ្នាក់ទី ១០-១២ កើនពី ៧០% ក្នុងឆ្នាំសិក្សា ២០០៩-២០១០ ដល់ ៨០% នៅឆ្នាំសិក្សា ២០១៣-២០១៤។

## ៤. កម្មវិធី និងសកម្មភាពចម្បងៗ

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- ផ្តល់ថវិកាដំណើរការសាលារៀននៅទូទាំងប្រទេស ដោយផ្អែកលើការសម្របសម្រួលកញ្ចប់ថវិកាប្រចាំឆ្នាំ និង រូបមន្តបែងចែកថវិកាឡើងវិញតាមស្ថានភាពជាក់ស្តែងដែលបានឯកភាព ។
- ផ្តល់ថវិកាលើកទឹកចិត្តសិស្សពូកែប្រចាំឆ្នាំ។
- ការពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សាការរៀននិងបង្រៀន ការងារគ្រប់គ្រង ការកសាងផែនការ ការងារប្រឡង លទ្ធផលសិក្សារបស់សិស្ស។
- ការពង្រឹងសមត្ថភាពស្តីពីការរៀបចំផែនការអភិវឌ្ឍសាលារៀន ការគ្រប់គ្រងបណ្ណាល័យ ការបង្រៀន ការគ្រប់គ្រង និងការប្រឡង ។
- ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកគណិតវិទ្យា អក្សរសាស្ត្រ និងរូបវិទ្យា។

៤.២ កម្មវិធីមូលធន

*ការវិនិយោគ ៖*

- ផ្តល់មធ្យោបាយទំនាក់ទំនងសម្រាប់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដូចជាឧបករណ៍អេឡិចត្រូនិចឧបករណ៍ និង សម្ភារពិសោធន៍។
- ផ្តល់ថវិកាដំណើរការវិទ្យាល័យធនធាន ក្នុងដំណាក់កាលពីរឆ្នាំដំបូង និងផ្ទេរការទទួលខុសត្រូវដល់ក្រសួងនៅឆ្នាំបន្តបន្ទាប់។
- ផ្តល់ថវិកាប្រតិបត្តិសម្រាប់សាលាកុមារមេត្រី។

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- រៀបចំឯកសារបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងការបង្រៀននៅវិទ្យាល័យធនធាននិងសាលាមធ្យមសិក្សាបណ្តាញ។
- សិក្សាផលប៉ះពាល់នៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី។
- ធ្វើតេសស្តង់ដាដើម្បីវាស់លទ្ធផលសិក្សារបស់សិស្សនៅ ថ្នាក់ទី ៣ ទី៦ និងទី៩ នៅទូទាំងប្រទេសរៀងរាល់ឆ្នាំតាមខួបនៃកម្រិតថ្នាក់ និងតាមវិធីជ្រើសរើសសំណាកគំរូ។

## ៥. ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

នាយកដ្ឋានធម្យមសិក្សាចំណេះទូទៅគ្រប់គ្រងការអភិវឌ្ឍអនុវិស័យទាំងមូល ដោយផ្តោតលើការធ្វើផែនការ ការពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ការប្រើប្រាស់ធនធាន និងការកសាង

សមត្ថភាព។ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅផ្តល់ជំនួយទាំងបច្ចេកទេស និងការគ្រប់គ្រងដល់ថ្នាក់ក្រោមជាតិដើម្បីអនុវត្តនូវតួនាទី និងភារកិច្ចរបស់គេ។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តទទួលខុសត្រូវរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំសម្រាប់អនុវិស័យ អនុវត្តគ្រប់សេចក្តីណែនាំរបស់ថ្នាក់ជាតិនិងជួយដល់សាលារៀនទាំងផ្នែកបច្ចេកទេស រដ្ឋបាល និងគ្រប់គ្រង រួមទាំងកិច្ចការហិរញ្ញវត្ថុ។ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌទាំង ១៩៣ ជួយសម្របសម្រួលផ្នែករដ្ឋបាល។ សាលាមធ្យមសិក្សានីមួយៗទទួលខុសត្រូវរៀបចំកសាង និងអនុវត្តផែនការអភិវឌ្ឍសាលារៀន ដោយមានការចូលរួមពេញលេញពីសហគមន៍ និងស្របតាមគ្រប់ការណែនាំពីថ្នាក់ជាតិ។ គ្រប់គ្រង និងអនុវត្តរាល់កម្មវិធីជាតិដែលថ្នាក់ជាតិបានកំណត់ឲ្យសាលារៀន។ ពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងសាលារៀន។ សុំការអនុញ្ញាត្តិពីថ្នាក់ជាតិរាល់ការអនុវត្តសកម្មភាពផ្សេងៗដែលអាចមានការប៉ះពាល់ដល់ការសិក្សារបស់សិស្ស ពីសំណាក់អង្គការ មហាជននានា។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១- កម្មវិធីចរន្ត** | **23900** | **26660** | **36139** | **40247** | **45076** |
| - មធ្យមសិក្សាបឋមភូមិ | **15700** | **16960** | **22147** | **24822** | **27959** |
| ថវិកាដំណើរការសាលារៀន | 12700 | 13200 | 14053 | 15911 | 17793 |
| ថវិកាពង្រឹងសមត្ថភាពគ្រប់គ្រង | 2500 | 3010 | 4047 | 4456 | 4901 |
| ការពិនិត្យតាមដាន | 500 | 750 | 1094 | 1204 | 1325 |
| - មធ្យមសិក្សាទុតិយភូមិ | **8200** | **9700** | **13992** | **15425** | **17117** |
| ថវិកាដំណើរការសាលារៀន | 7100 | 8500 | 9618 | 10609 | 11820 |
| រង្វាន់សិស្សពូកែ | 650 | 700 | 1249 | 1375 | 1512 |
| ការពិនិត្យតាមដាន | 450 | 500 | 3126 | 3441 | 3785 |
| **ធនធានសរុប** | **23900** | **26660** | **36139** | **40247** | **45076** |

## អនុកម្មវិធី ១.៤ ៖ ការចូលរៀនប្រកបដោយសមធម៌និងផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាក

អង្គភាព ៖ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

### ១. វត្ថុបំណង

វត្ថុបំណងអនុកម្មវិធីនេះគឺ ធានាបង្កើនឱកាសអប់រំសម្រាប់សិស្សក្រីក្ររៀនពូកែ និងសិស្សមកពីគ្រួសារក្រីក្របំផុត ជាពិសេសសិស្សស្រី និងសិស្ស ជនជាតិភាគតិច តាមរយៈការបង្កើនចំនួនអាហារូបករណ៍ ។

វត្ថុបំណងជាយុទ្ធសាស្ត្ររយៈពេលវែងរបស់កម្មវិធី គឺបង្កើន ការចូលរៀន ការរក្សាទុកសិស្ស និងការឡើងថ្នាក់របស់សិស្សមកពីគ្រួសារក្រីក្របំផុតនិង សិស្សក្រីក្ររៀនពូកែនៅមធ្យមសិក្សា ។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌*

- ❖ បង្កើនចំនួនសិស្សអាហារូបករណ៍ (ថវិកាឬស្បៀង) ដល់សិស្សមកពីគ្រួសារក្រីក្រ សិស្សក្រីក្ររៀនពូកែ ជាពិសេសសិស្សស្រី ដើម្បីធានាការចូលរៀនរបស់ពួកគេនៅសាលាបឋមសិក្សា និង មធ្យមសិក្សា។ ធានាកំណត់ឲ្យបានលើមុខសញ្ញាសិស្សបឋមសិក្សាក្រីក្រឬសុវត្ថិភាពស្បៀងសម្រាប់កម្មវិធីផ្តល់អាហារូបត្ថម្ភ និងកម្មវិធីអាហារូបករណ៍សម្រាប់សិស្សថ្នាក់ទី ៧-៩។

សកម្មភាពគោលនយោបាយ ៖

- កម្មវិធីជាតិអាហារូបករណ៍ រៀបចំបាននៅឆ្នាំ ២០១១។
- អនុក្រឹត្យស្តីពីការផ្តល់អាហារូបករណ៍ដល់សិស្សមកពីគ្រួសារក្រីក្រនៅមធ្យមសិក្សាទុតិយភូមិនឹងត្រូវអនុម័តនៅឆ្នាំ ២០១១។

### ៣. សូចនាករ និងចំណុចដៅ

- អាហារូបករណ៍ចំនួន ១០% ក្នុង ១ ឆ្នាំ សម្រាប់មធ្យមសិក្សាបឋមភូមិក្នុងនោះ ៦០ % សម្រាប់សិស្សស្រី ។
- អាហារូបករណ៍ចំនួន ៣% ក្នុង ១ ឆ្នាំ សម្រាប់មធ្យមសិក្សាទុតិយភូមិក្នុងនោះ ៦០ % សម្រាប់សិស្សស្រី ។

## ៤. កម្មវិធី និងសកម្មភាពចម្បងៗ

### ៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- ផ្តល់អាហារូបករណ៍ដល់សិស្សថ្នាក់ទី ៧-៩ ដែលបានជ្រើសរើស ដូចជាសិស្សមកពីគ្រួសារក្រីក្របំផុត និង ក្រុមជួបការលំបាកផ្សេងៗទៀត រួមមាន សិស្សស្រី និង ជនជាតិភាគតិច ។ សិស្សស្រីត្រូវមានចំនួនជាអប្បបរមា ៦០% នៃចំនួនសិស្សអាហារូបករណ៍ទាំងអស់នៅក្នុងសាលារៀនដែលបានជ្រើសរើស។
- ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្របំផុតនិងសិស្សក្រីក្ររៀនពូកែថ្នាក់ទី១០-១២ ដោយផ្អែកលើកម្រិតនៃភាពក្រីក្រ និងលទ្ធផលប្រលង សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ។ សិស្សស្រី ត្រូវមានចំនួនជាអប្បបរមា ៦០% នៃចំនួនសិស្សអាហារូបករណ៍ទាំងអស់នៅក្នុងសាលាដែលបានជ្រើសរើស។
- ផ្តល់ថវិកាដំណើរការគណៈកម្មការគ្រប់គ្រងមូលដ្ឋាន ដើម្បីការពិនិត្យតាមដាន ការជ្រើសរើស និងការប្រជុំ។
- ការពិនិត្យតាមដានការអនុវត្តកម្មវិធីអាហារូបករណ៍របស់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

### ៤.២ កម្មវិធីមូលធន

*ការវិនិយោគ ៖*

- អភិវឌ្ឍសម្ភារបរិក្ខារសម្រាប់ការគ្រប់គ្រងកម្មវិធីអាហារូបករណ៍ ។

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- សិក្សាផលប៉ះពាល់ពីកម្មវិធីអាហារូបករណ៍នៅមធ្យមសិក្សាបឋមភូមិ។
- ការប្រមូលទិន្នន័យស្តីពីសិស្សក្រីក្រនៅតាមមូលដ្ឋាន សាលារៀន និងសហគមន៍ ។
- កសាងសមត្ថភាពអ្នកគ្រប់គ្រង និងអ្នកបច្ចេកទេសនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីការកសាងផែនការកម្មវិធីសម្រាប់មុខសញ្ញាក្រីក្រ ការបែងចែកថវិកា ការពិនិត្យតាមដាន វាយតម្លៃ និងការស្រាវជ្រាវប្រតិបត្តិ។

## ៥. ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

ការគ្រប់គ្រងកម្មវិធីផ្តោតលើវិមជ្ឈការដល់សាលារៀននិងសហគមន៍។ អគ្គនាយកដ្ឋានអប់រំ នឹងចាត់តាំងអង្គភាពទទួលខុសត្រូវលើគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ការគ្រប់គ្រងទទួលខុសត្រូវហិរញ្ញប្បទាន។

គណៈកម្មការគ្រប់គ្រងអាហារូបករណ៍ថ្នាក់រាជធានី-ខេត្ត ទទួលខុសត្រូវលើការគ្រប់គ្រងពិនិត្យ

តាមដាន និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់សាលារៀន និងសហគមន៍។ នៅថ្នាក់សាលារៀន និងសហគមន៍ គណៈកម្មការគ្រប់គ្រងមូលដ្ឋានត្រូវដឹកនាំគ្រប់គ្រងកម្មវិធីអាហារូបករណ៍ប្រចាំថ្ងៃទៅតាមសៀវភៅប្រតិបត្តិការអាហារូបករណ៍។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | 2009 | 2010 | 2011 | 2012 | 2013 |
|---|---|---|---|---|---|
| **១. កម្មវិធីចរន្ត** | **6917** | **8230** | **9280** | **10342** | **11497** |
| អាហារូបករណ៍នៅមធ្យមសិក្សាបឋមភូមិ | 6172 | 7375 | 8306 | 9152 | 10197 |
| អាហារូបករណ៍នៅមធ្យមសិក្សាទុតិយភូមិ | 0 | 0 | 0 | 0 | 0 |
| កិច្ចដំណើរការ LMCs | 240 | 290 | 327 | 460 | 500 |
| ពិនិត្យតាមដាន | 505 | 575 | 647 | 730 | 800 |
| **ធនធានសរុប** | **6917** | **8230** | **9280** | **10342** | **11497** |

## អនុកម្មវិធី ១.៥ ៖ ការពង្រីកការអប់រំក្រៅប្រព័ន្ធ

អង្គភាព ៖ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

### ១- វត្ថុបំណង

វត្ថុបំណងនៃអនុកម្មវិធីនេះ គឺធានាថា កុមារ យុវជន និងជនពេញវ័យ ជនក្រីក្រ និងជនដែលបាត់បង់ឱកាសទទួលបានការអប់រំក្នុងប្រព័ន្ធគ្រប់រូប ឲ្យ យល់ដឹងនូវសិទ្ធិ និងទទួលបានការអប់រំយ៉ាងហោចកម្រិតមូលដ្ឋាន និងមានលទ្ធភាពបន្តការរៀនសូត្រពេញមួយជីវិត។ វត្ថុបំណងមួយទៀតគឺផ្តល់ឱកាសដល់យុវជន និងមនុស្សពេញវ័យឲ្យទទួលបានចំណេះដឹង បច្ចេកទេស ជំនាញ និង បំណិនជីវិត ដើម្បីអភិវឌ្ឍជីវភាពរស់នៅ។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌*

❖ ពង្រីកភាពជាដៃគូរវាងរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍លើការងារអប់រំ ទាំងក្នុង និងក្រៅប្រព័ន្ធនៅតាមតំបន់ព្រំដែន តំបន់ជួបការលំបាក ព្រមទាំងបង្កើនការគាំទ្រចំពោះការផ្តល់បំណិនជីវិតមូលដ្ឋាន និង ការបំប៉នជំនាញវិជ្ជាជីវៈមុខរបរចាំបាច់ ដែលអាចឆ្លើយតបនឹងតម្រូវការសង្គម និងទីផ្សារពលកម្ម ។

សកម្មភាពគោលនយោបាយ:

- សេចក្តីណែនាំស្តីពី ការវាយតម្លៃភាពជាដៃគូអប់រំ នៅក្នុងការងារអប់រំក្រៅប្រព័ន្ធផ្អែកលើប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំក្រៅប្រព័ន្ធ រៀបចំបាននៅឆ្នាំ ២០១១។
- ផែនការសម្រាប់រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានអប់រំក្រៅប្រព័ន្ធ កសាងបាននៅឆ្នាំ ២០១៣។

*គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

❖ កាត់បន្ថយអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សានៅគ្រប់កម្រិតថ្នាក់។

សកម្មភាពគោលនយោបាយ:

- សេចក្តីណែនាំស្តីពី ការអនុវត្តកម្មវិធីសមមូល រៀបចំបាននៅឆ្នាំ ២០១១។
- ការអនុវត្តកម្មវិធីចូលរៀនឡើងវិញ កម្មវិធីសមមូល និងមជ្ឈមណ្ឌលសិក្សា សហគមន៍ បានពិនិត្យឡើងវិញនៅឆ្នាំ ២០១៣។

*គោលនយោបាយទី៣ ៖ ការអភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

- ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំ អំពីការងារគ្រប់គ្រងនិងភាពជាអ្នកដឹកនាំនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

សកម្មភាពគោលនយោបាយ៖

- ផែនការអភិវឌ្ឍសមត្ថភាពរយៈពេលមធ្យមសម្រាប់មន្ត្រីអប់រំក្រៅប្រព័ន្ធរាជធានី ខេត្ត រៀបចំបាននៅឆ្នាំ ២០១២ ។

## ៣- សូចនាករ និងចំណុចដៅ

- ចំនួនសិស្សបញ្ចប់កម្មវិធីចូលរៀនឡើងវិញមាន ៩០% បានចូលរៀនក្នុងប្រព័ន្ធវិញ។
- អត្រាអក្ខរកម្មអាយុពី ១៥-៤៥ ឆ្នាំ កើនឡើង ២% ជារៀងរាល់ឆ្នាំ។
- ចំនួនសិស្សក្នុងកម្មវិធីសមមូលកើនពីចំនួន ១០៥៣០ នាក់ ដល់ ១៥០០០នាក់ ជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំសិក្សា ២០០៩-២០១០ ដល់ឆ្នាំសិក្សា ២០១៣-២០១៤។
- យុវជន និងមនុស្សពេញវ័យ នៅក្នុងកម្មវិធីអក្ខរកម្ម បំណិនជីវិត កម្មវិធីរកប្រា ក់ចំណូលមានចំនួន ៦០០០០ នាក់ ជារៀងរាល់ឆ្នាំរហូតដល់ឆ្នាំសិក្សា ២០១៣-២០១៤ ។
- ចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍កើនពី ៤០ ដល់ ៩០ កន្លែង ចាប់ពីឆ្នាំសិក្សា ២០០៩-២០១០ ដល់ឆ្នាំសិក្សា ២០១៣-២០១៤ ។
- មណ្ឌលអានចំនួន ២៤ កន្លែងត្រូវបានបង្កើនឡើងជារៀងរាល់ឆ្នាំ ។
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានអប់រំក្រៅប្រព័ន្ធ ត្រូវបានដំណើរការពេញលេញនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងផ្សារភ្ជាប់ជាមួយប្រព័ន្ធទិន្នន័យគ្រប់គ្រងអប់រំ ។

## ៤- កម្មវិធី និងសកម្មភាពចម្បងៗ

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- ពង្រីកកម្មវិធីចូលរៀនឡើងវិញ និងកម្មវិធីសមមូល។ សកម្មភាពទាំងនោះរួមមាន៖
  - ក) ការគាំទ្រថវិកាប្រតិបត្តិការ ដើម្បីពង្រីកកម្មវិធីចូលរៀនឡើងវិញសម្រាប់សិស្សបោះបង់ការសិក្សា
  - ខ) អភិវឌ្ឍកម្មវិធីសមមូល កម្មវិ ធីចូលរៀនឡើងវិញ និងការធ្វើ តែសដោយផ្អែកលើស្តង់ដាអប្បបរមា និង
  - គ) ពង្រឹងការកសាងកម្មវិធីសិក្សា និងឯកសាររៀន និងបង្រៀន ។

- ការពង្រីកកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ។ សកម្មភាពទាំង នេះត្រូវផ្តោតទៅលើការពិនិត្យឡើងវិញនូវជម្រើស ដើម្បីធ្វើឲ្យការផ្តល់កម្មវិធីអក្ខរកម្មបន្ថែម និងវិជ្ជាជីវៈអាចបន្តនិរន្តរភាព ដែលយុទ្ធសាស្ត្រទាំងនោះ រួមមានការទំនាក់ទំនងជាមួយការបណ្តុះបណ្តាលជំនាញអប់រំក្រៅប្រព័ន្ធ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ហើយ សកម្មភាពទាំងនេះ ក៏ផ្តោតទៅលើ ការងារសម្របសម្រួលដល់ភាពជាដៃគូនៃរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ កម្មវិធីបង្រៀនពីរភាសាសម្រាប់ជនជាតិភាគតិច។
- ពង្រឹង និងពង្រីកមជ្ឈមណ្ឌលសិក្សាសហគមន៍ និងមណ្ឌលអាន ដើម្បីលើកបង្កើនចំណេះដឹងបន្ថែម ព្រមទាំងផ្តល់ការគាំទ្រដល់អ្នកសិក្សាដែលជាអក្ខរជនថ្មី ។
- ពង្រឹងសមត្ថភាពអប់រំក្រៅប្រព័ន្ធ ។ សកម្មភាពទាំងនេះរួមមាន៖

  ក) ការវាយតម្លៃ និងផែនការអភិវឌ្ឍសមត្ថភាពមន្ត្រី

  ខ) ពង្រឹងសមត្ថភាពថ្នាក់កណ្តាល ថ្នាក់រាជធានី -ខេត្ត និងសហគមន៍ មូលដ្ឋានដើម្បីកំណត់ចំណុចដៅ ការកសាងផែនការ និងការគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធ

  គ) ពង្រឹងប្រព័ន្ធទិន្នន័យព័ត៌មានអប់រំក្រៅប្រព័ន្ធ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការវិភាគលើតម្រូវការសិក្សា ការកំណត់ចំ ណុចដៅនៃភាពក្រីក្រ ការវាយតម្លៃប្រសិទ្ធភាពចំណាយ ការពិនិត្យតាមដាន កម្មវិធី និងការកែលម្អគំនិតផ្តួចផ្តើមក្នុងការ សម្របសម្រួលរបស់ភ្នាក់ងារមិនមែនរដ្ឋាភិបាល ។
- ពង្រឹងរចនាសម្ព័ន្ធការងារអប់រំក្រៅប្រព័ន្ធ ចាប់ពីថ្នាក់កណ្តាលដល់ថ្នាក់មូលដ្ឋាន ។
- ជួយសម្រួលដល់កម្មវិធី សម្រាប់គាំទ្រដល់ដំណើរការពិនិត្យតាមដាន រួមទាំងរបាយការណ៍ផ្អែកលើលទ្ធផលរបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ការិ យាល័យអប់រំក្រៅប្រព័ន្ធរាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ។
- ផ្តល់កម្មវិធីអប់រំយុវជនក្រៅសាលារៀនរបស់ក្រសួងអប់រំ យុវជន និងកី ឡាដូចជាកម្មវិធីមិត្តអប់រំមិត្ត កម្មវិធីបំណិនជីវិតសម្រាប់ យល់ដឹងពីមេរោគអេដស៍ ជំងឺអេដស៍ ផ្កាសាយបក្សីដោយរួមសហការជាមួយដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលនានាដែលពាក់ព័ន្ធ[១] ។
- ពង្រីកសម្មភាពផ្សព្វផ្សាយអប់រំតាមប្រព័ន្ធផ្សព្វផ្សាយរដ្ឋនិងឯកជន។

[១] មានការគាំទ្រ តាមរយៈគណៈកម្មការអន្តរនាយកដ្ឋានស្តីពីមេរោគហ៊ីវ/ជំងឺអេដស៍ (ICHA) ។

### ៤.២ កម្មវិធីមូលធន

*ការវិនិយោគ ៖*

- អភិវឌ្ឍមជ្ឈមណ្ឌលសិក្សាសហគមន៍ និងមណ្ឌលអាន។
- អង្កេតអក្ខរកម្មវិជ្ជាជីវៈមនុស្សពេញវ័យអាយុ១៥-៤៥ ឆ្នាំ។

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- ពង្រឹងសមត្ថភាពនៅថ្នាក់កណ្តាល រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងមូលដ្ឋាន ដើម្បីកំណត់ចំណុចដៅធ្វើផែនការ និងការគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធ។
- ពង្រឹងប្រព័ន្ធទិន្នន័យព័ត៌មានអប់រំក្រៅប្រព័ន្ធជាមូលដ្ឋានគ្រឹះ សម្រាប់ធ្វើផែនការវិភាគ តម្រូវការរៀនសូត្រ ការកំណត់ចំណុចដៅនៃភាពក្រីក្រ និងការវាយតម្លៃប្រសិទ្ធភាពនៃការចំណាយ ការពិនិត្យតាមដានកម្មវិធី ព្រមទាំងកែលម្អកិច្ចសម្របសម្រួលជាមួយនឹងគំនិតផ្តួចផ្តើមរបស់អង្គការមិនមែនរដ្ឋាភិបាល។
- គាំទ្រដល់ការអភិវឌ្ឍស្ថាប័ន និងយុទ្ធសាស្ត្រគ្រប់គ្រង ដើម្បីពង្រឹងរចនាសម្ព័ន្ធអប់រំក្រៅប្រព័ន្ធពីថ្នាក់កណ្តាលដល់ថ្នាក់មូលដ្ឋាន ។

## ៥. ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធទទួលខុសត្រូវរួមលើការគ្រប់គ្រងកម្មវិធី រួមមានការរៀប ចំអន្តរាគមន៍ ការកំណត់មុខសញ្ញា ការកសាងផែនការ ការធានាគុណភាព និងការពិនិត្យតាមដាន ប៉ុន្តែត្រូវមានកិច្ចសហប្រតិបត្តិការជាមួយនាយកដ្ឋានពាក់ព័ន្ធ ការិយាល័យតាមបណ្តារាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ ក្រសួងពាក់ព័ន្ធនានា សហគមន៍ និងជាមួយអង្គការមិនមែនរដ្ឋាភិបាល។ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ គឺជាអង្គភាព សម្រាប់អនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ។ នាយកដ្ឋានក៏ជាអ្នកវិភាជន៍ថវិកាប្រចាំឆ្នាំ និងជំនួយ នានាដល់រាជធានី-ខេត្ត ដើម្បីធ្វើផែនការសកម្មភាព។ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធនឹងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាព និងលទ្ធផលរបស់ខ្លួនដោយប្រើប្រាស់ទិន្នន័យប្រមូលបានពីរាជធានី-ខេត្ត។

ការរៀបចំគ្រប់គ្រងថវិកានឹងត្រូវពិនិត្យឡើងវិញ ដែលតម្រូវទៅតាមសេចក្តីត្រូវការ ឬការប្រើប្រាស់របស់រាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ។ គោលការណ៍ណែនាំត្រូវប្រើប្រាស់ឲ្យអស់លទ្ធភាពនូវភាពទន់ភ្លន់ បត់បែន និងការឆ្លើយតប ទៅនឹងតម្រូវការជាអាទិភាព ហើយត្រូវធ្វើឲ្យការផ្តល់កម្មវិធីនេះមានភាពសម្បូរបែបទៅដល់សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១. កម្មវិធីចំណាយចរន្ត** | **9721.0** | **6860.0** | **7724.4** | **8504.5** | **9471.0** |
| ១).ការពង្រីកកម្មវិធីចូលរៀនឡើងវិញនិងកម្មវិធីសមមូល | 1907.6 | 1385.9 | 1426.8 | 1570.9 | 1749.9 |
| ២).ការពង្រីកកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ (ម.ស.ស) | 5256.8 | 5184.0 | 5598.7 | 6164.2 | 6866.9 |
| ៣).លើកកម្ពស់សមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធ | 278.6 | 0 | 400 | 440.4 | 490.6 |
| ៤).ការពិនិត្យតាមដាន និងការវាយតម្លៃកម្មវិធី | 791.9 | 290.1 | 298.8 | 329.0 | 366.6 |
| **២. កម្មវិធីចំណាយមូលធន** | **0** | **100.8** | **3342.3** | **3486.0** | **3696.0** |
| ការវិនិយោគ | 0 | 0 | 1196.0 | 1196.0 | 1414.0 |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 0 | 100.8 | 2146.3 | 2290.0 | 2282.0 |
| **ធនធានសរុប** | **9721.0** | **6960.8** | **11066.7** | **11990.5** | **13167.0** |

## អនុកម្មវិធី ១.៦ ៖ ការពង្រឹង និងពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា

អង្គភាព ៖ នាយកដ្ឋានសុខភាពសិក្សា

### ១. វត្ថុបំណង

វត្ថុបំណងចម្បងនៃអនុកម្មវិធីនេះគឺ លើកកម្ពស់សុខភាពបុគ្គលិកអប់រំ និងអ្នកសិក្សា តាមរយៈការអប់រំសុខភាពអនាម័យ ការអប់រំបង្ការជំងឺឆ្លង ជំងឺមិនឆ្លង សុវត្ថិភាពចំណីអាហារ និងអាហារូបត្ថម្ភ ព្រមទាំងធ្វើឲ្យប្រសើរឡើងនូវសេវាសុខភាព និងសម្ភារបរិក្ខារអនាម័យនៅតាមគ្រឹះស្ថានសិក្សា ដោយរួមបញ្ចូលទាំងការពិនិត្យសុខភាព វិធីសាស្ត្រសង្គ្រោះបឋម ការផ្តល់ថ្នាំបង្ការ និងការចុះអន្តរាគមន៍បន្ទាន់ពេលផ្ទុះជំងឺឆ្លងនានា។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

❖ ពង្រឹងនិងពង្រីកការងារសុខភាពសិក្សា នៅតាមអង្គភាពនិងគ្រឹះស្ថានសិក្សាគ្រប់កម្រិត និងគ្រប់លំដាប់ថ្នាក់

សកម្មភាពគោលនយោបាយ ៖

- គោលការណ៍ណែនាំអនុវត្តគោលនយោបាយ ស្តីពីសុខភាពសិក្សា នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រៀបចំឲ្យបាននៅឆ្នាំ២០១១។
- ខ្លឹមសារសារាចរណែនាំ ស្តីពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចសុខភាពសិក្សានៅថ្នាក់ក្រោមជាតិ កែសម្រួលបាននៅឆ្នាំ២០១១។
- ប្រកាសអន្តរក្រសួង ស្តីពីការពិនិត្យសុខភាពដល់បុគ្គលិកអប់រំ និងអ្នកសិក្សា រៀបចំបាននៅឆ្នាំ ២០១២។
- ខ្លឹមសារអនុក្រឹត្យលេខ ២៥ អនក្រ ស្តីពីអនាម័យសិក្សា កែសម្រួលបាននៅឆ្នាំ២០១៣។

### ៣. សូចនាករ និងចំណុចដៅ ៖

- ៦០% នៃគ្រឹះស្ថានសិក្សា បានអនុវត្តកម្មវិធីបំណិនជីវិត ស្តីពីការអប់រំបង្ការជំងឺអេដស៍ និងប្រធានបទពាក់ព័ន្ធ នៅឆ្នាំសិក្សា ២០១៣-២០១៤។
- ១៥% នៃគ្រឹះស្ថានសិក្សាបានអនុវត្តកម្មវិធីអប់រំ ស្តីពីអនាម័យ សុវត្ថិភាពចំណីអាហារ និងអាហារូបត្ថម្ភក្នុង ១ ឆ្នាំ។
- ១៥% នៃគ្រឹះស្ថានសិក្សាបានអនុវត្តការអប់រំ ស្តីពីវិធីសាស្ត្រក្នុងការសង្គ្រោះបឋម និងមានសម្ភារបរិក្ខារផ្នែកសង្គ្រោះបឋមក្នុង ១ ឆ្នាំ។

- ៧០% នៃគ្រឹះស្ថានសិក្សា មានបង្គន់អនាម័យ និងទឹកស្អាត។

## ៤. សកម្មភាព និងកម្មវិធីចម្បងៗ

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- ការអភិវឌ្ឍគោលនយោបាយនិងផែនការស្តីពីសុខភាពសិក្សា នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ការអភិវឌ្ឍសម្ភារនិងឯកសារសម្រាប់សុខភាពសិក្សា
- ពិនិត្យតាមដានការអនុវត្តកម្មវិធីសុខភាពសិក្សានៅតាមសាលារៀន និងការចុះអន្តរាគមបន្ទាន់ពេលផ្ទុះជំងឺឆ្លង។
- ផ្តល់ការពិនិត្យសុខភាពដល់បុគ្គលិកអប់រំ កម្មសិក្សាការី និងអ្នកសិក្សា

៤.២ កម្មវិធីមូលធន

*កិច្ចសហប្រតិបត្តិការបច្ចេកទេស៖*

- បំប៉នសមត្ថភាពថ្នាក់ក្រោមជាតិស្តីពីសុខភាពផ្លូវភេទ សុខភាពបន្តពូជនិងសិទ្ធិបន្តពូជរបស់យុវវ័យ ជំងឺអេដស៍ កាមរោគ គ្រឿងញៀន ការយល់ដឹងអំពីអំពើហឹង្សា យេនឌ័រ និងប្រធានបទពាក់ព័ន្ធនានា។
- បំប៉នសមត្ថភាពថ្នាក់ក្រោមជាតិស្តីពីសុខភាព អនាម័យ ការអប់រំបង្ការជំងឺឆ្លង ជំងឺមិនឆ្លង និងអាហារូបត្ថម្ភនៅតាមគ្រឹះស្ថានសិក្សា។

## ៥. ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

នាយកដ្ឋានសុខភាពសិក្សាគឺជាអង្គភាពអនុវត្ត និងទទួលខុសត្រូវចំពោះការបំពេញការងារសុខភាពសិក្សា រួមទាំងការពិនិត្យតាមដាន និងវាយតម្លៃ។ ការពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីលើកកម្ពស់សុខភាពសិក្សា ត្រូវបានធ្វើឡើងទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់។ ឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីនេះ នឹងត្រូវរៀបចំឲ្យមានស្តង់ដារួមមួយសម្រាប់អនុវត្តជាទូទៅដល់គ្រប់អ្នកពាក់ព័ន្ធ។ នៅពេលមានផ្ទុះជំងឺរាតត្បាត ឬគ្រោះថ្នាក់ជាយថាហេតុនៅតាមគ្រឹះស្ថានសិក្សា ការចុះអន្តរាគមន៍ ត្រូវបានធ្វើឡើងជាបន្ទាន់ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១. កម្មវិធីចរន្ត** | **3610** | **9760** | **15200** | **15200** | **15600** |
| ១.១. ពង្រឹងបរិយាកាសគោលនយោបាយស្តីពីសុខភាព សិក្សា | 650 | 520 | 600 | 600 | 600 |
| ១.២. បង្កើនការយល់ដឹងពីសុខភាព អនាម័យ ការអប់រំបង្ការជំងឺ ឆ្លង ជំងឺមិនឆ្លង សុវត្ថិភាពចំណីអាហារ និងអាហារូបត្ថម្ភតាមគ្រឹះស្ថានសិក្សា។ | 300 | 1200 | 900 | 900 | 900 |
| ១.៣. បង្កើនការយល់ដឹងពីសុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធិបន្តពូជរបស់យុវវ័យ ដោយរួមបញ្ចូលទាំងការអប់រំ ស្តីពីជំងឺអេដស៍ កាមរោគ គ្រឿងញៀន និងប្រធានបទពាក់ព័ន្ធ។ | 2500 | 2240 | 7200 | 7200 | 7600 |
| ១.៤. ធ្វើឲ្យប្រសើរឡើងនូវសេវាសុខភាព និងសម្ភាររូបវ័ន្តនៅតាម សាលារៀន | 160 | 5800 | 6500 | 6500 | 6500 |
| **២. កម្មវិធីមូលធន** | **192** | **192** | **990** | **2170** | **2170** |
| ការវិនិយោគ | 0 | 0 | 0 | 1180 | 1180 |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 192 | 192 | 990 | 990 | 990 |
| **ធនធានសរុប** | **3802** | **9952** | **16190** | **17370** | **17770** |

## អនុកម្មវិធី ១.៧ ៖ ការងារតម្រង់ទិសវិជ្ជាជីវៈ

អង្គភាព ៖ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ

### ១ វត្ថុបំណង

អនុកម្មវិធីនេះមានវត្ថុបំណង ផ្តល់សេវាអប់រំបច្ចេកទេសវិជ្ជាជីវៈរយៈពេលខ្លីនិងមធ្យម ពង្រីកការងារតម្រង់ទិសវិជ្ជាជីវៈ ពង្រឹងការអនុវត្តកម្មវិធីអប់រំបំណិនជីវិត និងកម្មវិធីអប់រំវិជ្ជាជីវៈជម្រើស ប្រកបដោយគុណភាពនិងប្រសិទ្ធភាព នៅតាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ។ ដោយធានាថាសិស្សានុសិស្សនឹងទទួលបានការតម្រង់ទិសវិជ្ជាជីវៈ ចំណេះដឹង និងជំនាញមូលដ្ឋាន ដើម្បីបម្រើការងារក្នុងទីផ្សារពលកម្ម ឬក៏អាចបន្តការសិក្សាទៅថ្នាក់ក្រោយមធ្យមសិក្សា។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌*

❖ ផ្តល់សេវាអប់រំវិជ្ជាជីវៈ ការអប់រំបំណិនជីវិត និងតម្រង់ទិសវិជ្ជាជីវៈនៅតាមសាលាចំណេះទូទៅ។

សកម្មភាពគោលនយោបាយ៖

- គោលនយោបាយតម្រង់ទិសវិជ្ជាជីវៈ សម្រាប់សាលាមធ្យមសិក្សា កសាងបាននៅឆ្នាំ២០១១។
- សេចក្តីណែនាំស្តីពីការអនុវត្តមុខវិជ្ជាបន្ថែមនៃការអប់រំបច្ចេកទេសវិជ្ជាជីវៈ និងមុខវិជ្ជាជីវៈជម្រើសនៅតាមបណ្តាវិទ្យាល័យនានា រៀបចំបាននៅឆ្នាំ២០១១។
- ផែនការអភិវឌ្ឍសេវាអប់រំបច្ចេកទេសវិជ្ជាជីវៈ កសាងបាននៅឆ្នាំ ២០១១។
- លិខិតបទដ្ឋាន និង លក្ខណវិនិច្ឆ័យសម្រាប់ពង្រីកវិទ្យាល័យឲ្យទៅជាវិទ្យាល័យអប់រំវិជ្ជាជីវៈ រៀបចំបាននៅឆ្នាំ ២០១២។
- សេចក្តីណែនាំស្តីពី ការអនុវត្តការងារតម្រង់ទិសវិជ្ជាជីវៈ រៀបចំបាននៅឆ្នាំ២០១២។
- សេចក្តីណែនាំស្តីពី ការអនុវត្តមុខវិជ្ជាជំនាញនៅតាមវិទ្យាល័យនានាដោយផ្តើមជាបឋមលើកម្មវិធីសិក្សា ICT រៀបចំបាន និងចាប់ដំណើរការជាបណ្តើរៗពីឆ្នាំ ២០១១ តទៅ។
- គោលនយោបាយបំណិនជីវិត កែលម្អបាននៅឆ្នាំ ២០១១។

*គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

❖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវា អប់រំបច្ចេកទេសវិជ្ជាជីវៈ ការអប់រំបំណិនជីវិត និងការតម្រង់ទិសវិជ្ជាជីវៈ។

សកម្មភាពគោលនយោបាយ៖

- សេចក្តីណែនាំបន្ថែមស្តីពី ការអនុវត្តកម្មវិធីបំណិនជីវិត រៀបចំបាននៅឆ្នាំ២០១១។

- ក្របខណ្ឌធានាគុណភាពសេវាអប់រំវិជ្ជាជីវៈ រៀបចំបាននៅឆ្នាំ២០១២។
- ផែនការអភិវឌ្ឍសម្ភាររូបវន្តនិងបណ្តុះបណ្តាលធនធានមនុស្សជំនាញ លើការងារបណ្តុះបណ្តាលអប់រំបច្ចេកទេសវិជ្ជាជីវៈ កសាងបាននៅឆ្នាំ ២០១០។
- និតិវិធីថវិកាទ្រទ្រង់ដល់ដំណើរការកម្មវិធីជ្រើសរើសការអប់រំបច្ចេកទេសវិជ្ជាជីវៈ រៀបចំ បាននៅឆ្នាំ ២០១០។

*គោលនយោបាយទី៣ ៖ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

❖ អភិវឌ្ឍរចនាសម្ព័ន្ធគ្រប់គ្រងការងារអប់រំវិជ្ជាជីវៈ និងកសាងសមត្ថភាពមន្ត្រីជំនាញការងារអប់រំវិជ្ជាជីវៈនៅគ្រប់លំដាប់ថ្នាក់ ។

សកម្មភាពគោលនយោបាយ៖

- លិខិតបទដ្ឋានស្តីពីតួនាទី និងភារកិច្ចការងារគ្រប់គ្រងការងារតម្រង់ទិសវិជ្ជាជីវៈ រៀបចំបាននៅឆ្នាំ ២០១១ ។
- ផែនការអភិវឌ្ឍសមត្ថភាពមន្ត្រីតម្រង់ទិសវិជ្ជាជីវៈកសាងបាននៅឆ្នាំ ២០១២។

## ៣ សូចនាករ និង ចំណុចដៅ

- ៥% នៃវិទ្យាល័យនៅតាមទីប្រជុំជន និងជនបទ អនុវត្តកម្មវិធីអប់រំបច្ចេកទេស ឬវិជ្ជាជីវៈជម្រើស ចាប់ពីឆ្នាំសិក្សា ២០១១-២០១២។
- សាលាមធ្យមសិក្សាចំនួន ៥ នឹងត្រូវពង្រីកឲ្យទៅជាវិទ្យាល័យអប់រំវិជ្ជាជីវៈ នៅឆ្នាំសិក្សា ២០១៣-២០១៤។
- ចំនួនសិស្សបានទទួលសេវាអប់រំបច្ចេកទេសវិជ្ជាជីវៈ ២០០០ នាក់ នៅឆ្នាំសិក្សា ២០១២-២០១៣។
- ២០% នៃសាលារៀនចំណេះទូទៅបានអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមគោលការណ៍ដែលបានកំណត់ នៅឆ្នាំសិក្សា ២០១២-២០១៣។

## ៤ កម្មវិធី និងសកម្មភាពចម្បងៗ

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- សិក្សា ប្រមូល និងចងក្រងព័ត៌មានដើម្បីរៀបចំគោលនយោបាយតម្រង់ទិសវិជ្ជាជីវៈ។
- ពិគ្រោះយោបល់ អំពីគោលនយោបាយផែនការយុទ្ធសាស្ត្រអប់រំវិជ្ជាជីវៈ នៅតាមរាជធានី ខេត្ត។
- អភិវឌ្ឍ និងរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងតាមបែបវិសហមជ្ឈការការងារអប់រំបច្ចេកទេសវិជ្ជាជីវៈ។

- បំប៉នសមត្ថភាពដល់មន្ត្រីអប់រំវិជ្ជាជីវៈ រួមមានថ្នាក់មន្ទីរ ថ្នាក់ស្រុក នាយកសាលាចំណេះទូទៅ និងគ្រូបង្រៀនមុខវិជ្ជា បំណិនជីវិត ។
- កសាងឯកសារស្តីពីក្របខណ្ឌធានាគុណភាពសេវាអប់រំបច្ចេកទេសវិជ្ជាជីវៈ ។
- សិក្សា ចងក្រង ផ្សព្វផ្សាយសៀវភៅមគ្គុទ្ទេសការតម្រង់ទិសវិជ្ជាជីវៈ និងការផ្តល់ប្រឹក្សាដល់សិស្សានុសិស្សនៅតាមវិទ្យាល័យនានាលើការងារតម្រង់ទិសវិជ្ជាជីវៈ ។
- ផ្តល់ថវិកាទ្រទ្រង់ដល់ដំណើរការប្រតិបត្តិការសេវាអប់រំវិជ្ជាជីវៈ នៅតាមសាលារៀនមធ្យមសិក្សា ។
- ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីអប់រំបំណិនជីវិត ការអប់រំបច្ចេកទេសវិជ្ជាជីវៈ និងដំណើរការប្រតិបត្តិការងារតម្រង់ទិសទៅរកមុខជំនាញវិជ្ជាជីវៈ ។

៤.២ កម្មវិធីមូលធន

*ការវិនិយោគ ៖*

- ផ្តល់សម្ភាររូបវន្ត និងសម្ភារបរិក្ខារ ដើម្បីប្រែក្លាយពីវិទ្យាល័យចំណេះទូទៅជាវិទ្យាល័យចំណេះទូទៅ និងវិជ្ជាជីវៈ។

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- ធ្វើទស្សនកិច្ចសិក្សា និងសិក្សាបទពិសោធន៍នានាស្តីពីការងារតម្រង់ទិសវិជ្ជាជីវៈពីបណ្តាប្រទេសក្នុងតំបន់ និងប្រទេសអភិវឌ្ឍ។
- រៀបចំថ្នាក់រៀន និងបំពាក់សម្ភារបរិក្ខាសម្រាប់ដំណើរការអនុវត្តកម្មវិធីអប់រំវិជ្ជាជីវៈ ឬ មុខវិជ្ជាវិជ្ជាជីវៈជម្រើសដល់បណ្តាវិទ្យាល័យនៅតាមទីប្រជុំជន និងជនបទ ។
- បំប៉នសមត្ថភាពដល់មន្ត្រីតម្រង់ទិសវិជ្ជាជីវៈ នាយកសាលាចំណេះទូទៅ គ្រូបង្រៀនមុខវិជ្ជាវិជ្ជាជីវៈ អំពីការងារគ្រប់គ្រងការតម្រង់ទិសវិជ្ជាជីវៈ។
- រៀបចំការតាំងពិពណ៌ការងារអប់រំវិជ្ជាជីវៈ ដើម្បីទាក់ទាញចំណាប់អារម្មណ៍សិស្សនៅតាមសាលាមធ្យមសិក្សាចំណេះទូទៅ និងសហគមន៍។

## ៥ ការគ្រប់គ្រងកម្មវិធី និងការពិនិត្យតាមដាន

ការអនុវត្តកម្មវិធីអប់រំវិជ្ជាជីវៈ និងការងារតម្រង់ទិសវិជ្ជាជីវៈ នឹងធ្វើសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធដទៃទៀតដូចជា៖ នាយកដ្ឋានផ្សេងៗ មន្ត្រីថ្នាក់ក្រោមជាតិ ក្រសួងពាក់ព័ន្ធ សហគមន៍ អង្គការជាតិ និងអន្តរជាតិ និងដៃគូអភិវឌ្ឍនានា។

រចនាសម្ព័ន្ធគ្រប់គ្រងកម្មវិធីនឹងត្រូវរៀបចំបង្កើតឡើងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដើម្បី

គ្រប់គ្រងព័ត៌មាន និងថវិកា។ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នឹងធ្វើរបាយការណ៍វឌ្ឍនភាព និងផលប៉ះពាល់របស់កម្មវិធី តាមរយៈរបាយការណ៍ពីថ្នាក់ក្រោមជាតិ។

## ៦ ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១- កម្មវិធីចរន្ត** | **0** | **0** | **2100** | **2450** | **2700** |
| ថវិកាទ្រទ្រង់ | 0 | 0 | 50 | 250 | 350 |
| អភិវឌ្ឍសមត្ថភាព | 0 | 0 | 1800 | 1900 | 2000 |
| ពិនិត្យតាមដាន | 0 | 0 | 250 | 300 | 350 |
| **២- កម្មវិធីមូលធន** | **0** | **0** | **8206.2** | **9854.1** | **10840.6** |
| ការវិនិយោគ | 0 | 0 | 6652.2 | 7702.9 | 8689.4 |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 0 | 0 | 1554.0 | 2151.2 | 2151.2 |
| **ធនធានសរុប** | **0** | **0** | **10306.2** | **12304.1** | **13540.6** |

## ៥.២ កម្មវិធីទី ២ ៖ ការអភិវឌ្ឍការអប់រំ បណ្តុះបណ្តាលបច្ចេកទេសឧត្តមសិក្សា និង ស្រាវជ្រាវវិទ្យាសាស្ត្រ

### អនុកម្មវិធី ២.១ ៖ ការពង្រឹងគុណភាព និង ប្រសិទ្ធភាពនៃការអប់រំនៅឧត្តមសិក្សា

អង្គភាព៖ នាយកដ្ឋានឧត្តមសិក្សា

### ១. វត្ថុបំណង

អនុកម្មវិធីនេះមានវត្ថុបំណង បន្តពង្រីកការចូលរៀននៅកម្រិតក្រោយមធ្យមសិក្សា និង ធានាឱ្យបាននូវការអភិវឌ្ឍធនធានបញ្ញា និងការផ្តល់ធនធានមនុស្សប្រកបដោយគុណភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និង ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជា។ សមធម៌នៃការចូលរៀនត្រូវបានពង្រីក តាមរយៈកម្មវិធីអាហារូបករណ៍សម្រាប់សិស្សអាទិភាព (សិស្សពូកែ សិស្សក្រីក្រ សិស្សមកពីតំបន់ដាច់ស្រយាល និងសិស្សនារី )។ អាទិភាពមួយចំនួន នឹងត្រូវបានផ្តល់ដល់សិស្សដែលចុះឈ្មោះសម្រាប់ជំនាញដែលពាក់ព័ន្ធតិចតួចទៅនឹងទីផ្សារ តែមានប្រយោជន៍ច្រើនចំពោះសង្គមជាពិសេសផ្នែកអប់រំ សុខាភិបាល កសិកម្ម បច្ចេកវិទ្យា វិស្វកម្ម វិទ្យាសាស្ត្រនិងគណិតសាស្ត្រ ។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌*

❖ បង្កើនកាលានុវត្តភាពនៃការចូលរៀនប្រកបដោយសមធម៌នៅឧត្តមសិក្សា តាមរយៈការបង្កើនចំនួនអាហារូបករណ៍សម្រាប់សិស្សអាទិភាព (សិស្សពូកែ សិស្សក្រីក្រ សិស្សមកពីតំបន់ដាច់ស្រយាល និងសិស្សនារី) និងការជំរុញឲ្យមានភាពជាដៃគូរវាងសាធារណៈ ឯកជន និងដៃគូអភិវឌ្ឍ។

សកម្មភាពគោលនយោបាយ ៖

- កសាងរបាយការណ៍ចំណាយប្រចាំឆ្នាំអំពីចំនួននិស្សិតអាហារូបករណ៍ ចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ចាប់ពីឆ្នាំ២០១០ តទៅ ។
- កសាងផែនការសម្រាប់ពង្រីកគ្រឹះស្ថានឧត្តមសិក្សាជាជំហានៗ និង សម្រាប់កម្មវិធីជំនាញអាទិភាព ដូចជាផ្នែកអប់រំ សិល្បៈ មនុស្សសាស្ត្រ សុខាភិបាល កសិកម្ម វិស្វកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និង គណិតសាស្ត្រ នៅឆ្នាំ ២០១១ ។
- រៀបចំគោលការណ៍រវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពង្រីកកម្មវិធីអាហារូបករណ៍នៅឧត្តមសិក្សាចាប់ពី ១៥% ឡើងទៅនៃចំនួនសិស្ស ប្រឡងជាប់មធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំនីមួយៗ ចាប់ពីឆ្នាំ ២០១១។ គោលការណ៍នេះ នឹងបញ្ចូលនូវប្រាក់អាហារូបករណ៍ សម្រាប់គាំទ្រជីវភាពសិក្សារបស់និស្សិតអាហារូបករណ៍ ។

- កសាងគោលនយោបាយអភិវឌ្ឍមូលដ្ឋានសម្ភាររូបវន្តនៅឧត្តមសិក្សា រួមបញ្ចូលទាំង ហេដ្ឋារចនាសម្ព័ន្ធ និងអន្តេវាសិកដ្ឋាន ចាប់ពីឆ្នាំ ២០១២។

### *គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

❖ កែលម្អគុណភាពនៃការបង្រៀន ការរៀន និងការស្រាវជ្រាវនៅឧត្តមសិក្សា តាមរយៈការអនុវត្តវិធីសាស្រ្តបង្រៀនបច្ចុប្បន្នភាព ការអភិវឌ្ឍកម្មវិធីសិក្សា និងការបំពាក់មូលដ្ឋានសម្ភាររូបវន្ត ។

សកម្មភាពគោលនយោបាយ ៖

- កសាងក្របខណ្ឌអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ឧត្តមសិក្សា ដោយពិចារណាលើសមត្ថភាពនៃគ្រូបង្រៀននៅឧត្តមសិក្សា ទីផ្សារការងារ និង តម្រូវការរបស់ជាតិ នៅឆ្នាំ២០១២។
- អភិវឌ្ឍក្របខណ្ឌគុណវុឌ្ឍិសម្រាប់ឧត្តមសិក្សា នៅឆ្នាំ ២០១២។

### *គោលនយោបាយទី៣៖ អភិវឌ្ឍស្ថាប័ន និង អភិវឌ្ឍសមត្ថភាពមន្រ្តីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

❖ អភិវឌ្ឍសមត្ថភាពមន្រ្តី និង កែ លម្អការគ្រប់គ្រងស្ថាប័នឧត្តមសិក្សា តាមរយៈការបណ្តុះបណ្តាល ការលើកទឹកចិត្ត ការកែទម្រង់ស្ថាប័ ន និងការគ្រប់គ្រងហិរញ្ញវត្ថុដែលផ្តល់ស្វ័យភាពប្រតិបត្តិ កាន់តែច្រើនដល់គ្រឹះស្ថានឧត្តមសិក្សា។

សកម្មភាពគោលនយោបាយ ៖

- កសាងគោលនយោបាយនិងចក្ខុវិស័យអភិវឌ្ឍឧត្តមសិក្សាក្នុងឆ្នាំ២០២០ បញ្ចប់នៅឆ្នាំ ២០១០។
- កសាងគោលការណ៍ ឧបករណ៍ និងយន្តការពិនិត្យតាមដាននិងវាយតម្លៃ សមិទ្ធកម្មនៃការបំពេញការងាររបស់គ្រឹះស្ថានឧត្តមសិក្សា នៅឆ្នាំ២០១០។
- កសាងបទដ្ឋានសម្រាប់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីពិនិត្យឡើងវិញលើរចនាសម្ព័ន្ធការគ្រប់គ្រងបច្ចុប្បន្ននៅតាមគ្រឹះស្ថានឧត្តមសិក្សា ឲ្យស្របតាមច្បាប់ស្តីពីការអប់រំ នៅឆ្នាំ ២០១១។
- កសាងផែនការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាល និងគ្រូបង្រៀននៅឧត្តមសិក្សា ឆ្នាំ ២០១១។
- កសាងគោលការណ៍ណែនាំ សម្រាប់ការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សា ដោយផ្សារភ្ជាប់នឹងប្រព័ន្ធ HEMIS នៅឆ្នាំ២០១១។
- កសាងគោលការណ៍សម្រាប់អភិបាលកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុ នៃគ្រឹះស្ថានឧត្តមសិក្សា នៅឆ្នាំ២០១២ ។
- រៀបចំឲ្យមានសាកលវិទ្យាល័យពេញលេញចំនួន ២ នៅឆ្នាំ២០១៣ ។

## ៣. សូចនាករ និងចំណុចដៅ

- ចំនួននិស្សិតចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សាកើនពី ១៣៧០០០ នាក់ នៅឆ្នាំសិក្សា ២០០៨-២០០៩ ទៅដល់ ១៩៥៦១៧ នាក់ ក្នុងនោះ ៤០% ជានិស្សិតស្រី នៅឆ្នាំ ២០១៣-២០១៤ ។
- ចំនួននិស្សិតចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ កើនពី ៤៦៣៩៥ នាក់ នៅឆ្នាំសិក្សា ២០០៨-២០០៩ ទៅដល់ ៨៤០៣៥ នាក់នៅឆ្នាំសិក្សា ២០១៣-២០១៤។
- ចំនួននិស្សិតចូលរៀនផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងគណិត វិទ្យានៅគ្រឹះស្ថានឧត្តមសិក្សាមានចំនួន ២៥% ចាប់ពីឆ្នាំសិក្សា ២០០៨-២០០៩ ដល់ឆ្នាំសិក្សា ២០១៣-២០១៤។ ។
- ស្ថានភាពនៃបុគ្គលិកគ្រឹះស្ថានឧត្តមសិក្សាត្រូវបានកែលម្អរៀងរាល់ឆ្នាំ ដោយការបន្ថែមបុគ្គលិកដែលត្រឡប់មកពីការសិក្សានៅបរទេស ។ ធ្វើរបាយការណ៍ពីចំនួន អ្នកមានសញ្ញាបត្របរិញ្ញាជាន់ខ្ពស់ និងបណ្ឌិត ដែលមានគុណភាពពិតប្រាកដ ។
- ប្រព័ន្ធព័ត៌មានគ្រប់គ្រងឧត្តមសិក្សានឹងចាប់ដំណើរការពីឆ្នាំសិក្សា ២០១១-២០១២ ។
- សាកលវិទ្យាល័យពេញលេញចំនួន ០២ ចាប់ដំណើរការនៅឆ្នាំសិក្សា ២០១៣-២០១៤។

## ៤. កម្មវិធី និងសកម្មភាពចម្បងៗ

### ៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- ផ្តល់ថវិកាសម្រាប់ដំណើរការ និងសកម្មភាពស្រាវជ្រាវដល់គ្រឹះស្ថានឧត្តមសិក្សា ក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ថវិកាទាំងនេះត្រូវផ្អែកលើចំនួននិស្សិតអាហារូបករណ៍ និងតម្លៃសិក្សានៃនិស្សិតម្នាក់តាមកម្មវិធីនីមួយៗ។
- ពិនិត្យតាមដាននិងវាយតម្លៃលើការគ្រប់គ្រងការងារបណ្តុះបណ្តាល និងពង្រឹងគុណភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សា។
- ផ្តល់ថវិកាពង្រឹងប្រព័ន្ធចុះឈ្មោះចូលរៀន ប្រព័ន្ធព័ត៌មានគ្រប់គ្រង និងការស្រាវជ្រាវ។
- បន្តប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលកំពុងដំណើរការឲ្យទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។

### ៤.២ កម្មវិធីមូលធន

*ការវិនិយោគ ៖*

- ផ្តល់មូលដ្ឋានសម្ភារៈសម្រាប់ការបង្រៀននិងការរៀនសំដៅពង្រីកកម្មវិធីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងគណិតវិទ្យានៅគ្រឹះស្ថានឧត្តមសិក្សា។
- អភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងឧត្តមសិក្សា ដោយរួមបញ្ចូលទាំងកម្មវិធីកុំព្យូទ័រហិរញ្ញវត្ថុ។

- កសាងអន្តេវាសិកដ្ឋាន សម្រាប់និស្សិតមកពីខេត្ត ពិសេសសម្រាប់និស្សិតនារី ។

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- សិក្សាស្រាវជ្រាវអំពីការងារ នៃនិស្សិតបញ្ចប់ការសិក្សា។
- សិក្សានិងវាយតម្លៃអំពីលទ្ធភាពបង្កើតសាកលវិទ្យាល័យពេញលេញកម្រិតខ្ពស់ឲ្យស្របតាមបរិបទឧត្តមសិក្សាកម្ពុជា តាមរយៈការ រៀបចំឯកសារទស្សនទាន និងការសិក្សាអំពីសាកលវិទ្យាល័យក្នុងតំបន់និងអន្តរជាតិ។
- អភិវឌ្ឍសមត្ថភាពបុគ្គលិក និងពង្រីកកម្មវិធីនានា ដើម្បីឈានទៅសាកល្បងអនុវត្ត សាកលវិទ្យាល័យចំនួន ០២។
- សិក្សាលទ្ធភាពក្នុងការអនុវត្តប្រព័ន្ធឥណទានកម្ចី (credit loan scheme) ក្នុងសហប្រតិបត្តិការជាមួយភ្នាក់ងារឥណទានក្នុងស្រុក ។
- ផ្តល់កញ្ចប់ថវិកា (block grant) ទៅតាមចំនួននិស្សិតអាហារូបករណ៍រដ្ឋ ជាពិសេសនិស្សិតអាទិភាព (និស្សិតស្រី និស្សិតក្រីក្រ និងនិស្សិតមកពីតំបន់ជួបការលំបាក ) ដល់គ្រឹះស្ថានឧត្តមសិក្សា ដោយផ្តោតលើកម្មវិធីសិក្សាមានប្រយោជន៍ ចំពោះសង្គម ជាពិសេសផ្នែកអប់រំ សុខាភិបាល កសិកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និង គណិតសាស្ត្រ ដែលត្រូវអនុវត្តចាប់ពីឆ្នាំ២០១១។
- អភិវឌ្ឍសមត្ថភាពគ្រូបង្រៀននៅឧត្តមសិក្សា ដោយការផ្តល់អាហារូបករណ៍ទៅសិក្សានៅក្នុងប្រទេស និងនៅបរទេស និង សកម្មភាពស្រាវជ្រាវ ។
- ផ្តល់ជំនួយការបច្ចេកទេសសម្រាប់ការដំណើរការអភិវឌ្ឍវិស័យឧត្តមសិក្សា។
- បញ្ជូននិស្សិតទៅសិក្សានៅបរទេសស្ថិតក្រោមកម្មវិធីសហប្រតិបត្តិការពហុភាគី និងទ្វេភាគី។

## ៥. ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

ថវិកាសម្រាប់ការគាំទ្រ និងដំណើរការគ្រឹះស្ថានសិក្សាត្រូវគ្រប់គ្រងផ្ទាល់ដោយគ្រឹះស្ថានឧត្តមសិក្សា។ នាយកដ្ឋានឧត្តមសិក្សានឹងទទួលខុស ត្រូវលើការពង្រឹងគុណភាពអប់រំ និងការពិនិត្យតាមដាន ។

នាយកដ្ឋានឧត្តមសិក្សា នឹងទទួលខុសត្រូវលើការរៀបចំផែនការយុទ្ធសាស្ត្រផ្នែកឧត្តមសិក្សាក្របខណ្ឌនៃការធ្វើផែនការប្រចាំឆ្នាំ ដោយរាប់បញ្ចូលអាទិភាពចំណាយសម្រាប់អាហារូបករណ៍ និងការបែងចែកថវិកាទៅដល់គ្រឹះស្ថានឧត្តមសិក្សានីមួយៗ។ គ្រឹះស្ថានឧត្តមសិក្សានីមួយៗត្រូវរៀបចំផែនការការងារប្រចាំឆ្នាំ ដោយរាប់បញ្ចូលការកែលម្អចំណុចខ្សោយ ផែនការសកម្មភាព និងគម្រោងថវិកា។

នាយកដ្ឋានឧត្តមសិក្សា នឹងធ្វើការពិនិត្យតាមដានផលប៉ះពាល់ វឌ្ឍនភាព ការងារលទ្ធផលសិក្សារបស់និស្សិត ប្រសិទ្ធភាពនៃការបំពេញការងារ របស់គ្រឹះស្ថានឧត្តមសិក្សា និងបញ្ហាផ្សេងទៀត។ របាយការណ៍ពិនិត្យតាមដានត្រូវដាក់ជូនទៅថ្នាក់ដឹកនាំក្រសួងទទួលបន្ទុកឧត្តមសិក្សា។ របាយការណ៍ប្រចាំឆ្នាំត្រូវរួមបញ្ចូលវិធានការសម្រាប់ការបំពេញការងារ ដែលត្រូវបានស្នើដោយគ្រឹះស្ថានឧត្តមសិក្សា សម្រាប់ការកែលម្អនៅក្នុងផែនការការងាររបស់ខ្លួន។

ក្រសួងអប់រំ យុវជន និងកីឡានឹងបន្តអនុវត្តគោលនយោបាយវិមជ្ឈការក្នុងការគ្រប់គ្រងផ្នែកឧត្តមសិក្សា តាមរយៈការជំ រុញគ្រឹះស្ថានឧត្តមសិក្សានីមួយៗ ឱ្យបង្កើតប្រព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងរបស់ខ្លួនប្រកបដោយតម្លាភាព និងគណនេយ្យភាព។ លក្ខណៈពិសេសដែលរំពឹងទុក គឺការបង្កើតក្រុមប្រឹក្សាភិបាល ដែលមានសមត្ថភាព ការបោះផ្សាយឯកសារហិរញ្ញវត្ថុ លទ្ធផលសិក្សា និងការពណ៌នាភារកិច្ចសម្រាប់បុគ្គលិកម្នាក់ៗ ក្នុងការគ្រប់គ្រង ។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១. កម្មវិធីចរិកាចរន្ត** | **3249.0** | **3493.0** | **15121.9** | **27310.0** | **40568.0** |
| កម្មវិធីអាហារូបករណ៍សម្រាប់គ្រឹះស្ថានឧត្តមសិក្សា | 2895.0 | 3163.0 | 13610.0 | 24579.0 | 36544.0 |
| កម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ការចុះឈ្មោះចូលរៀន | 88.5 | 75.9 | 347.7 | 628.1 | 933.8 |
| ការបោះពុម្ពសៀវភៅ | 9.2 | 20.5 | 105.8 | 191.2 | 248.2 |
| ការពិនិត្យតាមដាននិងវាយតម្លៃនិងពង្រឹងគុណភាព | 256.3 | 233.6 | 1058.4 | 1911.7 | 2842 |
| **២. កម្មវិធីមូលធន** | **0** | **1207.8** | **6630.0** | **6332.5** | **6332.5** |
| ការវិនិយោគ | 0 | 0 | 297.5 | 0 | 0 |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 0 | 1207.8 | 6332.5 | 6332.5 | 6332.5 |
| **ធនធានសរុប** | **3249.0** | **4700.8** | **21751.9** | **33642.5** | **46900.5** |

## អនុកម្មវិធី ២.២ ៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងបណ្ឌិត

អង្គភាព៖ **នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ**

### ១. វត្ថុបំណង

អនុវិស័យនេះមានវត្ថុបំណង អភិវឌ្ឍធនធានមនុស្សថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ថ្នាក់បណ្ឌិត និងការស្រាវជ្រាវប្រកបដោយគុណភាព និងប្រសិទ្ធភាពឲ្យឆ្លើយតបទៅនឹងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយនិងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌*

❖ បង្កើនកាលានុវត្តភាពនៃការចូលរៀនប្រកបដោយសមធម៌នៅឧត្តមសិក្សា ។

សកម្មភាពគោលនយោបាយ ៖

- ផែនការបណ្តុះបណ្តាលធនធានមនុស្សថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត កសាងបាននៅឆ្នាំ ២០១២។

*គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

❖ កែលម្អគុណភាពនៃការបង្រៀន ការរៀន និងការស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត តាមរយៈការអនុវត្តវិធីសាស្ត្របង្រៀនទំនើប និងការអភិវឌ្ឍកម្មវិធីសិក្សា ព្រមទាំងការបំពាក់សម្ភាររូបវន្ត ឲ្យឆ្លើយតបទៅនឹងតម្រូវការនៃការបង្រៀន រៀន និងការស្រាវជ្រាវ។

សកម្មភាពគោលនយោបាយ ៖

- គោលនយោបាយអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ កសាងបាននៅឆ្នាំ ២០១០ ។
- ក្របខណ្ឌដើម្បីកំណត់លំដាប់ស័ក្តិ ឋានៈ និងមុខងារ នៃគ្រូបង្រៀននៅឧត្តមសិក្សា រៀបចំបាននៅឆ្នាំ ២០១១ ។

❖ បង្កើនតម្លាភាពកែលម្អការពិនិត្យតាមដានការបំពេញការងារ ការទទួលខុសត្រូវរបស់គ្រូបង្រៀន និងគ្រឹះស្ថានឧត្តមសិក្សា។

សកម្មភាពគោលនយោបាយ ៖

- គោលការណ៍ស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ កែលម្អបាននៅឆ្នាំ ២០១០។
- គោលការណ៍ស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត រៀបចំបាននៅឆ្នាំ ២០១១។

### *គោលនយោបាយទី ៣ ៖ អភិវឌ្ឍស្ថាប័ន និង អភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

❖ ពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងបុគ្គលិក ប្រព័ន្ធ ព័ត៌មានគ្រប់គ្រងអប់រំ ប្រព័ន្ធព័ត៌មានគ្រប់គ្រងឧត្តមសិក្សា ប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ។

សកម្មភាពគោលនយោបាយ ៖

- ប្រព័ន្ធព័ត៌មានគ្រប់គ្រងការស្រាវជ្រាវក្នុងវិស័យអប់រំ កសាងបាននៅឆ្នាំ ២០១១ ។

## ៣. សូចនាករ និងចំណុចដៅ

- និស្សិតស្រាវជ្រាវពី ១០% ទៅ ១៥% មានឯកទេសផ្នែកវិទ្យាសាស្ត្រ នៅឆ្នាំសិក្សា ២០១៣-២០១៤។
- ប្រព័ន្ធព័ត៌មានគ្រប់គ្រងការស្រាវជ្រាវក្នុងវិស័យអប់រំ មាននៅឆ្នាំសិក្សា ២០១២-២០១៣។
- ជំនាញឯកទេសដែលមិនទាន់មានការបណ្តុះបណ្តាលនៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នឹងមានការបណ្តុះបណ្តាល និងជំនាញឯកទេសដែលមានការបណ្តុះបណ្តាលតិចតួចនឹងកើនឡើងពី ២០% ទៅ ៣០% នៅឆ្នាំសិក្សា ២០១៣-២០១៤។
- ទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រកម្ពុជានឹងត្រូវបានបោះពុម្ពផ្សាយក្នុងមួយឆ្នាំ ពីរលេខ ចាប់ពីឆ្នាំសិក្សា ២០១១-២០១២។

## ៤. កម្មវិធី និងសកម្មភាពចម្បងៗ

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- សកម្មភាពអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ ដូចជាការរៀបចំទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ ការពិគ្រោះយោបល់ និងការផ្លាស់ប្តូរបទពិសោធន៍។
- សកម្មភាពត្រួតពិនិត្យតាមដានគុណភាព និងប្រសិទ្ធភាពការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងថ្នាក់បណ្ឌិត ដូចជាការប្រឡងជ្រើសរើសឲ្យចូលរៀន ការប្រឡងបញ្ចប់ និងការការពារនិក្ខេបបទ ។

៤.២ កម្មវិធីមូលធន

*ការវិនិយោគ ៖*

- រៀបចំប្រព័ន្ធព័ត៌មានគ្រប់គ្រងការស្រាវជ្រាវក្នុងវិស័យអប់រំ ដើម្បីគ្រប់គ្រងស្ថិតិនិស្សិតសាស្ត្រាចារ្យ និងព័ត៌មានស្តីពីការបណ្តុះបណ្តាល ថ្នាក់បរិញ្ញាបត្រ ជាន់ខ្ពស់ និងបណ្ឌិត។

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- កសាងសមត្ថភាពមន្ត្រីអំពីការអភិវឌ្ឍនិងការស្រាវជ្រាវ។
- ជំនួយការបច្ចេកទេសស្តីពី ការអភិវឌ្ឍនិងការស្រាវជ្រាវ

## ៥. ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ នឹងធ្វើការពិនិត្យតាមដានផលប៉ះពាល់ និងវឌ្ឍនភាពដែលផ្តោតលើវត្តមាន និងសមិទ្ធកម្មសិក្សារបស់និស្សិត និងបញ្ហាផ្សេងទៀតទាក់ទង ព្រមទាំង ធ្វើការពិនិត្យតាមដានផ្នែកបច្ចេកទេសរបស់គ្រឹះស្ថានឧត្តមសិក្សា និងប្រសិទ្ធភាពនៃការបំពេញការងារ។ របាយការណ៍ពិនិត្យតាមដាន ត្រូវដាក់ជូនទៅថ្នាក់ដឹកនាំក្រសួងទទួលបន្ទុកឧត្តមសិក្សា។ របាយការណ៍ប្រចាំឆ្នាំត្រូវរួមបញ្ចូលវិធានការ សម្រាប់ការបំពេញការងារដែលត្រូវបានស្នើដោយគ្រឹះស្ថានឧត្តមសិក្សាសម្រាប់ធ្វើការកែលម្អផែនការការងាររបស់ខ្លួន។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១. កម្មវិធីចរន្ត** | **0** | **0** | **316.7** | **597.6** | **767.2** |
| ការអនុវត្តគោលនយោបាយ ស្រាវជ្រាវក្នុងវិស័យអប់រំ | 0 | 0 | 102.5 | 286.8 | 368.3 |
| ការបណ្តុះបណ្តាលនៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងបណ្ឌិត | 0 | 0 | 214.2 | 310.8 | 398.9 |
| **២. កម្មវិធីមូលធន** | **0** | **0** | **1218.7** | **1286.4** | **1431.4** |
| ការវិនិយោគ | 0 | 0 | 451 | 344.4 | 332.1 |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 0 | 0 | 767.7 | 942 | 1099.3 |
| **ធនធានសរុប** | 0 | 0 | **1535.4** | **1884** | **2198.6** |

## ៥.៣ កម្មវិធី ទី ៣ ៖ ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា

អង្គភាព ៖ អគ្គនាយកដ្ឋានកីឡា

### ១. វត្ថុបំណង

វត្ថុបំណងនៃកម្មវិធីអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា គឺអភិវឌ្ឍការងារអប់រំកាយនិងកីឡា ឱ្យទៅជាចំណុចស្នូលនៃកំណែទម្រង់ និង លើកកម្ពស់សុខភាព សមត្ថភាពជំនាញ បច្ចេកទេសអប់រំកាយនិងកីឡារបស់សិស្ស និស្សិត យុវជន និងមហាជន ប្រកបដោយគុណភាព និងសិទ្ធិផលខ្ពស់ក្នុងការប្រកួតជាលក្ខណៈជាតិ និងអន្តរជាតិ ព្រមទាំងចូលរួមអភិវឌ្ឍសង្គម វប្បធម៌ និងសេដ្ឋកិច្ចជាតិ។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌*

❖ ពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធកីឡាគ្រប់ប្រភេទនិងគ្រប់កម្រិត។

សកម្មភាពគោលនយោបាយ ៖

- ផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡា រៀបចំបាននៅឆ្នាំ ២០១១។
- សេចក្តីណែនាំស្តីពីការរៀបចំទីលានកីឡាតាមគ្រឹះស្ថានសិក្សា កែលម្អបាននៅឆ្នាំ ២០១១។
- សារាចរស្តីពី ការចងក្រងក្លឹបឬសមាគមកីឡា រៀបចំបាននៅឆ្នាំ ២០១១។
- លិខិតបទដ្ឋានស្តីពី ការបង្កើតមជ្ឈមណ្ឌលពិគ្រោះយោបល់ហាត់ប្រាណដើម្បីសុខភាព រៀបចំបាននៅឆ្នាំ ២០១២។
- កម្មវិធីបណ្តុះបណ្តាលគ្រូអប់រំកាយនិងកីឡាកម្រិតមូលដ្ឋាន កែលម្អបាននៅឆ្នាំ ២០១២។
- កម្មវិធីសិក្សាអប់រំកាយនិងកីឡាសម្រាប់គ្រឹះស្ថានបឋមនិងមធ្យមសិក្សា រៀបចំបាន នៅឆ្នាំ ២០១២
- សេចក្តីណែនាំការបង្កើតសមាគមកីឡានៅក្នុងគ្រឹះស្ថានបឋមនិងមធ្យមសិក្សា រៀបចំ បាននៅឆ្នាំ ២០១២។
- ឯកសារស្តីពីអត្តសញ្ញាណក្បាច់គុនបុរាណខ្មែរ រៀបចំបាននៅឆ្នាំ ២០១៣។

*គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

❖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពកម្មវិធីអប់រំកាយនិងកីឡា

សកម្មភាពគោលនយោបាយ ៖

- កម្រិតរបបឧបត្ថម្ភនិងអាហារបំប៉នសម្រាប់កីឡាករជម្រើសជាតិ រៀបចំបាននៅឆ្នាំ ២០១២។
- កម្មវិធីហ្វឹកហាត់កីឡា កែលម្អបាននៅឆ្នាំ ២០១២។
- លិខិតបទដ្ឋានដើម្បីបង្កើតកម្មវិធីវេជ្ជសាស្ត្រកីឡា រៀបចំបាននៅឆ្នាំ ២០១៣។
- កំណែទម្រង់ប្រព័ន្ធនៃការប្រកួតកីឡាគ្រប់ប្រភេទនិងគ្រប់កម្រិត រៀបចំបាននៅឆ្នាំ ២០១៣។

❖ លើកកម្ពស់ការយល់ដឹងនិងគាំទ្រអំពីសារៈសំខាន់របស់ការងារអប់រំកាយនិងកីឡា។

សកម្មភាពគោលនយោបាយ ៖

- គោលនយោបាយជាតិស្តីពីកីឡា រៀបចំបាននៅឆ្នាំ ២០១១។

## ៣ សូចនាករ និងចំណុចដៅ

- សមាគម ឬ ក្លឹបកីឡាដែលត្រូវចូលរួមប្រកួតមានចំនួន ២៥០ ទៅ ៣០០ ក្នុងមួយឆ្នាំ។
- ទីលានកីឡាចំនួន ២០ ត្រូវបានកែលម្អ ត្រឹមឆ្នាំ ២០១៣។
- ទីលានកីឡានៅតាមគ្រឹះស្ថានសិក្សាបឋមសិក្សានិងមធ្យមសិក្សាចំនួន ១៦៥ ត្រូវបានកែលម្អនៅឆ្នាំសិក្សា ២០១៣-២០១៤។
- អភិវឌ្ឍសមាគមកីឡាសិស្ស-និស្សិត ចំនួន ១២៥ នៅឆ្នាំសិក្សា ២០១៣-២០១៤។
- គ្រូអប់រំកាយ និងកីឡា ចំនួន ១៥០ នាក់ ត្រូវបានបណ្តុះបណ្តាលក្នុងមួយឆ្នាំ។
- កីឡាករជម្រើសជាតិ ចំនួន ៣៥០ នាក់ ត្រូវបានប្រមូលផ្តុំក្នុងមួយឆ្នាំ។
- ទស្សនាវដ្តីកីឡាត្រូវបានផ្សព្វផ្សាយជារៀងរាល់ខែ។

## ៤ សកម្មភាព និងកម្មវិធីចម្បង

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

***ការអភិវឌ្ឍសមាគមកីឡាមហាជន***

- កែលម្អទីលានកីឡា
- ត្រួតពិនិត្យតាមដានការកែលម្អទីលានកីឡា និងអភិវឌ្ឍសមាគមកីឡា
- បណ្តុះបណ្តាលមន្ត្រីគ្រប់គ្រង គ្រូបង្វឹក ចៅក្រម អាជ្ញាកណ្តាលថ្នាក់ ជាតិក្នុងមជ្ឈដ្ឋានមហាជនក្នុងប្រទេស និងក្រៅប្រទេស
- បំពាក់សម្ភារៈ និងឧបករណ៍កីឡានៅតាមសមាគម និងក្លឹបកីឡាមហាជន
- អភិវឌ្ឍគោលនយោបាយកីឡាមហាជន

- រៀបចំការប្រកួតកីឡាមហាជនជម្រើសជើងឯកភូមិភាគ និងជម្រើសជើងឯកថ្នាក់ជាតិ
- ស្រាវជ្រាវ ចងក្រងឯកសារកីឡាទំនើប កីឡាប្រពៃណី និងទិន្នន័យអ្នក លេងកីឡា ដើម្បីទាំងអស់គ្នា "ដើម្បីសុខភាព"

*ការអភិវឌ្ឍសមាគមកីឡាសិស្សនិស្សិត*

- ជួសជុលទីលានកីឡាក្នុងគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សា
- អភិវឌ្ឍសមាគមកីឡាក្នុងជួរសិស្ស-និស្សិត
- បំប៉នសមត្ថភាពគ្រូអប់រំកាយ និងកីឡា និងគ្រូចំណេះទូទៅ ដែលទទួលបន្ទុកការងារអប់រំកាយ និងកីឡានៅក្នុងគ្រឹះស្ថានមធ្យមសិក្សា និងសាលាគរុកោសល្យរាជធានី ខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ
- ពិនិត្យតាមដាន និងវាយតម្លៃការជួសជុលទីលានកីឡា ការអភិវឌ្ឍសមាគមកីឡា និងការបំប៉នសមត្ថភាពគ្រូអប់រំកាយនិងកីឡា
- អភិវឌ្ឍអង្គភាព សហព័ន្ធ សមាគម និងក្លឹបកីឡានៅក្នុងគ្រឹះស្ថានសិក្សា
- អភិវឌ្ឍគោលនយោបាយកីឡានៅក្នុងគ្រឹះស្ថានសិក្សា
- រៀបចំការប្រកួតកីឡាសិស្ស និស្សិតនៅគ្រប់កម្រិតសិក្សា
- រៀបចំកម្មវិធីហ្វឹកហាត់ដល់អត្តពលិកដែលជាសិស្ស-និស្សិត (ក្នុង និងក្រៅប្រទេស)
- បំពាក់សម្ភារៈ និងឧបករណ៍កីឡានៅតាមគ្រឹះស្ថានសិក្សា
- ស្រាវជ្រាវតែសកាយសមស្របនៅគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សា
- រៀបចំកម្មវិធីសិក្សាអប់រំកាយ និងកីឡាសម្រាប់បឋមសិក្សា និងមធ្យមសិក្សា

*ការបណ្តុះបណ្តាល និងស្រាវជ្រាវអប់រំកាយ និងកីឡា*

- បំប៉នគ្រូទទួលបន្ទុកការងារអប់រំកាយនិងកីឡាតាមកម្រង សាលាគរុកោសល្យនិងវិក្រឹតការរាជធានី ខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និង បំប៉នជំនាញ ថៅក្រមអាជ្ញាកណ្តាល
- បណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡាកម្រិតមូលដ្ឋាន
- ស្រាវជ្រាវ បកប្រែ ចងក្រង រក្សាឯកសារស្តីពី វិទ្យាសាស្ត្រអប់រំកាយ និងកីឡា
- ត្រួតពិនិត្យ និងតាមដានលើវិធីសាស្ត្របង្ហាត់បង្រៀនអប់រំកាយ និងកីឡា
- កែលម្អកម្មវិធីបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា

*ការអភិវឌ្ឍកីឡាកម្រិតខ្ពស់*

- ប្រមូលផ្តុំគ្រូបង្វឹក អនុរក្ស និងកីឡាករជម្រើសជាតិ ហាត់ហ្វឹកហ្វឺនត្រៀម ចូលរួមការប្រកួតលក្ខណៈ អន្តរជាតិ
- បំប៉នសមត្ថភាពគ្រូបង្វឹក អនុរក្ស និងកីឡាករជម្រើសជាតិ
- បំពាក់សម្ភារៈ និងឧបករណ៍បច្ចេកទេសហាត់ជំនួយសាច់ដុំ ដើម្បីបង្កើនប្រសិទ្ធភាព កម្លាំងកាយ ថាមពលមាំមួន បច្ចេកទេសល្អ និងសិទ្ធិផលកើនឡើង
- រៀបចំលិខិតបទដ្ឋាន ចងក្រងឯកសារកីឡាគ្រប់ប្រភេទតម្កល់ទុកក្នុងបណ្ណាល័យ
- និពន្ធ រៀបរៀង និងបោះពុម្ពទស្សនាវដ្តីកីឡា ចែកជូនតាមបណ្តារាជធានី-ខេត្ត

៤.២ កម្មវិធីចំណាយមូលធន

*ការវិនិយោគ ៖*

- សាងសង់សាលដំបូលទូកសម្រាប់ហ្វឹកហាត់កីឡាបាល់ទះ និង សាងសង់ទីលានកីឡា អត្តពលកម្ម សិប្បនិម្មិតនៅក្នុងពហុកីឡដ្ឋានជាតិ
- សាងសង់អគារសិក្សា អន្តេវាសិកដ្ឋាន និងសាលសម្រាប់ហាត់កីឡា នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា
- កសាងទីលានកីឡាក្នុងគ្រឹះស្ថានសិក្សា (កីឡាបាល់បោះ និងបាល់ទាត់)
- សាងសង់មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡាឱ្យបានត្រឹមត្រូវតាមនិយាមបច្ចេកទេស និងបង្កើតមជ្ឈមណ្ឌលភូមិភាគ

## ៥ ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

កម្មវិធីអភិវឌ្ឍវិស័យអប់រំកាយ និង កីឡាត្រូវគ្រប់គ្រង និងពិនិត្យតាមដាន តាមរយៈប្រធានអនុកម្មវិធីនីមួយៗ ដូចជា នាយកដ្ឋានអប់រំកាយនិងកីឡា នាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិត វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា និងមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា។ ការងារនេះ មានការសម្របសម្រួលរវាងប្រធាន អនុកម្មវិធីនៃនាយកដ្ឋានពាក់ព័ន្ធ ដើម្បីធានាឱ្យការពិនិត្យតាមដានមានតម្លាភាព និងប្រសិទ្ធភាពខ្ពស់។ ការពិនិត្យតាមដានកម្មវិធី ក៏មានកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នដែលពាក់ព័ន្ធការងារអប់រំកាយនិងកីឡានានាទាំងផ្នែកបច្ចេកទេសនិងថវិកា ដើម្បីរួមចំណែកអភិវឌ្ឍការងារអប់រំកាយ និងកីឡាគ្រប់ប្រភេទ និងគ្រប់លំដាប់ថ្នាក់។

## ៦ ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១- កម្មវិធីចរន្ត** | **1243.0** | **1315.4** | **1446.2** | **1530.1** | **1673.8** |
| ការអភិវឌ្ឍសមាគមកីឡាមហាជន | 350.0 | 300.0 | 337.8 | 371.9 | 414.6 |
| ការអភិវឌ្ឍសមាគមកីឡាសិស្ស-និស្សិត | 300.7 | 303.0 | 341.2 | 340.8 | 379.6 |
| ការបណ្តុះបណ្តាល និងស្រាវជ្រាវអប់រំកាយ និងកីឡា | 298.0 | 420.0 | 473.0 | 521.0 | 581.0 |
| ការអភិវឌ្ឍកីឡាកម្រិតខ្ពស់ | 294.3 | 292.4 | 294.2 | 296.4 | 298.6 |
| ធនធានសរុប | 1243.0 | 1315.4 | 1446.2 | 1530.1 | 1673.8 |

## ៥.៤ កម្មវិធីទី ៤ ៖ ការអភិវឌ្ឍយុវជន

អង្គភាព ៖ អគ្គនាយកដ្ឋានយុវជន

### ១. វត្ថុបំណង

យុវជនកម្ពុជាទាំងពីរភេទស្គាល់អត្តសញ្ញាណខ្លួននិងជាតិនិងសារៈសំខាន់នៃចំណេះដឹង ដោយខិតខំអភិវឌ្ឍសមត្ថភាពលើគ្រប់ផ្នែកប្រកបដោយគតិបណ្ឌិត ស្មារតីទទួលខុសត្រូវ មានសីលធម៌ល្អ ចេះជួយគ្នាទៅវិញទៅមកមានបំណិនវិជ្ជាជីវៈ មានសមត្ថភាពផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាន មានឥរិយាបថវិជ្ជមាន មានភាពជាគំរូចំពោះការងារនិងសង្គម មានការយល់ដឹងជ្រៅជ្រះអំពី ការវិវត្ត និងប្រព័ន្ធគ្រប់គ្រងច្បាប់ទម្លាប់របស់សង្គមហើយចូលរួមដោយស្មើភាពក្នុងកិច្ចការអភិវឌ្ឍប្រទេសជាតិ។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌*

❖ ពង្រីកការទទួលបានសេវាពីកម្មវិធីអភិវឌ្ឍយុវជន ដល់យុវជនបាត់បង់ឱកាស។
- គោលនយោបាយជាតិយុវជនកម្ពុជា រៀបចំបាននៅឆ្នាំ ២០១០។
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន រៀបចំបាននៅឆ្នាំ ២០១១។
- ផែនការពង្រីកមជ្ឈមណ្ឌលយុវជននៅតាមរាជធានី ខេត្ត កសាងបាននៅឆ្នាំ ២០១២។
- គោលការណ៍ស្តីពី ការបង្កើតមូលនិធិអប់រំសមធម៌ជាតិ សម្រាប់យុវជនក្រីក្របំផុត (កម្មវិធីអាហារូបត្ថម្ភ និងអន្តេវាសិកដ្ឋាន) រៀបចំបាននៅឆ្នាំ ២០១៣។

*គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

❖ បង្កើនគុណភាពនិងប្រសិទ្ធភាពនៃកម្មវិធីអភិវឌ្ឍយុវជន តម្រង់ទៅរកការអភិវឌ្ឍសង្គម សេដ្ឋកិច្ច។
- ឯកសារគាំទ្រស្តីពី ការអនុវត្តក្រុមប្រឹក្សាយុវជន រៀបចំបាននៅឆ្នាំ ២០១១។
- ស្តង់ដាសម្រាប់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៅតាមមជ្ឈមណ្ឌលយុវជន កសាងបាននៅឆ្នាំ ២០១២។

*គោលនយោបាយទី៣ ៖ អភិវឌ្ឍស្ថាប័ន និង អភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

❖ ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់កម្មវិធីអភិវឌ្ឍយុវជន ដើម្បីដោះស្រាយតម្រូវការរបស់យុវជនក្នុងតំបន់។
- លិខិតបទដ្ឋានក្នុងការបង្កើត ព្រឹត្តិបត្តិយុវជននិងកុមារ រៀបចំបាននៅឆ្នាំ២០១១។

## ៣. សូចនាករ និងចំណុចដៅ

- ចំនួនក្រុមប្រឹក្សាយុវជន ៩២% នៃសាលាមធ្យមសិក្សានៅឆ្នាំសិក្សា ២០០៩-២០១០ កើនដល់ ១០០% នៅឆ្នាំសិក្សា ២០១៣-២០១៤។
- ចំនួនក្រុមប្រឹក្សាកុមារ ៧៨% នៃសាលាបឋមសិក្សានៅឆ្នាំសិក្សា ២០០៩-២០១០ កើនដល់ ១០០% នៅឆ្នាំសិក្សា ២០១៣-២០១៤។
- យុវជនបានយល់ដឹងអំពីមេរោគនិងជំងឺអេដស៍កើនពីចំនួន ៥៨០០ នាក់នៅឆ្នាំសិក្សា ២០០៩-២០១០ ទៅដល់ ៩០០០នាក់ នៅឆ្នាំសិក្សា ២០១៣-២០១៤។
- ចំនួនសិក្ខាកាមឆ្លងកាត់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈកើនពី ៨៥០ នាក់ដល់ ៣៥៦០នាក់ នៅឆ្នាំសិក្សា ២០១៣-២០១៤។
- ចំនួនយុវជនស្ម័គ្រចិត្ត ៨៨០០ នាក់នៅឆ្នាំសិក្សា ២០១៣-២០១៤។

## ៤. សកម្មភាព និងកម្មវិធីចម្បងៗ

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

### *ថវិកាដំណើរកម្មវិធីអភិវឌ្ឍយុវជន*

- សិក្ខាសាលាផ្សព្វផ្សាយអំពីការយល់ដឹងជំងឺអេដស៍
- ការពង្រឹងក្រុមប្រឹក្សាយុវជន និងកុមារ
- ការអប់រំយុវជន និងកុមារ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ
- ការផ្លាស់ប្តូរបទពិសោធន៍ តាមរយៈទស្សនៈកិច្ចសិក្សាបោះជំរំក្នុងប្រទេស និងការប្រជុំ ផ្សេងៗ
- ផ្តល់ការបណ្តុះបណ្តាលអំពីការងារស្ម័គ្រចិត្ត និងជំនាញវិជ្ជាជីវៈខ្លីៗដល់យុវជន
- ការគាំទ្រអង្គភាព និង អភិវឌ្ឍ មជ្ឈមណ្ឌលយុវជន
- សិក្ខាសាលាផ្សព្វផ្សាយ
- ការគាំទ្រដំណើរការ

### *ការពង្រឹងសមត្ថភាព*

- វគ្គបំប៉នសមត្ថភាពស្តីពីការងារដឹកនាំគ្រប់គ្រង ដល់មន្ត្រីគ្រប់គ្រងយុវជន

### *ពិនិត្យតាមដាន និងវាយតម្លៃ*

- ការពិនិត្យតាមដាន និងវាយតម្លៃលើកម្មវិធីអភិវឌ្ឍយុវជន

៤.២ កម្មវិធីមូលធន

*ការវិនិយោគ៖*

- សាងសង់ និងបំពាក់បរិក្ខារដល់មជ្ឈមណ្ឌលយុវជនចំនួន ០៤
- ជួសជុល និងបំពាក់បរិក្ខារដល់មជ្ឈមណ្ឌលយុវជនចំនួន ០៤

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- រៀបចំគោលនយោបាយយុវជនជាតិកម្ពុជា
- វគ្គបំប៉នសមត្ថភាពស្តីពីការបណ្តុះបណ្តាលវិជ្ជាជីវៈដល់មន្ត្រីគ្រប់គ្រងយុវជន។

## ៥. ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

កម្មវិធីយុវជនត្រូវគ្រប់គ្រង និងពិនិត្យតាមដានតាមរយៈ អគ្គនាយកដ្ឋានយុវជន ដែលបានបង្កើតក្នុងអគ្គនាយកដ្ឋានយុវជន ដែលមាននាយកដ្ឋាន យុវជន និងនាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌលយុវជន។ ការងារនេះនឹងមានការសម្របសម្រួលយ៉ាងជិតស្និទ្ធរវាងនាយកដ្ឋានទាំងពីរ និង នាយកដ្ឋានដទៃទៀត ដើម្បីធានាឱ្យការធ្វើសមាហរណកម្មយុទ្ធសាស្ត្រ និងកម្មវិធីមានប្រសិទ្ធភាពស្ថិតនៅក្នុងក្របខណ្ឌនៃអាណត្តិរបស់ក្រសួង។ ការពិនិត្យ តាមដានកម្មវិធី នឹងរួមបញ្ចូលទាំង សហប្រតិបត្តិការជាមួយស្ថាប័នយុវជន និងស្ថាប័នពាក់ព័ន្ធ ហើយនឹងប្រើប្រាស់លទ្ធផលអង្កេតពីមាតាបិតា យុវជន និងសហគមន៍ និងធ្វើការវិភាគលើផលប៉ះពាល់នៃការអភិវឌ្ឍសង្គមទៅលើយុវជន។ អាទិភាពចម្បងមួយគឺការអភិវឌ្ឍក្របខណ្ឌពិនិត្យតាមដាន រួមមានចំណុចដៅប្រព័ន្ធផ្សេងៗ និងការទទួលខុសត្រូវ ។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១. កម្មវិធីចរន្ត** | **877.0** | **1101.6** | **1550.0** | **1860.0** | **2210.0** |
| ដំណើរការកម្មវិធីអភិវឌ្ឍយុវជន | 699.3 | 868.9 | 117.0 | 1405.0 | 1660.0 |
| ការពង្រឹងសមត្ថភាព | 0 | 89.3 | 180.0 | 240.0 | 300.0 |
| ការពិនិត្យតាមដាននិងវាយតម្លៃ | 117.7 | 143.4 | 200.0 | 215.0 | 250.0 |
| **២. កម្មវិធីមូលធន** | **25.0** | **25.0** | **1409.6** | **2159.4** | **2269.4** |
| ការវិនិយោគ | 0 | 0 | 1279.6 | 1919.4 | 1919.4 |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 25.0 | 25.0 | 130.0 | 240.0 | 350.0 |
| **ធនធានសរុប:** | **902.0** | **1126.6** | **2959.6** | **4019.4** | **4479.4** |

## ៥.៥ កម្មវិធីទី ៥ ៖ ការគាំទ្រ ការគ្រប់គ្រងសេវាអប់រំ និងអភិបាលកិច្ចល្អ

### អនុកម្មវិធី ៥.១ ៖ ការអភិវឌ្ឍគោលនយោបាយនិងពង្រឹងប្រព័ន្ធផែនការអប់រំ

អង្គភាព ៖ នាយកដ្ឋានផែនការ

### ១. វត្ថុបំណង

វត្ថុបំណងរបស់អនុកម្មវិធីនេះគឺ៖ ទី១)ធានាកសាងបានប្រព័ន្ធផែនការច្បាស់លាស់និងស៊ីសង្វាក់គ្នានៅគ្រប់លំដាប់ថ្នាក់។ ទី ២)ធានាការអភិវឌ្ឍប្រព័ន្ធព័ត៌មានស្ថិតិប្រកបដោយគុណភាព និងទាន់ពេលវេលា។ ទី៣)ធានាការអនុវត្តប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅគ្រប់លំដាប់ថ្នាក់។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី៣ ៖ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

❖ បង្កើនគុណភាពនិងប្រសិទ្ធភាពនៃការកសាងផែនការ ពិនិត្យតាមដាន ពិនិត្យឡើងវិញ និងវាយតម្លៃការអនុវត្តផែនការ នៅថ្នាក់ជាតិនិង ថ្នាក់ក្រោមជាតិ។

សកម្មភាពគោលនយោបាយ ៖

- សេចក្តីណែនាំស្តីពីផែនការប្រតិបត្តិប្រចាំឆ្នាំ២០១១ រៀបចំបាននៅឆ្នាំ ២០១០។
- សេចក្តីណែនាំស្តីពីការបង្កើតក្រុមការងារពង្រឹងការងារផែនការ ស្ថិតិ និងគ្រប់គ្រងជំនួយនៅថ្នាក់ក្រោមជាតិ រៀបចំបាននៅឆ្នាំ ២០១១។
- ផែនការអភិវឌ្ឍសមត្ថភាពការងារផែនការ ការពិនិត្យតាមដាន និងការវាយតម្លៃ កសាងបាននៅឆ្នាំ២០១១។
- សេចក្តីណែនាំស្តីពីការបង្កើតផែនការរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត រៀបចំបាននៅឆ្នាំ២០១១។
- សេចក្តីណែនាំស្តីពីការកសាងផែនការយុទ្ធសាស្ត្រវិស័យអប់រំសម្រាប់ដំណាក់កាលឆ្នាំ ២០១៤-២០១៨ រៀបចំបាននៅឆ្នាំ ២០១២។

❖ ពង្រឹងការតម្រឹម សុខដុមនីយកម្ម និងការសម្របសម្រួល ក្នុងការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ ដែលដឹកនាំដោយក្រសួងនិងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ។

សកម្មភាពគោលនយោបាយ ៖

- ការឯកភាពគ្នាលើគោលការណ៍ភាពជាដៃគូរវាងក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍត្រឹមឆ្នាំ២០១០។

- សូចនាករពិនិត្យតាមដានរួមគ្នា ស្ដីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការក្នុងវិស័យអប់រំ រៀបចំបាននៅឆ្នាំ ២០១០។
- សេចក្ដីណែនាំស្ដីពីការបង្កើតក្រុមការងារបច្ចេកទេសថ្នាក់ក្រោមជាតិ បានបង្កើតនៅឆ្នាំ២០១១។

## ៣. សូចនាករ និងចំណុចដៅ

- របាយការណ៍សន្និបាតអប់រំ ដែលត្រូវបានកែលម្អគុណភាពត្រូវបានវាយតម្លៃជាមួយនឹងលក្ខណវិនិច្ឆ័យសម្រាប់ការវាយតម្លៃដែលបានឯកភាពគ្នា ក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ។
- ផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលត្រូវបានកែលម្អគុណភាពត្រូវបានវាយតម្លៃជាមួយនឹងលក្ខណវិនិច្ឆ័យសម្រាប់ការវាយតម្លៃ ដែលបានឯកភាពគ្នាក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ។
- គោលការណ៍ភាពជាដៃគូនឹងត្រូវបានឯកភាពរួមគ្នារវាងក្រសួង និងដៃគូអភិវឌ្ឍក្នុងឆ្នាំ ២០១០ ជាមួយគ្នានោះសូចនាករ និងសកម្មភាពស្ដីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការត្រូវបានពិនិត្យតាមដានជារៀងរាល់ឆ្នាំ។
- ផែនការរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តរៀបចំបានចាប់ពីឆ្នាំ២០១២។
- រាជធានី ខេត្តទាំងអស់រៀបចំបានផែនការប្រតិបត្តិប្រចាំឆ្នាំ នៅឆ្នាំ ២០១៣។

## ៤. កម្មវិធី និងសកម្មភាពចម្បងៗ

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- ពង្រឹងដំណើរការកសាងផែនការ ពិនិត្យតាមដាន និងវាយតម្លៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ តាមរយៈការកែលម្អសន្និបាតអប់រំប្រចាំឆ្នាំ ការពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិ និងដំណើរការកសាងផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅជំហានបន្ទាប់ និងធ្វើអង្កេតលើ ផលប៉ះពាល់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ។
- ពង្រឹងដំណើរការកសាងផែនការ ពិនិត្យតាមដាន ពិនិត្យឡើងវិញ និងវាយតម្លៃផែនការប្រតិបត្តិប្រចាំឆ្នាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ថវិកាកម្មវិធី ផែនការយុទ្ធសាស្ត្រថវិកា និងកម្មវិធីវិនិយោគសាធារណៈ ស្របទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដើម្បីបង្កើតការផ្សារភ្ជាប់កាន់តែជិតស្និទ្ធជាងមុនរវាងផែនការនិងថវិកា។
- កែលម្អការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការក្នុងវិស័យអប់រំ តាមរយៈ ការពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងជំនួយអប់រំ និងការវិភាគលើប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ រាប់

បញ្ចូលទាំងការពិនិត្យតាមដាន សូចនាករពិនិត្យតាមដានរួមគ្នា និងតាមរយៈការពង្រឹងក្រុមការងារបច្ចេកទេសរួមគ្នារាប់បញ្ចូលទាំងការបង្កើតក្រុមការងារបច្ចេកទេសថ្នាក់ខេត្ត។

- ចងក្រងនិងផ្សព្វផ្សាយស្ថិតិនិងសូចនាករអប់រំគ្រប់ប្រភេទ គ្រប់ភូមិសិក្សា និងគ្រប់លំដាប់ថ្នាក់ និងធ្វើបច្ចុប្បន្នភាពផែនទីសិក្សាដោយប្រើប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ជារៀងរាល់ឆ្នាំ។
- វគ្គបំប៉នសមត្ថភាពការងារផែនការ ស្ថិតិ និងគ្រប់គ្រងជំនួយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

៤.២ កម្មវិធីមូលធន

*ការវិនិយោគ ៖*

- កែលម្អប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ដែលមានបញ្ចូលរបាយការណ៍តាមដំណាក់កាលនីមួយៗ និងតាមតម្រូវការ ដែលផ្អែកលើប្រព័ន្ធកុំព្យូទ័រ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- វគ្គបំប៉នរយៈពេលវែងនិងមធ្យមលើជំនាញផែនការនិងគ្រប់គ្រងអប់រំ ។
- វគ្គបំប៉នស្តីពីការកសាងផែនការ ការវិភាគស្ថិតិ ការពិនិត្យតាមដាន ការវាយតម្លៃ និងការលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ៥. ការគ្រប់គ្រង និងការពិនិត្យតាមដានកម្មវិធី

នាយកដ្ឋានផែនការនឹងទទួលខុសត្រូវលើការអនុវត្តអនុកម្មវិធីនេះ។ ការិយាល័យ និងផ្នែកផែនការនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងអនុវត្តសកម្មភាពនៅកម្រិតថ្នាក់ក្រោមជាតិ ដែលនឹងត្រូវ ពិនិត្យតាមដានទៀងទាត់ដោយនាយកដ្ឋានផែនការ។ សមាសភាគទាំងអស់របស់ អនុកម្មវិធីនឹងត្រូវបំបែកទៅជាសកម្មភាពតាមឆ្នាំនីមួយៗ ដែលឆ្លុះបញ្ចាំងចំណុចដៅនិងលទ្ធផលច្បាស់លាស់នៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ លទ្ធផលនៃការពិនិត្យតាមដាន និងវាយតម្លៃរបស់អនុកម្មវិធីនេះ នឹងត្រូវបញ្ចូលក្នុងរបាយការណ៍សន្និបាតអប់រំប្រចាំឆ្នាំ និង របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១. កម្មវិធីចរន្ត** | **558.0** | **600.0** | **603.5** | **744.0** | **819.0** |
| អភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | 0 | 62.0 | 66.5 | 86.0 | 100.0 |
| អភិវឌ្ឍប្រព័ន្ធកសាងផែនការ | 0 | 483.6 | 483.6 | 584.6 | 619.0 |
| ពិនិត្យតាមដានប្រសិទ្ធភាពនិងផលប៉ះពាល់នៃការអនុវត្តផែនការ | 0 | 54.4 | 53.4 | 73.4 | 100.0 |
| **២. កម្មវិធីមូលធន** | **5496.0** | **6908.0** | **11753.0** | **10349.0** | **7876.0** |
| ការវិនិយោគ | 0 | 0 | 410.0 | 0 | 0 |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 5496.0 | 6908.0 | 11343.0 | 10349.0 | 7876.0 |
| ធនធានសរុប | 6054.0 | 7508.0 | 12428.0 | 11093.0 | 8695.0 |

## អនុកម្មវិធី ៥.២ ៖ ការអភិវឌ្ឍការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន

អង្គភាព ៖ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ

### ១. វត្ថុបំណង និងយុត្តិកម្ម

វត្ថុបំណងទីមួយ គឺធានាការផ្តល់គ្រូបង្រៀនគ្រប់កម្រិតសិក្សាប្រកបដោយប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងការពង្រីកប្រព័ន្ធអប់រំ រួមទាំងការពង្រីកសមត្ថភាពអ្នកគ្រប់គ្រងសាលាគរុកោសល្យ និងអ្នកគ្រប់គ្រងអប់រំ គ្រូឧទ្ទេស នាយកសាលារៀន និងមន្ត្រីអប់រំសំខាន់ៗផ្សេងទៀត។

វត្ថុបំណងទី២ គឺធានាថាគរុសិស្ស-គរុនិស្សិតនៅសាលាគរុកោសល្យ និងវិ ទ្យាស្ថានជាតិអប់រំ ព្រមទាំងការដាក់ពង្រាយគ្រូចេញថ្មី ឆ្លើយតបទៅនឹងកំណើនតម្រូវការនៅ តំបន់ជនបទតំបន់ដាច់ស្រយាល និងតំបន់ ជួបការលំបាក តាមរយៈការជ្រើសរើស សគរុសិស្ស-គរុនិស្សិតថ្មីពីតំបន់ទាំងនោះ និងតំបន់ជនជាតិភាគតិច។

វត្ថុបំណងទី៣គឺកែលម្អគុណភាពនៃការបង្រៀនតាមរយៈការពង្រីកការធ្វើវិក្រឹតការគ្រូបង្រៀន។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌*

❖ ធានាសនិទានកម្មបុគ្គលិកអប់រំសម្រាប់តំបន់ដាច់ស្រយាល និងជួបការលំបាក ។

សកម្មភាពគោលនយោបាយ

- ផែនការសកម្មភាពក្នុងការបង្រៀនថ្នាក់គួបសម្រាប់គ្រូនៅតំបន់ព្រំដែន តំបន់ដាច់ស្រយាល និងឬតំបន់ជនជាតិភាគតិចត្រូវបានរៀបចំជារៀងរាល់ឆ្នាំ។

*គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

❖ លើកកម្ពស់ការអភិវឌ្ឍគ្រូបង្រៀនទាំងការបណ្តុះបណ្តាល និងវិក្រឹតការ។

សកម្មភាពគោលនយោបាយ ៖

- ផែនការសកម្មភាពសម្រាប់អភិវឌ្ឍសមត្ថភាពត្រូវបានរៀបចំតាមឆ្នាំនីមួយៗ។
- របាយការណ៍ស្តីពី ការវិភាគតម្រូវការបំប៉ននិងផែនការសម្រាប់អភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេស ត្រូវបានបញ្ចប់នៅឆ្នាំ ២០១០។
- ផែនការគោលស្តីពី ការអភិវឌ្ឍគ្រូបង្រៀន ត្រូវបានបញ្ចប់នៅឆ្នាំ២០១០។
- របាយការណ៍ស្តីពី ការវិភាគតម្រូវការសម្ភារៈរូបវន្តនៅតាមសាលាគរុកោសល្យ ត្រូវបានបញ្ចប់នៅឆ្នាំ ២០១០។

- ផែនការលើកកម្ពស់សមត្ថភាពគ្រូបង្រៀនមធ្យមសិក្សាដែលសមត្ថភាពនៅមានកម្រិត រៀបចំបាននៅឆ្នាំ ២០១១។
- ខ្លឹមសារឯកសារ ICT ក្នុងកម្មវិធីបណ្តុះបណ្តាល គ្រូបង្រៀនត្រូវបានកែលម្អ នៅឆ្នាំ ២០១១។
- ម៉ូឌុលស្តីពីការយល់ដឹងយេនឌ័រ ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីបណ្តុះបណ្តាលជាផ្លូវការ នៅឆ្នាំ ២០១១។
- កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវបានបញ្ចប់ការកែលម្អ នៅឆ្នាំ២០១២។
- ម៉ូឌុលស្តីពីការអប់រំបញ្ចូលគ្នា ក្នុងកម្មវិធីបណ្តុះបណ្តាលត្រូវ បានកែលម្អនៅឆ្នាំ ២០១២។

## ៣. សូចនាករ និងចំណុចដៅ

- គរុសិស្ស-គរុនិស្សិតថ្មីចំនួន ៥០០០នាក់ ក្នុងមួយឆ្នាំត្រូវបានជ្រើសរើសចូលរៀននៅសាលាគរុកោសល្យ ដែលក្នុងនោះយ៉ាងតិច ៥០% មកពីតំបន់ជនបទ តំបន់ជួបការលំបាក តំបន់ដាច់ស្រយាល និងក្រុមជនជាតិភាគតិច។
- គ្រូបឋមសិក្សាចំនួន ៣០០០នាក់ ត្រូវបាន បង្កើនសមត្ថភាពឱ្យក្លាយជាគ្រូបង្រៀនកម្រិតអប់រំមូលដ្ឋាន តាមរយៈការបំប៉ន នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង ៦ នៅត្រឹមឆ្នាំសិក្សា ២០១៣-២០១៤។
- អធិការបឋមសិក្សាចំនួន ៩០ នាក់ និងអធិការមធ្យមសិក្សាចំនួន ១២០ នាក់ ត្រូវបានជ្រើសរើស តាមរយៈការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ ត្រឹមឆ្នាំ សិក្សា ២០១៣-២០១៤។
- គរុសិស្ស-គរុនិស្សិតចំនួន ១,៥០០ នាក់ត្រូវបានជ្រើសរើសជារៀងរាល់ឆ្នាំ ពីតំបន់ជួបការលំបាក ហើយពួកគេត្រូវបានចាត់តាំងឲ្យទៅប ម្រើការនៅតំបន់នោះវិញ ក្រោយពីបញ្ចប់ការបណ្តុះបណ្តាល ។

## ៤. សកម្មភាព និងកម្មវិធីចម្បងៗ

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

*១- ថវិកាដំណើរការសាលាគរុកោសល្យទាំង ២៥*

- ផ្តល់ថវិកាដំណើរការប្រចាំឆ្នាំ ដល់សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិមសាលាគរុកោសល្យនិងវិក្រឹតការរាជធានី-ខេត្តទាំង១៨ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦ និងមជ្ឈមណ្ឌលធនធានចំនួន៦ សំដៅកែលម្អគុណភាព និងប្រសិទ្ធភាពនៃកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន។ អាទិភាពមួយ

សម្រាប់សាលាគរុកោសល្យ គឺការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ដើម្បីឆ្លើយតបប្រកប ដោយភាពទន់ភ្លន់ទៅនឹងការប្រែប្រួលការចូលរៀននៅបណ្តាឆ្នាំខាងមុខនេះ។

*២- កម្មវិធីអភិវឌ្ឍសមត្ថភាពគ្រប់គ្រងអប់រំ*

- ផ្តល់ឱ្យនាយកសាលាបឋមសិក្សា និងមធ្យមសិក្សានូវជំនាញនានា ដើម្បីអនុវត្តការដឹកនាំឱ្យបានសកម្ម និងទទួលខុសត្រូវក្នុងការអនុវត្តវិធានការនានា និងគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាពនិងគុណភាព តាមរយៈកម្មវិធីបំប៉នសមត្ថភាពគ្រប់គ្រងអប់រំ។

*៣- កម្មវិធីបន្តការអភិវឌ្ឍវិក្រឹតការគ្រូបង្រៀន*

- បង្កើនសមត្ថភាពបុគ្គលិក នៅសាលាគរុកោសល្យទាំងអស់ រួមមានការបំប៉នគ្រូឧទ្ទេស តាមរយៈកម្មវិធីអភិវឌ្ឍបុគ្គលិក នៅសាលាគរុកោសល្យ។
- ផ្តោតការយកចិត្តទុកដាក់ទៅលើការបង្រៀនថ្នាក់គួប ជាពិសេសសម្រាប់សាលារៀនដែលស្ថិតនៅក្នុងតំបន់ដាច់ស្រយាល និងសាលារៀនមិនគ្រប់កម្រិតថ្នាក់។ អាទិភាពត្រូវផ្តល់ឱ្យគ្រូបង្រៀន ដែលបច្ចុប្បន្នកំពុងបង្រៀនថ្នាក់គួប។
- បង្កើនសមត្ថភាពគ្រូបឋមសិក្សាឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងកំណើនសិស្សចូលរៀននៅមធ្យមសិក្សាបឋមភូមិ។
- បំប៉នសមត្ថភាព ស្តី ពីការប្រើប្រាស់កម្មវិធីសិក្សា ស្តង់ដាកម្មវិធីសិក្សា និ ងអប់រំបញ្ចូលគ្នាជូនដល់គ្រូបង្រៀននៅគ្រប់កម្រិតសិក្សា។
- ផ្តល់ការបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ ដល់គ្រូឧទ្ទេស និងគ្រូមធ្យមសិក្សាទាំងអស់។
- បំប៉នសមត្ថភាព ស្តីពីការបញ្ច្រាបយេនឌ័រជូនដល់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

### ៤.២ កម្មវិធីមូលធន

*ការវិនិយោគ ៖*

- លទ្ធកម្មបំពាក់ឧបករណ៍ ICT នៅសាលាគរុកោសល្យត្រូវបានរៀបចំឡើងនៅឆ្នាំ ២០១១។

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់អ្នកដឹកនាំ នៅគ្រប់សាលាគរុកោសល្យ។

- ពង្រឹងសមត្ថភាពគ្រូឧទ្ទេស នៅសាលាគរុកោសល្យទាំងអស់អំពីវិធីសាស្ត្របង្រៀន ដូចជា ការសិក្សា ស្រាវជ្រាវ មេរៀន និងការសិក្សាតាមបែបរិះរក (Lesson Study and Inquiry Base Learning)។
- បំប៉នគ្រូឧទ្ទេសនៅសាលាគរុកោសល្យ ស្តីពីការអភិវឌ្ឍ និងប្រើប្រាស់សម្ភារឧបទេស។
- បំប៉នគ្រូឧទ្ទេសនៅសាលាគរុកោសល្យ ស្តីពីការប្រើប្រាស់ឧបករណ៍ពិសោធន៍។
- ពង្រឹងសមត្ថភាពមន្ត្រីនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ដើម្បីកំណត់សកម្មភាពជាអាទិភាពសំដៅធ្វើឱ្យការផ្តល់សេវាកាន់តែមានប្រសិទ្ធភាព តាមរយៈសកម្មភាពដូចខាងក្រោម ៖
    - រៀបចំផែនការសកម្មភាពសម្រាប់បណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន ដើម្បីពង្រាយទៅកាន់សាលារៀននៅតំបន់ជនបទ តំបន់ដាច់ស្រយាល និងតំបន់ ជួបការលំបាក ដោយសហការជាមួយនាយកដ្ឋានបុគ្គលិក។
    - អភិវឌ្ឍផែនការសកម្មភាពសម្រាប់ពង្រឹងនិងពង្រីកការធ្វើវិក្រឹតការគ្រូបង្រៀន។
    - វាយតម្លៃកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន រួមមានផលប៉ះពាល់នៃកម្មវិធីបណ្តុះបណ្តាលគ្រូសម្រាប់តំបន់ជនបទ តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។

## ៥. ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

គោលបំណងនៃកម្មវិធីនេះ គឺធ្វើវិមជ្ឈការការពិនិត្យតាមដាន និងការវាយតម្លៃដល់សាលាគរុកោសល្យពីមជ្ឈការកសាងផែនការនិងត្រួតពិនិត្យ ទៅជាការពិនិត្យតាមដាននិងការគាំទ្រពីប្រព័ន្ធបណ្តុះបណ្តាលថ្នាក់ជាតិ។ វត្ថុបំណងជាយុទ្ធសាស្ត្រនេះ គឺបង្ក លទ្ធភាពផ្ទេរសិទ្ធិទទួលខុសត្រូវ និងស្វ័យភាពប្រតិបត្តិកាន់តែធំធេងដល់សាលាគរុកោសល្យ។

ថវិកាសម្រាប់ដំណើរការគ្រឹះស្ថាននីមួយៗត្រូវបានផ្តល់ជូនតាមរយៈមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត និងនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ។ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការត្រូវទទួលខុសត្រូវចំពោះការពិនិត្យតាមដាន និងការធានាគុណភាព។ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ត្រូវទទួល ខុសត្រូវចំពោះការកសាងផែនការនិងពិនិត្យតាមដានទូទៅ រួមមាន ការបែងចែកថវិកាទៅតាមសេចក្តីណែនាំដែលបានឯកភាពគ្នារួចហើយ។ សាលាគរុកោសល្យនីមួយៗ ត្រូវរៀបចំផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ និងរបាយការណ៍រីកចម្រើនប្រចាំត្រីមាសរៀងរាល់ឆ្នាំ។

ការបែងចែកមូលនិធិទៅដល់សាលាគរុកោសល្យ ត្រូវគ្រប់គ្រងដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។ មន្ទីរអប់រំ យុវជន និង កីឡារាជធានី ខេត្តត្រូវរៀបចំផែនការបែងចែកថវិកា និងទទួលខុសត្រូវធ្វើរបាយការណ៍កិច្ចបញ្ជីការគណនេយ្យ។ គណៈកម្មការប្រើប្រាស់ មូលនិធិរបស់

សាលាគរុកោសល្យ រួមមាននាយក នាយករង តំណាងបុគ្គលិក ២រូប និង តំណាងគរុសិស្ស គរុនិស្សិត ២រូប។

នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការទទួលខុសត្រូវ ចំពោះសកម្មភាពពិនិត្យតាមដានកម្មវិធី ដោយគិតទាំងការពិនិត្យតាមដានហិរញ្ញវត្ថុ។ នាយ កដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការទទួលខុសត្រូវ ចំពោះការគ្រោង និងការ តាមដានត្រួតពិនិត្យគុណភាពនិងប្រសិទ្ធភាពនៃការប្រើប្រាស់ថវិការបស់អនុកម្មវិធីនេះ។ មន្ទីរអប់រំ យុវជន និងកីឡាក ជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ពិនិត្យតាមដានការរីកចម្រើន ។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១. កម្មវិធីចរន្ត** | **3898.0** | **4030.2** | **4538.0** | **4996.3** | **5565.9** |
| ថវិកាដំណើរការសម្រាប់ សាលាគរុកោល្យ | 1704.5 | 1743.5 | 1963.2 | 2161.5 | 2407.9 |
| កម្មវិធីអភិវឌ្ឍសមត្ថភាពគ្រប់គ្រងអប់រំ | 496.7 | 414.3 | 466.0 | 513.1 | 571.6 |
| កម្មវិធីបន្តការអភិវឌ្ឍ/ វិក្រឹតការគ្រូបង្រៀន | 1552.4 | 1752.4 | 1973.6 | 2172.8 | 2420.5 |
| ការពិនិត្យតាមដាន និង ការវាយតម្លៃ | 144.4 | 120.0 | 135.2 | 148.9 | 165.9 |
| **២. កម្មវិធីមូលធន** | **3235.2** | **3200.0** | **3056.0** | **1600.0** | **0** |
| ១). កិច្ចសហប្រតិបត្តិការបច្ចេកទេស | 3235.2 | 3200.0 | 3056.0 | 1600.0 | 0 |
| **ធនធានសរុប** | **7133.2** | **7230.2** | **7594** | **6596.3** | **5565.9** |

## អនុកម្មវិធី ៥.៣ ៖ ការអភិវឌ្ឍសម្ភារៈ និងសៀវភៅសិក្សា

អង្គភាព ៖ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

### ១. វត្ថុបំណង

វត្ថុបំណងសំខាន់នៃកម្មវិធីនេះគឺ៖ ១) អភិវឌ្ឍកម្មវិធីសិក្សាឲ្យមានលក្ខណៈជាសកលស្របតាមការរីកចម្រើននៃវិស័យអប់រំក្នុងតំបន់និងពិភពលោក។ ២) ធានាការផ្តល់សៀវភៅសិក្សាឲ្យបានគ្រប់គ្រាន់ទូទាំងប្រទេស។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

. *គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

❖ កែលម្អគុណភាពនៃការបង្រៀន ការរៀន និងការស្រាវជ្រាវនៅគ្រប់កម្រិតទូទាំងប្រទេស ។

សកម្មភាពគោលនយោបាយ៖

- យន្តការផ្គត់ផ្គង់សៀវភៅសិក្សាគោល កែសម្រួលបាននៅឆ្នាំ ២០១០។
- ឯកសារគរុកោសល្យ បច្ចេកទេសបណ្ណាល័យ និងសម្ភារឧបទេស បានអភិវឌ្ឍ នៅឆ្នាំ ២០១១។

❖ អនុវត្តគោលនយោបាយកម្មវិធីសិក្សាថ្មីទាំងនៅបឋមសិក្សា និងនៅមធ្យមសិក្សាបឋមភូមិ ដោយផ្តោតការយកចិត្តទុកដាក់លើម៉ោងបង្រៀន។

សកម្មភាពគោលនយោបាយ ៖

- វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយកម្មវិធីសិក្សាថ្មី ពិនិត្យបាននៅឆ្នាំ ២០១១ ។
- គោលនយោបាយកម្មវិធីសិក្សាចំណេះទូទៅ កែលម្អបាននៅឆ្នាំ ២០១១។

❖ បង្កើតស្តង់ដានៃការសិក្សារបស់សិស្សនៅថ្នាក់ទី ៣ ទី ៦ និងទី ៩ ទូទាំងប្រទេស ។

សកម្មភាពគោលនយោបាយ ៖

- លទ្ធផលរបស់តេស្តស្តង់ដាប្រចាំឆ្នាំ ផ្សព្វផ្សាយជាសាធារណៈចាប់ពីឆ្នាំ ២០១០ តទៅ។

❖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវា អប់រំបច្ចេកទេសវិជ្ជាជីវៈ ការអប់រំបំណិនជីវិត និងការងារតម្រង់ទិសវិជ្ជាជីវៈ ។

សកម្មភាពគោលនយោបាយ ៖

- កម្មវិធីសិក្សាបណ្តុះបណ្តាលអប់រំបច្ចេកទេសវិជ្ជាជីវៈ អភិវឌ្ឍបាននៅឆ្នាំ ២០១០។

- សម្ភារៈរូបវន្តនិងបណ្តុះបណ្តាលធនធានមនុស្សជំនាញ លើការងារបណ្តុះបណ្តាលអប់រំបច្ចេកទេសវិជ្ជាជីវៈ កសាងបាននៅឆ្នាំ ២០១០។
- កញ្ចប់ថវិកាសម្រាប់ទ្រទ្រង់ដល់ដំណើរការកម្មវិធីជ្រើសរើសការអប់រំបច្ចេកទេសវិជ្ជាជីវៈ រៀបចំបាននៅឆ្នាំ ២០១០។

## ៣. សូចនាករ និងចំណុចដៅ

- ការអនុម័តប្រព័ន្ធថ្មីនៃការអភិវឌ្ឍសៀវភៅសិក្សាគោល បោះពុម្ព និងចែកផ្សាយ នៅត្រឹមឆ្នាំ ២០១៣ ។
- ផលធៀបសៀវភៅសិក្សា-សិស្ស ១:១ សម្រាប់ថ្នាក់ទី ១-៩ ។
- ផលធៀបសៀវភៅសិក្សា-សិស្ស ២:១ សម្រាប់ថ្នាក់ទី ១០-១២ នៅតំបន់ប្រជុំជន
- ផលធៀបសៀវភៅសិក្សា-សិស្ស ១:១ សម្រាប់ថ្នាក់ទី ១០-១២ សម្រាប់សាលារៀននៅតំបន់ជនបទ និង ខេត្តដាច់ស្រយាល ។

## ៤. កម្មវិធី និងសកម្មភាពចម្បង

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- ធានាការអនុម័តគោលនយោបាយសៀវភៅសិក្សាថ្មី និងការប្តេជ្ញាចិត្តរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការផ្តល់ហិរញ្ញប្បទានឲ្យបានទាន់ពេលវេលា ។
- អនុវត្តគោលនយោបាយសៀវភៅសិក្សាថ្មី នៅគ្រប់សាលាបឋមសិក្សា និងមធ្យមសិក្សា ។
- ផ្សព្វផ្សាយ និង អនុវត្តស្តង់ដាកម្មវិធីសិក្សា និងកម្មវិធីសិក្សាថ្មីសម្រាប់ការអប់រំចំណេះទូទៅ រួមបញ្ចូលទាំងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ។
- ពិនិត្យតាមដាន ការនិពន្ធ ការផ្សព្វផ្សាយ និងការនាំចូលសម្ភារសិក្សា សៀវភៅសិក្សា និងឯកសារពាក់ព័ន្ធការបង្រៀន និងរៀន។
- ពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សាគោល ការគ្រប់គ្រងបណ្ណាល័យ និងកម្មវិធីបំណិនជីវិត។
- លទ្ធកម្មសៀវភៅសិក្សាគោល។
- ពង្រឹងបណ្តាញបណ្ណាល័យទូទាំងប្រទេស តាមរយៈកម្មវិធីវិកិលនៃការបង្កើត និងពង្រឹងមជ្ឈមណ្ឌលឯកសារបែបវិមជ្ឈការ។ ការផ្តោតជាបឋមទៅលើការពង្រឹងមជ្ឈមណ្ឌលឯកសារនៅសាលាគរុកោសល្យនិងវាយតម្លៃសក្តានុពលសម្រាប់ពង្រីករហូតដល់សាលាមធ្យមសិក្សា។

### ៤.២ កម្មវិធីមូលធន

*កិច្ចសហប្រតិបត្តិការបច្ចេកទេស៖*

- សិក្សាស្រាវជ្រាវខ្លឹមសារកម្មវិធីជាតិ និងអន្តរជាតិ។
- កសាងសមត្ថភាពបុគ្គលិកមួយចំនួននៅថ្នាក់កណ្តាល ដើម្បីអនុវត្តគោលនយោបាយ ថ្មីស្តីពីការអភិវឌ្ឍសៀវភៅសិក្សា និងចាប់ផ្តើមអនុវត្តស្តង់ដាកម្មវិធីសិក្សា និងកម្មវិធីសិក្សាថ្មី សម្រាប់អប់រំចំណេះទូទៅ
- ពង្រឹងសមត្ថភាពពិនិត្យតាមដាននៅថ្នាក់កណ្តាល និងថ្នា ក់រាជធានី ខេត្ត ដើម្បីធានាថាការផ្តល់សៀវភៅសិក្សាទៅឲ្យក្រុង ស្រុក ខណ្ឌ និងសាលារៀន បានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព ។
- ពង្រឹងសមត្ថភាពគ្រប់គ្រង និងបច្ចេកទេសបណ្ណារក្សនៅមជ្ឈមណ្ឌលឯកសារ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និង វិក្រឹតការរាជធានី ខេត្ត ។

## ៥. ការគ្រប់គ្រងនិងពិនិត្យតាមដាន

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាត្រូវទទួលខុសត្រូវលើការអនុវត្ត និងការពិនិត្យតាមដានគោលនយោបាយសៀវភៅសិក្សា ស្តង់ដាកម្មវិធីសិក្សា បណ្តាញបណ្ណាល័យ និងគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ឆ្នាំ ២០០៩-២០១៤ ។ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តបន្តទទួលខុសត្រូវលើសកម្មភាពពិនិត្យតាមដានការរីកចម្រើនលើការផ្គត់ផ្គង់ និងបែងចែកសៀវភៅសិក្សាទៅសាលារៀន។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១- កម្មវិធីចរន្ត** | **14473.0** | **15782.7** | **17369.1** | **18903.2** | **20954.1** |
| ការផ្តល់សេវាដល់សាលាបឋម និងមធ្យមសិក្សា | 14473.0 | 14526.7 | 16357.1 | 18009.2 | 20062.1 |
| ការផ្សព្វផ្សាយគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា | 0 | 381 | 0 | 0 | 0 |
| បំណិនជីវិត | 0 | 140 | 0 | 0 | 0 |
| ស្តង់ដាកម្មវិធីសិក្សា(ថ្នាក់ទី៣ ទី៦ ទី៩ និងទី១២) | 0 | 317 | 0 | 0 | 0 |
| កម្មវិធីសិក្សាគោល /កម្មវិធីសិក្សាលំអិតភាសាអង់គ្លេស | 0 | 272 | 0 | 100 | 0 |
| ស្រាវជ្រាវ និងវាយតម្លៃ | 0 | 0 | 173 | 175 | 346 |
| ពិនិត្យតាមដាន | 0 | 146 | 419 | 419 | 346 |
| ការងារបណ្ណាល័យ | 0 | 0 | 320 | 100 | 100 |
| អភិវឌ្ឍកម្មវិធីអប់រំវិជ្ជាជីវៈជំរើស | 0 | 0 | 100 | 100 | 100 |
| **ធនធានសរុប** | **14473.0** | **15782.7** | **17369.1** | **18903.2** | **20954.1** |

## អនុកម្មវិធី ៥.៤ ៖ ការគ្រប់គ្រង និងពង្រឹងប្រសិទ្ធភាពធនធានមនុស្ស

អង្គភាព ៖ នាយកដ្ឋានបុគ្គលិក

### ១. វត្ថុបំណង

វត្ថុបំណងរបស់អនុកម្មវិធីនេះគឺ ១) កែលម្អប្រសិទ្ធភាពនិងសមធម៌ក្នុងការចាត់តាំងបុគ្គលិកបង្រៀននិងមិនបង្រៀនឲ្យឆ្លើយតបទៅនឹងការពង្រីកកាលានុវត្តភាពចូលរៀននៅបឋមសិក្សា និងមធ្យមសិក្សាជាពិសេសតំបន់ដាច់ស្រយាលនិងជួបការលំបាក និង តំបន់ពុំទាន់បានផ្តល់សេវាអប់រំគ្រប់គ្រាន់ ព្រមទាំងការចាត់តាំងគ្រូបង្រៀនឲ្យមានសមធម៌តាមមុខវិជ្ជាឯកទេសនីមួយៗ។ ២) ចូលរួមចំណែកកែលម្អគុណភាពអប់រំ តាមរយៈការជំនួសគ្រូចូលនិវត្តន៍ និងគ្រូជាប់កិច្ចសន្យាដោយ បុគ្គលិក និងគ្រូចេញថ្មីដែលមានគុណភាព។ ៣) លើកទឹកចិត្តមន្ត្រីអប់រំ ដើម្បីលើកកម្ពស់ឆន្ទៈបំពេញ ភារកិច្ចនៅតំបន់ដាច់ស្រយាលនិងជួបការលំបាក។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌*

❖ ធានាសនិទានកម្មបុគ្គលិកអប់រំសម្រាប់តំបន់ដាច់ស្រយាល និងជួបការលំបាក ។

សកម្មភាពគោលនយោបាយ ៖

- ការរីកចម្រើនរបស់យុទ្ធសាស្ត្រដាក់ពង្រាយបុគ្គលិក បានពិនិត្យឡើងវិញនៅឆ្នាំ ២០១០ ។
- និយាមស្តីពីការប្រើប្រាស់បុគ្គលិកអប់រំ ជាពិសេសសាលារៀនដែលលើសគ្រូ បានពិនិត្យឡើងវិញនៅឆ្នាំ ២០១១។
- យុទ្ធសាស្ត្រស្តីពីតម្រូវការនិងការផ្គត់ផ្គង់គ្រូបង្រៀន កែសម្រួលបាននៅឆ្នាំ ២០១១។

*គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

❖ បង្កើនរង្វាន់លើកទឹកចិត្ត និងប្រាក់លាភការជូនគ្រូបង្រៀន ផ្អែកលើលទ្ធផលបំពេញការងារ និងស្តង់ដា។

សកម្មភាពគោលនយោបាយ ៖

- ការគ្រប់គ្រងប្រតិបត្តិការការងារ (RBM) ដូចជាការវាយតម្លៃការបំពេញការងាររបស់ បុគ្គលិក រៀបចំបាននៅឆ្នាំ ២០១១។

*គោលនយោបាយទី៣ ៖ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

❖ ពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងបុគ្គលិក ប្រព័ន្ធ ព័ត៌មានគ្រប់គ្រងអប់រំ ប្រព័ន្ធព័ត៌មានគ្រប់គ្រងឧត្តមសិក្សា ប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ។

សកម្មភាពគោលនយោបាយ ៖

- ផែនការសកម្មភាពសម្រាប់ពិនិត្យឡើងវិញប្រព័ន្ធគ្រប់គ្រងព័ត៌មានបុគ្គលិក នៅគ្រប់កម្រិតថ្នាក់ រៀបចំបាននៅឆ្នាំ ២០១០។
- ការពណ៌នាមុខតំណែងនិងការពណ៌នាលក្ខណៈសម្បត្តិមុខតំណែងរបស់ក្រសួង បញ្ចប់បាននៅឆ្នាំ ២០១០។
- ផែនការអភិវឌ្ឍសមត្ថភាពរយៈពេលមធ្យមសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ទាំងមូល រៀបចំបាននៅត្រឹមឆ្នាំ ២០១១។

❖ កាត់បន្ថយវិសមភាពយេនឌ័រនៅក្នុងតំណែងអ្នកគ្រប់គ្រងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

សកម្មភាពគោលនយោបាយ ៖

- គោលការណ៍ក្នុងការតែងតាំងមន្ត្រីគ្រប់គ្រងដោយផ្តល់អាទិភាពដល់ស្ត្រី បានពិនិត្យឡើងវិញនៅឆ្នាំ ២០១១។

## ៣. សូចនាករ និងចំណុចដៅ

- គ្រូបង្រៀនដែលចេញថ្មីចំនួន ៩៥% នឹងត្រូវចាត់តាំងឲ្យទៅបម្រើការងារនៅសាលាខ្វះគ្រូ តំបន់ជួបការលំបាក និង តំបន់ដាច់ស្រយាលរៀងរាល់ឆ្នាំ ។
- គ្រូបង្រៀនថ្មីចំនួនពី ៤,៨០០ ទៅ ៥,០០០ នាក់ត្រូវបានជ្រើសរើសក្នុងមួយឆ្នាំ ។
- ចំនួនមន្ត្រីអប់រំជាស្ត្រីក្នុងតំណែងអ្នកគ្រប់គ្រង (ប្រធាន និងអនុប្រធាននាយកដ្ឋាន មន្ទីរនៅថ្នាក់រាជធានី ខេត្ត និងថ្នាក់កណ្តាល) កើនដល់ ១៥% នៅឆ្នាំ ២០១៣ និងក្នុងតំណែងខ្ពស់បំផុត (អគ្គនាយក អគ្គនាយករង និងខ្ពស់ជាងនេះ) កើនដល់ ១០% នៅឆ្នាំ ២០១៤។
- ផែនការរយៈពេលមធ្យមសម្រាប់ការអភិវឌ្ឍសមត្ថភាពត្រូវបានបង្កើតឡើងត្រឹមឆ្នាំ២០១០។

## ៤. សកម្មភាព និង កម្មវិធីចម្បងៗ

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- ផ្តល់ថវិកាឧបត្ថម្ភគ្រូបង្រៀននៅតំបន់ដាច់ស្រយាលនិងជួបការលំបាក។

- ផ្តល់ថវិកាឧបត្ថម្ភម្តងគត់ដល់បុគ្គលិកអប់រំដែលត្រូវពង្រាយពីសាលាលើសគ្រូ ទៅសាលាខ្វះគ្រូ។
- ពិនិត្យឡើងវិញ និងពិនិត្យតាមដានផែនការពង្រាយបុគ្គលិក ពិសេសនៅថ្នាក់រាជធានី ខេត្ត និងការពង្រាយគ្រូបង្រៀនចេញថ្មី ។

៤.២ កម្មវិធីមូលធន

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- ការកសាងផែនការប្រើប្រាស់បុគ្គលិក និង ការរៀបចំប្រព័ន្ធវាយតម្លៃស្របទៅនឹងផែនការការងារផ្អែកលើកម្រិតការទទួលខុសត្រូវ និងការបំពេញការងារ។
- ការរៀបចំការពណ៌នាមុខតំណែង និងការពណ៌នាលក្ខណ:សម្បត្តិមុខតំណែង។
- ការពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានបុគ្គលិក និងគាំទ្រដល់ដំណើរការប្រតិបត្តិរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។
- ការវាយតម្លៃផលប៉ះពាល់នៃយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពនៅការិយាល័យអប់រំ យុវជន និង កីឡាក្រុង ស្រុក ខណ្ឌ និងសាលារៀន។
- ការគាំទ្រផ្នែកបច្ចេកទេសដល់អាជ្ញាធរអប់រំថ្នាក់ក្រោមជាតិ។
- ការសិក្សាស្រាវជ្រាវលើនិយាមប្រើប្រាស់បុគ្គលិកបង្រៀន និងមិនបង្រៀននៅតាមគ្រឹះស្ថានសិក្សានានា ។
- ការកសាងសមត្ថភាពរយ:ពេលមធ្យមសម្រាប់បុគ្គលិកអប់រំ។

## ៥. ការគ្រប់គ្រងនិងពិនិត្យតាមដាន

នាយកដ្ឋានបុគ្គលិកទទួលខុសត្រូវក្នុងការពិនិត្យតាមដាន និងសម្របសម្រួលកម្មវិធីនិងគម្រោងទាំងអស់។ កម្មវិធីនេះ ត្រូវគ្រប់គ្រងដោយមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត និងឈានទៅផ្ទេរសិទ្ធិអំណាច និងការទទួលខុសត្រូវជា បណ្តើរៗឲ្យការិយាល័យអប់រំ យុវជន និង កីឡាក្រុង ស្រុក ខណ្ឌ ដោយផ្អែកតាមបទបញ្ញត្តិ និងនិយាមប្រើប្រាស់បុគ្គលិកដែលបានកំណត់ ដោយមានការពិនិត្យតាមដាន និងពិនិត្យឡើងវិញពីតួនាទីរបស់អង្គភាព/ស្ថាប័ន ដើម្បីបន្តអនុវត្តការគ្រប់គ្រងតាមបែបវិមជ្ឈការ ។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១. កម្មវិធីចរន្ត** | **16701.4** | **17954.0** | **20216.0** | **22258.0** | **24506.0** |
| កម្មវិធីគាំទ្រការងារគ្រប់គ្រង និងបច្ចេកទេស | 704.5 | 0 | 0 | 0 | 0 |
| កម្មវិធីគាំទ្រសម្រាប់ពង្រាយបុគ្គលិកឡើងវិញ និង ពង្រាយគ្រូបង្រៀនចេញថ្មី | 2011.4 | 368.0 | 414.4 | 456.2 | 508.2 |
| ប្រាក់រង្វាន់លើកទឹកចិត្តផ្អែកលើការបំពេញការងារ និងប្រាក់រង្វាន់ទៅ បម្រើការងារនៅតាមតំបន់ជួបការលំបាក និងដាច់ស្រយាល | 12886.5 | 15258.0 | 171780.5 | 18195.7 | 21072.1 |
| កម្មវិធីតម្រង់ទិស និងផ្គត់ផ្គង់សម្ភារៈសម្រាប់ការពិនិត្យតាមដាន | 1099.0 | 403.0 | 453.8 | 499.6 | 556.6 |
| **២. កម្មវិធីមូលធន** | **535544.0** | **486527.0** | **546920.0** | **576775.0** | **606630.0** |
| ការវិនិយោគ | 0 | 0 | 0 | 0 | 0 |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 535544.0 | 486527.0 | 546920.0 | 576775.0 | 606630.0 |
| **ធនធានសរុបៈ** | 552245.4 | 504481.0 | 567136.0 | 599033.0 | 631136.0 |

## អនុកម្មវិធី ៥.៥៖ ការអភិវឌ្ឍសមត្ថភាពការងារគ្រប់គ្រងផែនការហិរញ្ញវត្ថុនិងមូលដ្ឋានសម្ភារៈ

អង្គភាព ៖ នាយកដ្ឋានហិរញ្ញវត្ថុ

### ១. វត្ថុបំណង

ពង្រឹងការគ្រប់គ្រងនិងប្រើប្រាស់ថវិការបស់អង្គភាពថ្នាក់ជាតិ និងថ្នា ក់ក្រោមជាតិឲ្យមានតម្លាភាព គណនេយ្យភាព ភាពស័ក្តិសិទ្ធ និង ប្រសិទ្ធភាព ព្រមទាំងធ្វើរបាយការណ៍ចំណាយ និងការទូទាត់ថវិកាបានត្រឹមត្រូវនិងទាន់ពេលវេលា ស្របតាមកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

- ❖ បង្កើនគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈនិង ការទ ទួលខុសត្រូវរបស់គ្រឹះស្ថានសិក្សាក្នុងការប្រើប្រាស់ថវិកា និងការសម្រេចចិត្តលើកម្មវិធីនានា ។

សកម្មភាពគោលនយោបាយ ៖

- បទបញ្ញត្តិ និងគោលការណ៍ចំណាយថវិកា ស្តីពីការអនុវត្តថវិកាកម្មវិធី ដូចជាថវិកាដំណើរការសាលារៀន ការផ្តល់អាហារូបករណ៍ ការចំណាយលើបន្ទុកបុគ្គលិក និងប្រាក់ឧបត្ថម្ភ ផ្សេងៗឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត កែសម្រួលបានត្រឹមឆ្នាំ២០១៣។

*គ) គោលនយោបាយទី ៣ ៖ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

- ❖ កែលម្អមូលដ្ឋានសម្រាប់រៀបចំផែនការហិរញ្ញវត្ថុរយៈពេលមធ្យម និង ការគ្រប់គ្រងបែបវិមជ្ឈការព្រមទាំងកែលម្អប្រព័ន្ធច្បាប់ និងអភិបាលកិច្ចល្អ ។

សកម្មភាពគោលនយោបាយ ៖

- ការអនុវត្តផែនការសកម្មភាពស្តីពី កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា បានពិនិត្យនិងកែសម្រួលឡើងវិញនៅឆ្នាំ ២០១២។
- សេចក្តីណែនាំទាក់ទងនឹងការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដូចជា ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិប្រចាំឆ្នាំជាដើម រៀបចំបាននៅឆ្នាំ ២០១២។

- ❖ ធានាថាគ្រប់អង្គភាពនិងគ្រឹះស្ថានសិក្សាជាអង្គភាពប្រតិបត្តិ ប្រកបដោយប្រសិទ្ធភាពក្នុងការគ្រប់គ្រងនិងប្រើប្រាស់ថវិកា។

សកម្មភាពគោលនយោបាយ ៖

- សេចក្តីណែនាំលើការគ្រប់គ្រងនិងប្រើប្រាស់ថវិកា រៀបចំបានជារៀងរាល់ឆ្នាំ។

## ៣. សូចនាករ និង ចំណុចដៅ

- ភាគរយថវិកាកម្មវិធីប្រចាំឆ្នាំធៀបនឹងថវិកាសរុបក្នុងវិស័យអប់រំកើនពី ១៧% ក្នុងឆ្នាំ ២០០៩ ទៅដល់ ១៨% ក្នុងឆ្នាំ ២០១៣។
- ភាគរយនៃការចំណាយថវិកាកម្មវិធីប្រចាំឆ្នាំកើនពី ៩០% ក្នុងឆ្នាំ ២០០៩ ទៅដល់ ៩៥% ក្នុងឆ្នាំ ២០១៣។

## ៤. កម្មវិធី និងសកម្មភាពចម្បងៗ

### ៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- ពិនិត្យតាមដានពីការគ្រប់គ្រង និងប្រើប្រាស់ថវិកា ដោយពង្រឹងសមត្ថភាពដល់មន្ត្រីជំនាញ ដើម្បីឱ្យការគ្រប់គ្រងនិងប្រើប្រាស់ថវិកាមានប្រសិទ្ធភាពខ្ពស់។
- គាំទ្រកិច្ចដំណើរការអង្គភាព។
- ផ្គត់ផ្គង់ទព្វសម្ភារៈ បោះពុម្ព សាងសង់ ជួសជុល និងទិញទូដែក។

### ៤.២ កម្មវិធីមូលធន

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- ពង្រឹងសមត្ថភាពមន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ ដើម្បីពិនិត្យតាមដាន និង ធ្វើរបាយការណ៍ ស្តីពីការបញ្ចេញ និងលំហូរថវិការបស់ថវិកាកម្មវិធី ។
- ដំណើរការប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ។
- ពង្រឹងប្រព័ន្ធសន្តិសុខហិរញ្ញវត្ថុនៅគ្រប់កម្រិត ជាពិសេសនៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដែលរួមមានការប្រើប្រាស់ប្រព័ន្ធធនាគាររាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ ។
- ពង្រឹងសមត្ថភាពមន្ត្រីនៅតាមមន្ទីរអប់រំ យុវជន និង កីឡារាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ជាប្រចាំដល់អង្គភាពគ្រប់គ្រងថវិកា និងសាលារៀនដើម្បីធានាសកម្មភាពចំណាយ និងការធ្វើរបាយការណ៍ទាន់ពេលវេលា។
- បំប៉នមន្ត្រីពីការអភិវឌ្ឍប្រព័ន្ធគណនេយ្យ ឱ្យស្របគ្នាទៅនឹងបទដ្ឋានថ្មី ដែលកើតចេញពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

## ៥. ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

នាយកដ្ឋានហិរញ្ញវត្ថុទទួលខុសត្រូវលើការពិនិត្យតាមដានផ្នែកហិរញ្ញវត្ថុ និងការរៀបចំធ្វើផែនការ ដោយអនុវត្តការពិនិត្យតាមដាន និងសម្របសម្រួលក្រុមការងារគ្រប់គ្រងហិរញ្ញវត្ថុ។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១- កម្មវិធីចរន្ត** | **1838.6** | **4695.2** | **26434.0** | **29103.8** | **32411.6** |
| ការពិនិត្យតាមដានការអនុវត្តថវិកា | 1,290.4 | 1271.9 | 7160.8 | 7884.0 | 8782.8 |
| គាំទ្រកិច្ចដំណើរការអង្គភាព | 548.2 | 584.4 | 3290.2 | 3622.5 | 4025.4 |
| ទព្វសំភារៈ បោះពុម្ព សាងសង់ ជួសជុល និងទិញ ទូដែក | 0 | 2838.9 | 15983.0 | 17597.3 | 19603.4 |
| ធនធានសរុប | 1838.6 | 4695.2 | 26434.0 | 29103.8 | 32411.6 |

## អនុកម្មវិធី ៥.៦ ៖ ពង្រឹងការធ្វើសវនកម្មផ្ទៃក្នុង

អង្គភាព ៖ នាយកដ្ឋានសវនកម្មផ្ទៃក្នុង

### ១. វត្ថុបំណង

បង្កើនគុណភាពនិងប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងលើការគ្រប់គ្រង ការប្រព្រឹត្តតាមការណែនាំ និងការបំពេញការងាររបស់សវនដ្ឋាន។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី៣ ៖ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

❖ ពង្រឹងអភិបាលកិច្ចល្អលើការគ្រប់គ្រង ការប្រព្រឹត្តតាមការណែនាំ និងការបំពេញការងារ។

សកម្មភាពគោលនយោបាយ ៖

- នីតិវិធីក្នុងការធ្វើសវនកម្ម កែលម្អបាននៅឆ្នាំ ២០១១។
- ផែនការអភិវឌ្ឍសមត្ថភាពមន្ត្រីសវនកម្ម កសាងបាននៅឆ្នាំ ២០១១។
- នីតិវិធីក្នុងការបង្កើតមន្ត្រីបង្គោលទទួលបន្ទុកការងារព័ត៌មានសវនកម្ម នៅតាមរាជធានី ខេត្ត រៀបចំបាននៅឆ្នាំ ២០១៣។

### ៣. សូចនាករ និង ចំណុចដៅ

- អង្គភាពរដ្ឋបាលកណ្តាល ត្រូវបានធ្វើសវនកម្មកើនពី ២៣% នៅឆ្នាំ ២០១០ ទៅដល់ ៤២% នៅឆ្នាំ ២០១៣។
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ១០០% ត្រូវបានធ្វើសវនកម្មរៀងរាល់ឆ្នាំ ។
- ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌត្រូវបានធ្វើសវនកម្ម កើនពី ៣៣.៧% នៅឆ្នាំ ២០១០ ទៅដល់ ៧០% នៅឆ្នាំ ២០១៣។
- សាលារៀននិងគ្រឹះស្ថានសិក្សា សាធារណៈ ត្រូវបានធ្វើសវនកម្មកើនពី ៥.២% នៅឆ្នាំ ២០១០ ទៅដល់ ៨.៩% នៅឆ្នាំ ២០១៣។

### ៤. កម្មវិធី និង សកម្មភាពចម្បងៗ

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- បណ្តុះបណ្តាលមន្ត្រីបង្គោលអំពីនីតិវិធីសវនកម្មផ្ទៃក្នុង ដែលបាន កំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អាជ្ញាធរសវនកម្មជាតិ ។

- ប្រមូលព័ត៌មាន និង វិភាគលើស្ថានភាពរបស់សវនដ្ឋាន
- ប្រតិបត្តិការសវនកម្ម នៅតាមសវនដ្ឋានថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ
- រៀបចំរបាយការណ៍លទ្ធផលនិងការផ្តល់អនុសាសន៍ស្តីពីការធ្វើសវនកម្មផ្ទៃក្នុងនៅតាមសវនដ្ឋាន
- ពិនិត្យតាមដានការកែលម្អតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង និង អង្គភាពពាក់ព័ន្ធ។

៤.២ កម្មវិធីមូលធន

- បណ្តុះបណ្តាលដល់មន្ត្រីសវនកម្មអំពីនីតិវិធីសវនកម្មផ្ទៃក្នុង ដែលបាន កំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង អាជ្ញាធរសវនកម្មជាតិ ។
- រៀបចំចុះកម្មសិក្សាជាក់ស្តែងលើនីតិវិធីសវនកម្មផ្ទៃក្នុងតាមសវនដ្ឋាននៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិដែលស្ថិតក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ដោយពង្រីក វិសាលភាពសវនកម្មលើការគ្រប់គ្រង និង ប្រើប្រាស់ ថវិកាកម្មវិធី ថវិកាមិនមែ នកម្មវិធី និង ថវិកាដៃគូអភិវឌ្ឍ។
- ពិនិត្យ និងកែសម្រួលការងារផ្ទៃក្នុង នីតិវិធី គោលការណ៍ បទដ្ឋានច្បាប់នានាដែលពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានសវនកម្មផ្ទៃក្នុង។
- រៀបចំកម្មវិធីសាកល្បងអនុវត្តនីតិវិធីសវនកម្មផ្ទៃក្នុង និងប្រព័ន្ធគ្រប់គ្រងព័ត៌មាន សវនកម្មផ្ទៃក្នុង ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៥. ការពិនិត្យតាមដាន និង ការគ្រប់គ្រងកម្មវិធី

នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានរៀបចំផែនការការងារជាពីរសកម្មភាពធំៗ គឺ ១)-ការគាំទ្រកិច្ចដំណើរការសវនកម្មផ្ទៃក្នុង និង ២)-ប្រតិបត្តិការសវនកម្មផ្ទៃក្នុង ដោយផ្តោតលើការងារគ្រប់គ្រង (management) ការប្រព្រឹត្តតាមការណែនាំ (compliance) និងការបំពេញការងារ (performance) តាមដំណាក់កាលដូចខាងក្រោម៖

- ការរៀបចំប្រមូលព័ត៌មាន និង វិភាគលើស្ថានភាពរបស់សវនដ្ឋាន
- ការរៀបចំផែនការ និងប្រតិបត្តិការសវនកម្ម នៅតាមសវនដ្ឋានថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ
- ការរៀបចំរបាយការណ៍លទ្ធផលនិងការផ្តល់អនុសាសន៍ ស្តីពីការធ្វើសវនកម្មផ្ទៃក្នុងនៅតាមសវនដ្ឋាន

- ការពិនិត្យតាមដានការកែលម្អតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង និង អង្គភាពពាក់ព័ន្ធ។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១- កម្មវិធីចរន្ត** | **0** | **317.5** | **464.0** | **510.9** | **569.1** |
| គាំទ្រកិច្ចដំណើរការការងារសវនកម្ម | 0 | 0 | 142.5 | 156.9 | 174.8 |
| ពង្រឹងសមត្ថភាពមន្ត្រីជំនាញ | 0 | 317.5 | 321.5 | 354.0 | 394.3 |
| **ធនធានសរុប** | **0** | **317.5** | **464.0** | **510.9** | **569.1** |

## អនុកម្មវិធី ៥.៧ ៖ ការពិនិត្យតាមដាននិងវាយតម្លៃការបំពេញការងារវិស័យអប់រំថ្នាក់មូលដ្ឋាន

អង្គភាព ៖ នាយកដ្ឋានធានាគុណភាពអប់រំ

### ១. វត្ថុបំណង

វត្ថុបំណងរបស់អនុកម្មវិធីនេះគឺ ពង្រឹងការពិនិត្យតាមដាន វាយតម្លៃការបំពេញការងារតាមផ្នែក ដោយផ្អែកលើលទ្ធផល ដើម្បីធានាគុណភាពអប់រំ និងជំ រុញការបង្កើនគុណភាពអប់រំនៅតាមសាលារៀនទូទាំងប្រទេស។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

- បង្កើនតម្លាភាព និង កែ លម្អការពិនិត្យតាមដានការបំពេញការងារ និងការទទួលខុសត្រូវ របស់គ្រូបង្រៀន សាលារៀន និង គ្រឹះស្ថានឧត្តមសិក្សា ។

សកម្មភាពគោលនយោបាយ ៖

- ឯកសារសម្រាប់ការងារធានាគុណភាពអប់រំនៅតាមសាលារៀន កសាងបាននៅឆ្នាំ ២០១១។
- គោលនយោបាយនិងក្របខណ្ឌការងារធានាគុណភាពអប់រំ កសាងបាននៅឆ្នាំ ២០១២។
- លិខិតបទដ្ឋានស្តីពីការប្រែក្លាយការិយាល័យអធិការកិច្ចនៅតាមមន្ទីរអប់រំ យុវជន និង កីឡា រាជធានី ខេត្តទៅជាការិយាល័យធានាគុណភាពអប់រំ រៀបចំបាននៅឆ្នាំ ២០១២។
- គោលការណ៍យន្តការសម្រាប់វាស់ស្ទង់សមភាពកម្រិតសមមូល រៀបចំបាននៅឆ្នាំ ២០១២។
- ស្តង់ដាជាតិដើម្បីធានាគុណភាពអប់រំ កសាងរួចរាល់នៅឆ្នាំ ២០១៣។

### ៣. សូចនាករ និងចំណុចដៅ

- របាយការណ៍លទ្ធផលការពិនិត្យតាមដាន វាយតម្លៃ ការធានាគុណភាពអប់រំនៅតាមសាលារៀនត្រូវបានផ្សព្វផ្សាយរៀងរាល់ឆ្នាំ។
- រាជធានី ខេត្ត ៥០% សម្រេចបានគុណភាព និងប្រសិទ្ធភាពក្នុង ការបំពេញការងារវិស័យអប់រំលើគ្រប់ផ្នែកនៅឆ្នាំ ២០១៣។

### ៤. សកម្មភាព និងកម្មវិធីចម្បង ៗ

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- ការផ្លាស់ប្តូរបទពិសោធន៍លើការអនុវត្ត និងបង្កើនគុណភាពអប់រំនៅតាមសាលារៀន
- ការពង្រឹងសមត្ថភាព ស្តីពីការធានាគុណភាពអប់រំនៅថ្នាក់ជាតិ និងក្រោមជាតិ

- ការចុះអង្កេតនិងធ្វើអធិការកិច្ចលើការងារធានាគុណភាពអប់រំនៅគ្រប់លំដាប់ថ្នាក់។

## ៥. ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

នាយកដ្ឋានធានាគុណភាពអប់រំ គឺជាអង្គភាពគ្រប់គ្រងថវិការបស់កម្មវិធីនេះ។ នៅជំហានបន្ទាប់ កញ្ចប់ថវិកានឹងត្រូវចែករំលែកទៅដល់ថ្នាក់ក្រោមជាតិ។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១. កម្មវិធីចរន្ត** | **157.0** | **220.2** | **247.9** | **593.5** | **677.8** |
| ការពង្រឹងសមត្ថភាពប្រព័ន្ធពិនិត្យតាមដាន | 76.5 | 69.9 | 78.7 | 156.8 | 179.0 |
| ការពិនិត្យតាមដាន ការបំពេញការងារតាមផ្នែក ដោយផ្តោតលើលទ្ធផល | 80.5 | 150.3 | 169.2 | 436.7 | 498.8 |
| ធនធានសរុប | 157.0 | 220.2 | 247.9 | 593.5 | 677.8 |

## អនុកម្មវិធី ៥.៨ ៖ អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ

អង្គភាព ៖ អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

### ១. វត្ថុបំណង

វត្ថុបំណងរបស់អនុកម្មវិធីនេះគឺ ពង្រឹងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនិងហិរញ្ញវត្ថុនៅអង្គភាពរដ្ឋបាល និងគ្រឹះស្ថានសិក្សាទាំងអស់ ឱ្យមានការទទួលខុសត្រូវនិងតម្លាភាព ។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី៣ ៖ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

❖ ពង្រឹងអភិបាលកិច្ចល្អ លើការគ្រប់គ្រង ការប្រព្រឹត្តតាមការណែនាំ និងការបំពេញការងារ។

សកម្មភាពគោលនយោបាយ ៖

- កម្មវិធីអធិការកិច្ច និងកម្មវិធីពិនិត្យឡើងវិញលើការកែលម្អ បានធ្វើបច្ចុប្បន្នភាពនៅឆ្នាំ ២០១០ និង ២០១៣។

### ៣. សូចនាករ និងចំណុចដៅ

- របាយការណ៍លទ្ធផលអធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវបានផ្សព្វផ្សាយជារៀងរាល់ឆ្នាំ ។
- អង្គភាពចំនួន ៣៧០ បានធ្វើការកែលម្អតាមអនុសាសន៍បានល្អ។
- អង្គភាព ១,៥៤៧ ត្រូវបានធ្វើអធិការកិច្ច ។

### ៤. សកម្មភាព និងកម្មវិធីចម្បង

៤.១ កម្មវិធីចរន្ត(ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- អធិការកិច្ច និងពិនិត្យឡើងវិញលើការកែលម្អតាមអនុសាសន៍។
- ពង្រឹងសមត្ថភាពដល់មន្ត្រីគ្រប់គ្រងដែលរងអធិការកិច្ច។

៤.២ កម្មវិធីមូលធន

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- អង្កេត និងវាយតម្លៃលទ្ធផលការអនុវត្តកម្មវិធីអធិការកិច្ច។

### ៥. ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

អធិការដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ទទួលខុសត្រូវលើការធ្វើអធិការកិច្ចលើដំណើរការនៃការ

គ្រប់គ្រងបុគ្គលិក រដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋនៅតាមអង្គភាព និងគ្រឹះស្ថា នសិក្សាសាធារណៈ និងឯកជន។ ត្រួតពិនិត្យ និងលើកសំណើដោះស្រាយករណីទាំងឡាយពាក់ព័ន្ធទៅនឹងការងាររដ្ឋបាល និង ហិរញ្ញវត្ថុ។ ក្រសួងអប់រំ យុវជន និងកីឡាបែងចែកមូលនិធិសម្រាប់ដំណើរការអធិការកិច្ច តាមរយៈអនុកម្មវិធីរបស់អធិការដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។ របាយការណ៍អធិការកិច្ចនឹងត្រូវប្ញូកសរុបជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងផ្នែកពាក់ព័ន្ធដែលជាមូលដ្ឋានសម្រាប់ធ្វើសកម្មភាព ។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១. កម្មវិធីចរន្ត** | **157.0** | **169.0** | **202.1** | **222.3** | **244.5** |
| ១. ពង្រឹងសមត្ថភាព | 38.8 | 25.2 | 30.0 | 33.0 | 36.3 |
| ២. ពិនិត្យតាមដាន | 118.2 | 143.3 | 172.1 | 189.3 | 208.2 |
| **២. កម្មវិធីមូលធន** | 0 | **0** | **0** | **100** | **0** |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 0 | 0 | 0 | 100 | 0 |
| **ធនធានសរុប** | **157** | **169** | **202.1** | **322.3** | **244.5** |

## អនុកម្មវិធី ៥.៩ ៖ ការអភិវឌ្ឍការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍

អង្គភាព ៖ នាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន

### ១. វត្ថុបំណង

វត្ថុបំណងរបស់អនុកម្មវិធីនេះគឺ ធានាថាបច្ចេកវិទ្យាដែលក្រសួងទទួលយកទៅប្រើប្រាស់ ឬអភិវឌ្ឍសមស្របនឹងតម្រូវការសម្រាប់ទំនើបកម្មរដ្ឋបាល និង អាចបត់បែនបានដើម្បីសម្របតាមគោលនយោបាយវិមជ្ឈការ ។ ជំរុញ និងតាមដានត្រួតពិនិត្យស្តង់ដាភាវូបនីយកម្មទ្រង់ទ្រាយទិន្នន័យ និងឧបករណ៍កុំព្យូទ័រទូទាំងក្រសួង ។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី៣ ៖ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

- កែលម្អការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់ទំនើបកម្ម និង វិមជ្ឈការនៃប្រព័ន្ធរដ្ឋបាល និងត្រួតពិនិត្យ ដែលអាចឈានទៅដល់កម្រិតសាលារៀន ។

សកម្មភាពគោលនយោបាយ ៖

- សុវត្ថិភាព ស្ថិរភាព និងស្តង់ដាភាវូបនីយកម្មក្នុងទំនើបកម្មនិងសមាហរណកម្មរចនាសម្ព័ន្ធការគ្រប់គ្រងទិន្នន័យសម្រាប់ EMIS HRMIS និង FMIS ក៏ដូចជា ប្រព័ន្ធ ព័ត៌មានរបស់ក្រសួងធានាបាននៅត្រឹមឆ្នាំ ២០១០ ។
- ការគ្រប់គ្រងសាលារៀនផ្អែកលើកុំព្យូទ័រ ធានាប្រតិបត្តិការបាននៅត្រឹមឆ្នាំ ២០១០ ។
- ស្តង់ដាភាវូបនីយកម្ម និងទំនាក់ទំនងជាអេឡិចត្រូនិកក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡាទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និង សាលារៀន ពង្រឹងបានត្រឹមឆ្នាំ ២០១១ ។

### ៣. សូចនាករ និង ចំណុចដៅ

- គ្រប់អង្គភាពថ្នាក់កណ្តាល មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌទំនាក់ទំនងគ្នាបានតាមមធ្យោបាយអេឡិចត្រូនិក នៅត្រឹមឆ្នាំ ២០១១
- មូលដ្ឋានទិន្នន័យថ្មីសម្រាប់ EMIS, HRMIS and FMIS ត្រូវបានតភ្ជាប់ និង ចាត់ទុកជាស្តង់ដាមានសុវត្ថិភាព និងស្ថិរភាព នៅពាក់កណ្តាល ឆ្នាំ ២០១១ ។
- កម្មវិធីកុំព្យូទ័រសម្រាប់គ្រប់គ្រងដែលបានសាកល្បងបានត្រឹមត្រូវ និង សម្របតាមតម្រូវការសាលានៅកម្ពុជា ប្រើប្រាស់បាន នៅឆ្នាំ ២០១០ ។

- គ្រប់នាយកដ្ឋាន មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ សាលារៀន និងថ្នាក់ឧត្តមសិក្សាប្រើប្រាស់កម្មវិធីខ្មែរយូនីកូដ Open Document Format (ODF) and Portable Document Format (PDF) នៅចុងឆ្នាំ ២០១០ ។

## ៤. សកម្មភាព និង កម្មវិធីចម្បង

៤.១ កម្មវិធីចរន្ត(ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- បណ្តុះបណ្តាលដល់បុគ្គលិកនៅថ្នាក់ក្រសួង ថ្នា ក់ខេត្ត និង ថ្នាក់ស្រុក ស្តីពីការប្រើប្រាស់កម្មវិធីគ្រប់គ្រងសាលា និងកម្មវិធីផលិតភាព ដែលបានបង្កើតឡើងដោយក្រសួង

៤.២ កម្មវិធីមូលធន

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- ការអភិវឌ្ឍយុទ្ធសាស្ត្រគ្រប់គ្រងព័ត៌មាន
- ត្រួតពិនិត្យដំណើរការទំនើបកម្មការគ្រប់គ្រងទិន្នន័យ ដែល ធានាថាបញ្ហាបច្ចេកទេសសម្រាប់សុវត្ថិភាព ស្តង់ដាភាពរូបនីយកម្ម និងវិមជ្ឈការត្រូវបានរួមបញ្ចូល ។
- ការរៀបចំ និងសាកល្បងការគ្រប់គ្រងសាលារៀនដោយប្រើកម្មវិធីកុំព្យូទ័រស្វ័យប្រវត្តិកម្ម និងការផ្លាស់ប្តូរទិន្នន័យរវាងសាលារៀន និងមូលដ្ឋានទិន្នន័យក្រសួង ។

## ៥. ពិនិត្យតាមដាន និង ការគ្រប់គ្រងកម្មវិធី

នាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន ទទួលខុសត្រូវលើការរៀបចំ និង តាមដានរាល់សកម្មភាពទាំងអស់នេះ ក៏ដូចជាសម្របសម្រួលជាមួយដៃគូដែលធ្វើការអភិវឌ្ឍ ។ ការវាយតម្លៃលើការអនុវត្តនឹងធ្វើឡើងនៅក្នុងវិស័យនេះ ដោយ ធ្វើតាមការចង្អុលបង្ហាញរបស់ផែនការគោល និងផែនការសកម្មភាព សម្រាប់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១. កម្មវិធីចរន្ត** | **0** | **118.3** | **144.4** | **157.7** | **150.0** |
| បំប៉នសមត្ថភាពមន្ត្រីក្រសួង | 0 | 118.3 | 144.4 | 157.7 | 150.0 |
| **២. កម្មវិធីមូលធន** | **0** | **909.6** | **932.0** | **1122.1** | **669.7** |
| ការវិនិយោគ | 0 | 770.0 | 790.4 | 972.0 | 531.6 |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 0 | 139.6 | 142.6 | 150.1 | 138.1 |
| ធនធានសរុប | 0 | 1027.9 | 1077.4 | 1279.8 | 819.7 |

## អនុកម្មវិធី ៥.១០ ៖ ការពង្រឹងការងារនីតិកម្មសម្រាប់វិស័យអប់រំ

អង្គភាព ៖ នាយកដ្ឋាននីតិកម្ម

### ១. វត្ថុបំណង

វត្ថុបំណងនៃអនុកម្មវិធីនេះគឺ រៀបចំក្រប ខណ្ឌច្បាប់ បទបញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តិនានាសម្រាប់អនុវត្តក្នុងវិស័យអប់រំ។ វត្ថុបំណងមួយទៀតគឺ ពង្រឹងអភិបាលកិច្ចល្អ ។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី៣ ៖ ការអភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

- ❖ លិខិតបទដ្ឋានគតិយុត្តច្បាស់លាស់លើគ្រប់វិស័យ និង អនុវិស័យអប់រំទាំងអស់ ស្របតាមច្បាប់ស្តីពីការអប់រំ រៀបចំបាននៅត្រឹមឆ្នាំ ២០១៣។

សកម្មភាពគោលនយោបាយ

- វិធាននិងលក្ខខណ្ឌតម្រូវស្របនឹងច្បាប់ស្តីពីការអប់រំ រៀបចំបានជារៀងរាល់ឆ្នាំ ។

- ❖ ពង្រឹងការផ្តល់សេវាសាធារណៈសម្រាប់វិស័យអប់រំ។

សកម្មភាពគោលនយោបាយ

- លិខិតបទដ្ឋានគតិយុត្តដើម្បីធានាការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ រៀបចំបានជារៀងរាល់ឆ្នាំ ។
- កម្រងព័ត៌មានសេវាសាធារណៈពាក់ព័ន្ធនឹងវិស័យអប់រំ កែលម្អបានជារៀងរាល់ឆ្នាំ។
- ផែនការកែលម្អការផ្តល់សេវាសាធារណៈសម្រាប់វិស័យអប់រំ កសាងបានរៀងរាល់បីឆ្នាំ។
- រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចតាមកម្រិតថ្នាក់រដ្ឋបាល ស្របតាមការងារវិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំ រៀបចំបាននៅឆ្នាំ ២០១៣។
- ក្របខណ្ឌច្បាប់និងបទបញ្ញត្តិសម្រាប់ការគ្រប់គ្រងធនធានមនុស្សបែបវិមជ្ឈការ រៀបចំបាននៅឆ្នាំ ២០១៣។
- ផែនការសកម្មភាពស្តីពីការផ្ទេរមុខងារ ធនធានមនុស្ស និងហិរញ្ញវត្ថុ ទៅថ្នាក់ក្រោមជាតិ កែលម្អបាននៅឆ្នាំ ២០១៣។

## ៣. សូចនាករ និងចំណុចដៅ

- លិខិតបទដ្ឋានគតិយុត្តចំនួន ២៩ ត្រូវបានរៀបចំ និងផ្សព្វផ្សាយ ត្រឹម២០១៣ ។

## ៤. សកម្មភាព និងកម្មវិធីចម្បងៗ

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- ការអភិវឌ្ឍ និងផ្សព្វផ្សាយឯកសារស្តីពី ការពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈក្នុងវិស័យអបរំ ឯកសារស្តីពី នីតិវិធីនៃការស្នើ ឫការតវ៉ា និងនីតិវិធីនៃដំណោះស្រាយសៀវភៅលិខិតបទដ្ឋានគតិយុត្តសម្រាប់វិស័យអប់រំ និងឯកសារស្តីពី ក្របខណ្ឌច្បាប់ ការការពារ និងប្រឆាំងការជួញដូរ និងការរត់ពន្ធមនុស្ស ។
- ពង្រឹងសមត្ថភាពមន្ត្រីអប់រំ អំពីគោលការណ៍ណែនាំ និងការពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ និងផ្សព្វផ្សាយអំពីការងារប្រឆាំងអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មលើមនុស្ស ពិសេសស្ត្រី និងកុមារ ។
- ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធី ការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់វិស័យអប់រំ និងការងារប្រឆាំងអំពើជួញដូរ ការរត់ពន្ធ និងធ្វើអាជីវកម្មពលកម្មលើមនុស្ស ពិសេសស្ត្រី និងកុមារ ។

៤.២ កម្មវិធីមូលធន

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- ផ្សព្វផ្សាយលិខិបទដ្ឋានគតិយុត្តសម្រាប់វិស័យអប់រំដល់បុគ្គលិកអប់រំ
- អភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំលើការតាក់តែងលិខិតបទដ្ឋានគតិយុត្ត
- ការពិនិត្យតាមដានការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងការកសាងប្រព័ន្ធទិន្នន័យគតិយុត្ត
- ការស្ទាបស្ទង់មតិ ប្រមូលព័ត៌មាន រៀបចំ និងផ្សព្វផ្សាយ លិខិតបទដ្ឋានគតិយុត្ត ស្តីពីការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិ
- អភិវឌ្ឍសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំអំពី គោលការណ៍វិមជ្ឈការនិងវិសហមជ្ឈការវិស័យអប់រំ
- សិក្សាមុខងារ ការស្ទាបស្ទង់មតិ ប្រមូលព័ត៌មាន ផ្សព្វផ្សាយ និង រៀបចំការផ្ទេរមុខងារដល់ថ្នាក់ក្រោមជាតិ
- សិក្សាអំពីតម្រូវការហិរញ្ញវត្ថុនិងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ សម្រាប់អនុវត្ត មុខងារដែលត្រូវផ្ទេរជូន។
- ពង្រឹងសមត្ថភាពក្រុមការងារវិមជ្ឈការនិងវិសហមជ្ឈការវិស័យអប់រំក្នុងការគ្រប់គ្រងកម្មវិធីជាតិ

- ពិនិត្យតាមដានរាល់ករណីវិវាទបុគ្គលិកអប់រំ
- ផ្សព្វផ្សាយសៀវភៅស្តីពី នីតិវិធីនៃការស្នើ ការតវ៉ា និងនីតិវិធីនៃ ដំណោះស្រាយដល់មន្ត្រីគ្រប់គ្រងអប់រំ។

## ៥. ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

នាយកដ្ឋាននីតិកម្មទទួលខុសត្រូវលើអនុកម្មវិធីនេះ តាមរយៈការបង្កើតក្រុមការងារគ្រប់គ្រងថវិកានិងគ្រប់គ្រងគម្រោងក្នុងនាយកដ្ឋាន ដើម្បីធានាឲ្យការពិនិត្យតាមដានមានតម្លាភាព និងប្រសិទ្ធភាពខ្ពស់។ ការពិនិត្យតាមដានកម្មវិធី ក៏មានកិច្ច សហប្រតិបត្តិការជាមួយស្ថាប័នដែលពាក់ព័ន្ធការងារនីតិកម្មនានា ទាំងផ្នែកបច្ចេកទេស និង ថវិកា ដើម្បីរួមចំណែកអភិវឌ្ឍការងារនីតិកម្មគ្រប់ប្រភេទ និង គ្រប់លំដាប់ថ្នាក់។ រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពសម្រាប់ដំណើរការគម្រោង។ ការប្រើប្រាស់ថវិកាកម្មវិធី នឹងត្រូវអនុវត្តស្របតាមគោលការណ៍ណែនាំ និងនិតិវិធីរបស់រាជរដ្ឋាភិបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការប្រើប្រាស់ថវិការបស់ដៃគូអភិវឌ្ឍ ត្រូវអនុវត្តស្របតាមនិតិវិធីហិរញ្ញវត្ថុដាច់ដោយឡែក ដោយមានការឯកភាពរួមគ្នារវាងក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១. កម្មវិធីចរន្ត** | **0** | **0** | **512.2** | **673.7** | **761.7** |
| ការអភិវឌ្ឍ និងផ្សព្វផ្សាយឯកសារ | 0 | 0 | 36.2 | 59.8 | 77.8 |
| ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំ | 0 | 0 | 363.8 | 491.7 | 564.7 |
| ពិនិត្យដាន និងវាយតម្លៃ | 0 | 0 | 112.2 | 122.2 | 119.2 |
| **២. កម្មវិធីមូលធន** | **0** | **677.14** | **1105.1** | **1105.1** | **1317.5** |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 0 | 677.14 | 1105.1 | 1105.1 | 1317.5 |
| **ធនធានសរុប** | **0** | **677.14** | **1617.3** | **1778.8** | **2079.2** |

## អនុកម្មវិធី ៥.១១ ៖ ការពង្រីកការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ

អង្គភាព ៖ នាយកដ្ឋានសំណង់

### ១. វត្ថុបំណង

វត្ថុបំណងនៃអនុកម្មវិធីនេះគឺ អភិវឌ្ឍការគ្រប់គ្រងការងារសាងសង់តាមលំដាប់ថ្នាក់ ភូមិ ឃុំ ស្រុក តាមបណ្តាអង្គភាព រាជធានី ខេត្ត និងសិក្សាពីតម្រូវការ អគារសិក្សាចាំបាច់ពាក់ព័ន្ធទៅនឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្តប្រកបដោយតម្លាភាព។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី៣ ៖ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

❖ បង្កើនគុណភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ ។

សកម្មភាពគោលនយោបាយ

- ប្រព័ន្ធគ្រប់គ្រងព័ត៌មានអំពី តម្រូវការសាងសង់និង ជួសជុលនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិកសាងបាននៅឆ្នាំ ២០១១។
- ផែនការមេសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធអប់រំរយៈពេលមធ្យម កសាងបាននៅឆ្នាំ ២០១១។
- ផែនការការពារគ្រោះមហន្តរាយនានា(ខ្យល់ព្យុះ ទឹកជំនន់...) កសាងបាននៅឆ្នាំ ២០១១។
- ប្រព័ន្ធតាមដាននិងវាយតម្លៃគុណភាពសំណង់ រៀបចំបាននៅឆ្នាំ ២០១២។

### ៣. សូចនាករ និងចំណុចដៅ

- ប្រព័ន្ធគ្រប់គ្រងព័ត៌មានអំពីតម្រូវការសាងសង់ ជួសជុលហេដ្ឋារចនាសម្ព័ន្ធអប់រំ និងប្រព័ន្ធតាមដានវាយតម្លៃគុណភាពសំណង់ ចាប់ដំណើរការនៅឆ្នាំ ២០១៣ ។
- ក្រសួងនឹងមានទិន្នន័យគ្រប់គ្រាន់ មានប្លង់មេសម្រាប់សំណង់អគាររដ្ឋបាលកណ្តាល និងរាជធានី ខេត្ត ស្រុក ចាប់ដំណើរការនៅឆ្នាំ ២០១៣។

### ៤. សកម្មភាព និងកម្មវិធីចម្បងៗ

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- ប្រមូលផ្តុំទិន្នន័យ រៀបចំគំនូសប្លង់ និងសិក្សាពីតម្រូវការអគារ ពាក់ព័ន្ធទៅនឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- អភិវឌ្ឍសមត្ថភាព និងកិច្ចដំណើរការអង្គភាព

- បំប៉នសមត្ថភាពលើការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំដល់មន្ត្រីជំនាញថ្នាក់រាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ នាយកសាលារៀន និងសហគមន៍
- ទព្វសម្ភារសម្រាប់ដំណើរការអង្គភាព
- ការពិនិត្យតាមដាន និងសិក្សាគម្រោង
- ចុះពិនិត្យនិងសិក្សាគម្រោងសាងសង់ គម្រោងជួសជុល នៅតាមរដ្ឋ បាលកណ្តាល និងរាជធានី ខេត្ត
- ពិនិត្យតាមដានការងារគ្រប់គ្រង ថែទាំហេដ្ឋារចនាសម្ព័ន្ធអប់រំនៅតាមរដ្ឋបាលកណ្តាល និង រាជធានី ខេត្ត។

## ៤.២ កម្មវិធីមូលធន

*ការវិនិយោគ ៖*

- បង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងប្រព័ន្ធពិនិត្យតាមដាន វាយតម្លៃគុណភាពសំណង់។

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- បំប៉នមន្ត្រីជំនាញសម្រាប់គ្រប់គ្រងប្រព័ន្ធព័ត៌មានដល់ថ្នាក់រដ្ឋបាលកណ្តាល ថ្នាក់រាជធានី ខេត្ត ស្រុក ខណ្ឌសម្រាប់រៀបចំផែនការសាងសង់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធអប់រំ។

តារាងទី ៥ ៖ ការងារសាងសង់អគាររដ្ឋបាល និងអគារសិក្សាពីឆ្នាំ ២០១១ ដល់ ២០១៣

| សកម្មភាព | ចំនួន | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|
| មត្តេយ្យសិក្សាធនធាន | 185 | 60 | 60 | 65 |
| សាលាបឋមសិក្សា | 600 | 200 | 200 | 200 |
| មណ្ឌលសិក្សាសហគមន៍ | 150 | 50 | 50 | 50 |
| សាលាអនុវិទ្យាល័យ (ឃុំ) | 186 | 62 | 62 | 62 |
| សាលាវិទ្យាល័យ (ស្រុក) | 14 | 5 | 5 | 4 |
| ទីលានកីឡាអនុ និងវិទ្យាល័យ | 240 | 80 | 80 | 80 |
| ផ្ទះគ្រូស្នាក់នៅ | 480 | 160 | 160 | 160 |
| សាលាវិទ្យាល័យធនធាន | 48 | 16 | 16 | 16 |
| អន្តេវាសិកដ្ឋាន | 72 | 24 | 24 | 24 |
| ជួសជុលនិងថែទាំមណ្ឌលកីឡា | 24 | 8 | 8 | 8 |
| អគារសាលប្រជុំយុវជន | 24 | 8 | 8 | 8 |
| **សរុប** | **2023** | **673** | **673** | **677** |

## ៥. ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

ថវិកាចរន្តត្រូវគ្រប់គ្រងដោយនាយកដ្ឋានសំណង់ផ្ទាល់នៅឆ្នាំ ២០១១ និងឆ្នាំ ២០១២។ នៅឆ្នាំ ២០១៣ ថវិកាពិនិត្យតាមដាន ៦០% ត្រូវផ្ទេរជូនរាជធានី ខេត្តជាអ្នកគ្រប់គ្រង។ ចំពោះថវិកាមូលធន ត្រូវគ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡា។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១. កម្មវិធីចរន្ត** | **0** | **0** | **442** | **827** | **1064** |
| ការអភិវឌ្ឍ និងកិច្ចដំណើរការអង្គភាព | 0 | 0 | 294 | 383 | 472 |
| ពិនិត្យដាន និងសិក្សាគម្រោង | 0 | 0 | 148 | 444 | 592 |
| **២. កម្មវិធីមូលធន** | **0** | **0** | **353406** | **353406** | **355431** |
| ការវិនិយោគ | 0 | 0 | 287073 | 286957 | 288564 |
| *- ការសាងសង់* | *0* | *0* | *287033* | *286957* | *288564* |
| *- ការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មាន* | *0* | *0* | *40* | *0* | *0* |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 0 | 0 | 66333 | 66449 | 66867 |
| ធនធានសរុប | 0 | 0 | 353848 | 354233 | 356495 |

## អនុកម្មវិធី ៥.១២ ៖ ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

អង្គភាព ៖ នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ

### ១. វត្ថុបំណង

វត្ថុបំណងរបស់អនុកម្មវិធីនេះគឺ ពង្រឹងការគ្រប់គ្រងសម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និង គ្រឹះស្ថានអប់រំឱ្យមានតម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាព និងធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋបានត្រឹមត្រូវ និងទាន់ពេលវេលា។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី៣ ៖ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

❖ ពង្រឹងប្រព័ន្ធពិនិត្យតាមដានការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

សកម្មភាពគោលនយោបាយ៖

- ផែនការបង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ រៀបចំបាននៅឆ្នាំ ២០១១។

### ៣. សូចនាករ និង ចំណុចដៅ

- អង្គភាព និងមន្ទីរ អប់រំមានបញ្ជីគ្រប់គ្រប់ទ្រព្យសម្បត្តិរដ្ឋត្រឹមត្រូវពី ៥០% នៅឆ្នាំ ២០០៩ ទៅ ១០០% នៅឆ្នាំ ២០១៣។
- ប្រព័ន្ធព័ត៌មានគ្រប់គ្រងទិន្នន័យទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងអប់រំ យុវជន និងកីឡាចាប់ដំណើរការនៅឆ្នាំ ២០១៣។

### ៤. សកម្មភាព និង កម្មវិធីចម្បង

៤.១ កម្មវិធីចរន្ត(ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

*ការអភិវឌ្ឍសមត្ថភាព និងកិច្ចដំណើរការអង្គភាព ៖*

- បំប៉នមន្ត្រី នៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ទិញសម្ភារបរិក្ខារសម្រាប់ដំណើរការអង្គភាព

*ពិនិត្យតាមដាន ៖*

- ផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌ ទិន្នន័យអចលនទ្រព្យ និងពិនិត្យតាមដានការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅតាមគ្រឹះស្ថានសិក្សា

៤.២ កម្មវិធីមូលធន

*ការវិនិយោគ ៖*

- កសាងប្រព័ន្ធព័ត៌មានគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ។
- បំប៉នបុគ្គលិកជំនាញគ្រប់គ្រងសម្ភារ និង ទ្រព្យសម្បត្តិរដ្ឋស្តី ពីការប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ

## ៥. ពិនិត្យតាមដាន និង ការគ្រប់គ្រងកម្មវិធី

ថវិកាត្រូវគ្រប់គ្រងដោយផ្ទាល់ដោយនាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋនៅឆ្នាំ ២០១១ និង ២០១២។ ដោយឡែក នៅឆ្នាំ ២០១៣ ៧០ ភាគរយនៃថវិកាសម្រាប់ពិនិត្យតាមដានការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅតាមសាលារៀនត្រូវផ្ទេរជូនថ្នាក់រាជធានី ខេត្ត ។

## ៦. ផែនការហិរញ្ញវត្ថុ (គិតជាលានរៀល)

| សកម្មភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **១. កម្មវិធីចរន្ត** | **0** | **0** | **346.0** | **382.0** | **420.0** |
| ការអភិវឌ្ឍសមត្ថភាព និងកិច្ចដំណើរការអង្គភាព | 0 | 0 | 287.0 | 301.0 | 317.0 |
| ការពិនិត្យតាមដាន | 0 | 0 | 59.0 | 81.0 | 103.0 |
| **២. កម្មវិធីមូលធន** | **0** | **0** | **1 948.4** | **841.6** | **722.0** |
| ការវិនិយោគ | 0 | 0 | 576.4 | 109.6 | 0.0 |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 0 | 0 | 1372 | 732.0 | 722.0 |
| ធនធានសរុប | 0 | 0 | 2 294.4 | 1 223.6 | 1 142.0 |

## អនុកម្មវិធី ៥.១៣ ៖ ការអភិវឌ្ឍ និងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រងរដ្ឋបាលអប់រំ

អង្គភាព ៖ នាយកដ្ឋានរដ្ឋបាល

### ១. វត្ថុបំណង

វត្ថុបំណងនៃអនុកម្មវិធីនេះគឺ ជំរុញការងាររដ្ឋបាលនៅគ្រប់កម្រិតឱ្យដំណើរការទៅមុខតាមបទដ្ឋានរដ្ឋបាលជាក់លាក់ តាមរយៈការពង្រឹងបណ្តាញការងាររដ្ឋបាលពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ។ វត្ថុបំណងមួយទៀតគឺ រៀបចំឱ្យមានសេវាផ្តល់ និងទទួលព័ត៌មានអប់រំដើម្បីធានា និង ជំរុញការបំពេញ ការងារលើគ្រប់វិស័យរបស់ផ្នែកប្រតិបត្តិឱ្យប្រព្រឹត្តទៅដោយរលូន និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី៣ ៖ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ*

❖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល។

សកម្មភាពគោលនយោបាយ ៖

- ផែនការយុទ្ធសាស្ត្រស្តីពី ការពង្រឹងការគ្រប់គ្រងរដ្ឋបាល រៀបចំបាននៅឆ្នាំ ២០១២។
- សេចក្តីណែនាំស្តីពីការអនុវត្តច្រកចេញចូលតែមួយ រៀបចំបាននៅឆ្នាំ ២០១២។
- សេចក្តីណែនាំស្តីពីបែបបទការគ្រប់គ្រងរដ្ឋបាល និងការទុកដាក់ឯកសារ រៀបចំបាននៅឆ្នាំ ២០១២ ។
- យន្តការស្តីពីការងារប្រឡងប្រណាំង កែសម្រួលបាននៅឆ្នាំ ២០១២។
- សេចក្តីណែនាំស្តីពីការរៀបចំសេវាផ្តល់ និងទទួលព័ត៌មានក្នុងផ្នែករដ្ឋបាលពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន រៀបចំបាននៅឆ្នាំ ២០១៣។

### ៣. សូចនាករ និងចំណុចដៅ

- ការពិនិត្យឡើងវិញលើគ្រប់វិស័យរបស់ផ្នែកអប់រំ តាមរយៈការរៀបចំសន្និបាតអប់រំ ប្រចាំឆ្នាំ។
- ច្រកចេញចូលតែមួយត្រូវបានបង្កើតឡើងក្នុងផ្នែករដ្ឋបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅឆ្នាំ ២០១១។
- ប្រព័ន្ធទិន្នន័យឯកសាររដ្ឋបាលត្រូវបានបង្កើតនៅដើមឆ្នាំ ២០១២។

## ៤. សកម្មភាព និងកម្មវិធីចម្បង

៤.១ កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)

- ការពង្រឹងសមត្ថភាពការងារគ្រប់គ្រងរដ្ឋបាល និងរបាយការណ៍
- ការងារប្រឡងប្រណាំង
- ការរៀបចំសេវាផ្តល់ និងទទួលព័ត៌មានក្នុងផ្នែករដ្ឋបាលនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន
- ការរៀបចំទិន្នន័យសម្រាប់តម្កល់ឯកសាររដ្ឋបាល និងឯកសារពាក់ព័ន្ធ
- ការត្រួតពិនិត្យទៀងទាត់ និងវាយតម្លៃការបំពេញការងារ

៤.២ កម្មវិធីមូលធន

*ការវិនិយោគ ៖*

- ផ្តល់សម្ភារៈ និងមធ្យោបាយសម្រាប់ដំ ណើរការការងាររដ្ឋបាលរបស់ផ្នែករដ្ឋបាលថ្នាក់រាជធានី ខេត្ត ក្រុង និង ស្រុក ខណ្ឌ

*កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖*

- ការពង្រឹងសមត្ថភាពមន្ត្រីផ្នែករដ្ឋបាលលើគ្រប់វិស័យក្នុងផ្នែកអប់រំ
- ការត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងរដ្ឋបាល
- ការរៀបចំសន្និបាតអប់រំប្រចាំឆ្នាំ

## ៥. ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

នាយកដ្ឋានរដ្ឋបាលនឹងទទួលខុសត្រូវលើការអនុវត្តកម្មវិធីនេះ។ ការិយាល័យ ឬផ្នែករដ្ឋបាលនៅថ្នាក់ជាតិ និងថ្នាក់ ក្រោមជាតិ នឹងអនុវត្តសកម្មភាពទាំងនេះដោយមានការណែនាំ និងត្រួតពិនិត្យតាមដានជាទៀងទាត់ពីនាយកដ្ឋានរដ្ឋបាល។ ការងាររដ្ឋ បាលជាសេវាសម្រាប់គាំទ្រឱ្យការងារជំនាញដំណើរការទៅមុខដោយរលូន ហើយប្រព័ន្ធគ្រប់គ្រងរដ្ឋបាលដែលល្អ ក៏នឹងជួយឱ្យថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងផ្នែកពាក់ ព័ន្ធមានភាពងាយស្រួលក្នុងការដឹកនាំ និងការរៀបចំដំណើរ ការកម្មវិធីផ្សេងៗ ។

## ៦. ផែនការហិរញ្ញវត្ថុ(គិតជាលានរៀល)

| សកម្មភាព | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|
| **១- កម្មវិធីចរន្ត** | **936.0** | **700.0** | **793.0** | **585.0** |
| ពង្រឹងបណ្តាញការងាររដ្ឋបាលពីថ្នាក់ជាតិ ដល់ថ្នាក់មូលដ្ឋាន | 45.0 | 60.0 | 85.0 | 120.0 |
| រៀបចំសេវាផ្តល់និងទទួលព័ត៌មានក្នុងផ្នែករដ្ឋបាល នៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន | 50.0 | 65.0 | 85.0 | 125.0 |
| ពង្រឹងប្រព័ន្ធត្រួតពិនិត្យ | 135.0 | 102.0 | 76.0 | 50.0 |
| បំផុសចលនាការងារប្រឡងប្រណាំង | 46.0 | 33.0 | 32.0 | 25.0 |
| រៀបចំទិន្នន័យសម្រាប់តម្កល់ឯកសាររដ្ឋបាល និង ឯកសារពាក់ព័ន្ធ | 45.0 | 50.0 | 175.0 | 65.0 |
| ត្រួតពិនិត្យទៀងទាត់ និងវាយតម្លៃការបំពេញ ការងារ | 65.00 | 55.0 | 50.0 | 45.0 |
| ពង្រឹងសមត្ថភាពការងារគ្រប់គ្រងរដ្ឋបាល និង របាយការណ៍ | 215.0 | 215.0 | 215.0 | 120.0 |
| ផែនការយុទ្ធសាស្ត្រស្តីពីការពង្រឹងការគ្រប់គ្រង រដ្ឋបាល | 335.0 | 120.0 | 75.0 | 35.0 |
| **២-កម្មវិធីមូលធន** | **170.0** | **130.0** | **130.0** | **130.0** |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 170.0 | 130.0 | 130.0 | 130.0 |
| **ធនធានសរុប** | **1106.0** | **830.0** | **923.0** | **715.0** |



# ផែនការ និង ការគ្រប់គ្រងហិរញ្ញវត្ថុ
# សម្រាប់ជួយគាំទ្រដល់ជនក្រក្រ

# ៦. ផែនការ និងការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ជួយគាំទ្រដល់ជនក្រីក្រ

## ៦.១ ការព្យាករណ៍ថវិកាសម្រាប់វិស័យអប់រំ

ទិសដៅគោលនយោបាយរយៈពេលវែង នៃការផ្តល់ហិរញ្ញប្បទានសម្រាប់វិស័យអប់រំ គឺគ្មានសិស្សណាម្នាក់មិនបានទទួលការអប់រំ និង ការបណ្តុះបណ្តាលដោយសារតែគ្មានលទ្ធភាពបង់ប្រាក់ទោះជាតាមផ្លូវការ ក្រៅផ្លូវការ ឬជាវិភាគទាននោះទេ។ គោលដៅមួយទៀតគឺ ការអនុវត្តយន្តការហិរញ្ញប្បទានប្រកបដោយសមធម៌និងត្រឹមត្រូវ ដោយគិតទាំងការជួយគាំទ្រពីសំណាក់ រាជរដ្ឋាភិបាល មាតាបិតាសិស្ស និង ដៃគូអភិវឌ្ឍដទៃទៀត។ ជាមួយ នោះ ព័ត៌មាន ផ្នែកហិរញ្ញវត្ថុមានគ្រប់គ្រាន់សម្រាប់ជូនដំណឹងដល់ដៃគូអភិវឌ្ឍទាំងអស់អំពីការចំណាយក្នុងវិស័យអប់រំ ដើម្បី ផ្តល់លទ្ធភាពក្នុងពិនិត្យឡើងវិញលើការវិនិយោគនាពេលបច្ចុប្បន្ន និង ពេលអនាគតប្រកបដោយប្រសិទ្ធភាព។ ម្យ៉ាងវិញទៀត ជំរុញឱ្យមានការចូលរួមពីសំណាក់រាជរដ្ឋាភិបាល មាតាបិតាសិស្ស ផ្នែកឯកជន និ ង អ្នក ពាក់ព័ន្ធដទៃទៀត ក្នុងការផ្តល់ហិរញ្ញប្បទានសម្រាប់ការអប់រំនៅគ្រប់កម្រិត ។

នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ ការព្យាករណ៍ចំណាយថវិកាសម្រាប់វិស័យអប់រំសម្រាប់រយៈពេលពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៣ បានកើនឡើងទៅដល់ ១២០៧ ពាន់លានរៀល នៅក្នុងឆ្នាំ ២០១៣។ ចំពោះការព្យាករណ៍ ចំណាយសម្រាប់វិស័យអប់រំនៅក្នុងក្របខណ្ឌចំណាយរយៈពេលមធ្យម ២០១១-២០១៣ និងផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ ២០១១-២០១៣ ចំណាយថវិកាចរន្តក្នុងវិស័យអប់រំបានកើនឡើងពី ៨២៤ ពាន់លានរៀលនៅឆ្នាំ ២០១០ ទៅដល់ ១១៦៥ ពាន់លានរៀល នៅឆ្នាំ ២០១៣ ក្នុងនោះបន្ទុកបុគ្គលិកមានប្រមាណ ៧៤% នៃចំណាយចរន្តសរុប និងថយចុះមកត្រឹម ៧២% នៅឆ្នាំ ២០១៣។ ចំណាយសម្រាប់ថវិកាកម្មវិធីនឹងកើនឡើងពី ១២៧ ពាន់លានរៀលនៅឆ្នាំ ២០១០ ទៅដល់ ២០១ ពាន់លានរៀលនៅឆ្នាំ ២០១៣។ ភាគរយថវិកាកម្មវិធីធៀបនឹងចំណាយចរន្តសរុបនឹងកើនឡើងពី ១៥.៤% ទៅដល់ ១៧.៣% (តារាង ទី ៦)។

តារាងទី៦ ៖ ចំណែកថវិកាសម្រាប់វិស័យអប់រំនិងការព្យាករណ៍ចំណាយសម្រាប់ឆ្នាំ២០១១-២០១៣

(គិតជាលានរៀល)

| កម្មវិធី | ឆ្នាំ ២០១០ | ឆ្នាំ ២០១១ | ឆ្នាំ ២០១២ | ឆ្នាំ ២០១៣ |
|---|---|---|---|---|
| **ចំណាយថវិកាចរន្ត វិស័យអប់រំ *** | **824 879 .0** | **935 737.0** | **1 064 039.0** | **1 207 989.0** |
| **សរុបចំណាយចរន្ត **** | **824 879.0** | **950 184.7** | **1 046 418.6** | **1 165 414.9** |
| បន្ទុកបុគ្គលិក | 609 960.0 | 686 815.0 | 756 448.8 | 842 388.1 |
| ក្រៅពីបន្ទុកបុគ្គលិក | 214 919.0 | 263 369.7 | 289 969.8 | 323 026.8 |
| **ថវិកាកម្មវិធី **** | **127 032.0** | **164 409.0** | **181 014.1** | **201 649.9** |
| ភាគរយថវិកាកម្មវិធី/ចរន្តសរុប | 15.4% | 17.3% | 17.3% | 17.3% |

* ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ ** ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១១-២០១៣

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ បានប្រមូលផ្តុំសកម្មភាពអភិវឌ្ឍទាំងអស់ទៅជា កម្មវិធីធំៗចំនួន ៥ និងមានអនុកម្មវិធីចំនួន ២៨ (មើលតារាង ខ ក្នុងឧបសម្ព័ន្ធ)។ នៅក្នុងដំណាក់កាលឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៣ ក្រសួងអប់រំ យុវជន និងកីឡាបន្តអនុវត្តកំណែទម្រង់ដែលកំពុងអនុវត្ត និងបន្ថែមនូវសកម្មភាពអភិវឌ្ឍមួយចំនួនទៀត សំដៅសម្រេចបានគោលនយោបាយទាំងបីរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ដូចនេះតម្រូវការធនធានសរុបសម្រាប់ អនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ នឹងកើនឡើងពី ៨៥៥ ពាន់លានរៀលនៅឆ្នាំ ២០១០ ទៅដល់ ១៧៩៥ ពាន់លានរៀលនៅឆ្នាំ ២០១៣។ ក្នុងរយៈពេលដូចគ្នា តម្រូវការថវិកាចរន្តសរុបនឹងកើនឡើងពី ៨២៤ ពាន់លានរៀល ទៅដល់ ១៣៧៧ ពាន់លានរៀល។ តម្រូវការថវិកាកម្មវិធីសរុបនឹងកើនឡើងពី ១៦២ ពាន់លានរៀល ទៅដល់ ៣០៤ ពាន់លានរៀល។ ភាគរយថវិកាកម្មវិធីធៀបនឹងថវិកាចរន្តសរុបត្រូវបានគេរំពឹងថានឹងកើនឡើងពី ១៩.៧% ទៅដល់ ២២.១%។

ចំពោះតម្រូវការថវិកាមូលធនសរុបនឹងកើនឡើងពី ៣០ ពាន់លានរៀលក្នុងឆ្នាំ ២០១០ ទៅដល់ ៤១៧ ពាន់លានរៀលក្នុងឆ្នាំ ២០១៣ ។ ក្នុងរយៈពេលពីឆ្នាំ ២០១០ ដល់ ២០១៣ ថវិកាប្រមាណ ៨៦២ ពាន់លានរៀល នឹងត្រូវចំណាយសម្រាប់ការសាងសង់។ ទន្ទឹមនឹងការកើនឡើងខ្លាំងតម្រូវការថវិកាមូលធននៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ ថវិកាមូលធនដែលដៃគូអភិវឌ្ឍបានប្តេជ្ញានៅក្នុងកម្មវិធីវិនិយោគសាធារណៈឆ្នាំ ២០១១-២០១៣ នឹងថយចុះពីប្រមាណ ៣៣៤ ពាន់លានរៀល នៅឆ្នាំ ២០១១ មកនៅត្រឹម ២៥៣ ពាន់លានរៀលនៅឆ្នាំ ២០១៣។ ការថយចុះនេះដោយសារការថយចុះនៃការគាំទ្រពីដៃគូអភិវឌ្ឍ តាមរយៈគម្រោងដែលកំពុងអនុវត្តមួយចំនួននឹងត្រូវបញ្ចប់នៅឆ្នាំ ២០១៣។ ប៉ុន្តែ ថវិការាជរដ្ឋាភិបាល ជាពិសេសចំណាយចរន្តមានការកើនឡើង។

តារាងទី ៧ ៖ តម្រូវការធនធានសម្រាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៩-២០១៣ (គិតជាលានរៀល)

| កម្មវិធី | ឆ្នាំ ២០១០ | ឆ្នាំ ២០១១ | ឆ្នាំ ២០១២ | ឆ្នាំ ២០១៣ |
|---|---|---|---|---|
| ថវិកាចរន្តសរុប | 824 879.0 | 1 020 033.0 | 1 184 656.0 | 1 377 956.0 |
| ថវិកាកម្មវិធី សរុប | 162 271.5 | 226 550.3 | 265 601.1 | 304 131.9 |
| ភាគរយថវិកាកម្មវិធី/ចរន្តសរុប | 19.67% | 22.21% | 22.42% | 22.07% |
| ថវិកាមូលធនសរុប | 30 395.0 | 408 585.0 | 412 672.0 | 417 252.0 |
| *ផលធៀប មូលធន/ចរន្ត* | *4%* | *40%* | *35%* | *30%* |
| **តម្រូវការសរុបសម្រាប់វិស័យអប់រំ** | **855 273.0** | **1 428 616.0** | **1 597 328.0** | **1 795 208.0** |

នៅក្នុងឯកសារផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ ការផ្តល់ហិរញ្ញប្បទានសម្រាប់វិស័យអប់រំ នៅតែជាឧបករណ៍សម្រាប់កែទម្រង់ និងអនុវ ត្តគោលនយោបាយជួយជនក្រីក្រតាមរយៈ បង្កើនចំណែក និងបរិមាណនៃថវិកាចំណាយចរន្ត និងថវិកាមូលធន ទៅលើឃុំក្រីក្របំផុត

និងតំបន់ដែលមានសិស្សចូលរៀនតិចតួច ជាពិសេសសិស្ស ស្រី ។

លក្ខណៈពិសេសសំខាន់ៗរួមមាន ៖

១) រក្សាភាគរយនៃចំណាយចរន្តលើការអប់រំមូលដ្ឋាន នៅកន្លែងណាដែលមានសិស្សក្រីក្រច្រើនឲ្យស្ថិតក្នុងរង្វង់ ៣៨% ក្នុងរយៈពេលអនុវត្តផែនការនេះ (គ្រោងចំណាយ ពី ៨០ ពាន់លានរៀល នៅឆ្នាំ ២០១០ ដល់ទៅប្រហែល ១០៥ ពាន់លានរៀល នៅ ឆ្នាំ ២០១៣ ជាពិសេសថវិកាដំណើរការសាលារៀន) ។

២) ធានាឱ្យមាននិរន្តរភាពចំណាយមូលធនលើការអភិវឌ្ឍសម្ភាររូបវន្តនៅអប់រំមូលដ្ឋាន និងការអភិវឌ្ឍសម្ភាររូបវន្តនៅក្រោយអប់រំមូលដ្ឋាន។ បង្កើនការសាងសង់សាលាបឋមសិក្សា និងមធ្យមសិក្សាបន្ថែមនៅតំបន់ជនបទដែលក្រីក្របំផុត និងកន្លែងពុំទាន់មាន ដែលគ្រោងចំណាយស្មើនឹង ៣០% នៃថវិកាមូលធន ។ ថវិកាមូលធនសម្រាប់កម្មវិធីនេះមានប្រហែល ៨៦០ ពាន់លានរៀល (ប្រហែល ២៨៧ ពាន់លានរៀលក្នុងមួយឆ្នាំ) ។

៣) កែទម្រង់ការផ្តល់ប្រាក់បៀវត្សផ្អែកលើការបំពេញការងារដោយផ្សារភ្ជាប់ទៅនឹងការកែលម្អគុណភាព និង បង្កើនការចូលរៀន (តារាង ឃ ក្នុងឧបសម្ព័ន្ធ) ។ ការលុបបំបាត់ចំណាយក្រៅផ្លូវការជំនួសដោយការផ្តល់ការលើកទឹកចិត្ត និងបង្កើនប្រាក់បៀវត្សគ្រូបង្រៀនផ្អែក តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ អាទិភាពគឺការបង្កើនប្រាក់ឧបត្ថម្ភ និងប្រាក់លាភការជូនគ្រូឈរថ្នាក់ ដែលស្របទៅនឹងយុទ្ធសាស្ត្រកែទម្រង់ប្រាក់បៀវត្សរបស់រាជរដ្ឋាភិបាល ដើម្បីបង្កបរិយាកាសដល់ការចូលរៀនរបស់កុមារក្រីក្រ ព្រម ទាំងការកែលម្អគុណភាពផងដែរ។ ចំណាយសម្រាប់បុគ្គលិកគ្រូ បានគ្រោងថាកើនឡើងពី ៦១០ ពាន់លាន រៀលនៅឆ្នាំ ២០១០ ទៅប្រហែល ៨៤២ ពាន់លានរៀលនៅត្រឹមឆ្នាំ ២០១៣។ ចំណាយមិនមែនបុគ្គលិកត្រូវរក្សាឲ្យនៅត្រឹម ២៧% រៀងរាល់ ឆ្នាំ ដើម្បីធ្វើឲ្យយុទ្ធសាស្ត្រផ្តល់ហិរញ្ញប្បទានកាន់តែមានតុល្យភាព និងប្រសិទ្ធភាព ។ ដើម្បីធានា ឲ្យផលប៉ះពាល់នៃយុទ្ធសាស្ត្រផ្តល់ប្រាក់ឧបត្ថម្ភដែលបានគ្រោងមានលក្ខណៈល្អប្រសើរ ការបង្កើនប្រាក់លាភការនឹងត្រូវផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងការពង្រាយបុគ្គលិកប្រកបដោយប្រសិទ្ធភាព ការដាក់ឱ្យប្រើប្រាស់នូវការវាយតម្លៃការបំពេញការងារបុគ្គលិកប្រចាំឆ្នាំ ដែលជាមូលដ្ឋានសម្រាប់ដំឡើងប្រាក់បៀវត្ស និងឋានៈតួនាទី ព្រមទាំងការពង្រឹងអធិការកិច្ចគ្រូបង្រៀននៅថ្នាក់សាលារៀនផងដែរ ។

## ៦.២ ការព្យាករណ៍តម្រូវការហិរញ្ញវត្ថុ និងធនធានដែលមាន

ដើម្បីអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រក្នុង ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ ឲ្យមានប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡា នឹងបន្តខិតខំធ្វើការកាន់តែជិតស្និទ្ធថែមទៀត ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុម ប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីធានាថា ផែនការចំណាយរយៈពេលមធ្យមសម្រាប់វិស័យអប់រំ ស្របទៅនឹងក្រប ខណ្ឌចំណាយរយៈពេលមធ្យមរបស់រាជរដ្ឋាភិបាល ព្រមទាំងស្របតាមការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលកំពុងអនុវត្ត។

ក្រសួងនឹងខិតខំប្រឹងប្រែងដើម្បីធានាថា តម្រូវការផ្នែកថវិកាចរន្តដែលបានគ្រោងរួចហើយ នោះនឹងបានមកពីចំណូលថវិការបស់រដ្ឋ និងប្រភពដទៃទៀត ។ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តក្នុងការ បង្កើនថវិកាចំណាយចរន្តសម្រាប់វិស័យអប់រំដែលក្នុងឆ្នាំ ២០១០ ទទួលបាន ១៧.៨% ដែលរំពឹងថានឹងកើនឡើងទៅដល់ ២២.៣% នៅឆ្នាំ ២០១៣ (សូមមើលតារាង ង ក្នុងឧបសម្ព័ន្ធ)។

តារាងទី ៨ ៖ តម្រូវការធនធាន និងធនធានដែលមាន (គិតជាលានរៀល)

| កម្មវិធី | ឆ្នាំ ២០១០ | ឆ្នាំ ២០១១ | ឆ្នាំ ២០១២ | ឆ្នាំ ២០១៣ |
|---|---|---|---|---|
| **ចំណាយថវិកាចរន្តវិស័យអប់រំ *** | **824 879.0** | **935 737.0** | **1 064 039.0** | **1 207 989.0** |
| តម្រូវការថវិកាចរន្តសរុប | 824 879.0 | 1 020 032.8 | 1 184 656.2 | 1 377 956.3 |
| គម្លាត ថវិកាចរន្ត | 0.0 | -84 295.8 | -120 617.2 | -169 967.3 |
| ថវិកាដៃគូអភិវឌ្ឍ សរុប** | 334 485.9 | 416 320.2 | 310 847.1 | 253 729.4 |
| ថវិកាមូលធនសរុប | 30 394.7 | 408 584.8 | 412 672.3 | 417 251.8 |
| គម្លាត ថវិកាមូលធន | 304 091.2 | 7 735.4 | -101 825.2 | -163 522.4 |
| **គម្លាតថវិកា សរុប** | **304 091.2** | **-76 560.4** | **-222 442.4** | **-333 489.7** |

* ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ ** ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១១-២០១៣

ក្នុងតារាងខាងលើបានបង្ហាញពីកង្វះថវិកាចរន្តប្រមាណ ៣២៨ ពាន់លានរៀល ក្នុងកំឡុងពេលពីឆ្នាំ ២០១០ ទៅដល់ឆ្នាំ ២០១៣ ខាងមុខ។ ក្នុងករណីនេះ ក្រសួងនឹងត្រូវស្វែងរកការជួយឧបត្ថម្ភលើចំណាយចរន្តពីសំណាក់ដៃគូអភិវឌ្ឍឬអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីបំពេញកង្វះខាតថវិកានេះ និងធានាផ្តល់ហិរញ្ញវត្ថុសម្រាប់កែទម្រង់វិស័យអប់រំប្រកបដោយចីរភាព។

ជារួម នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ កង្វះខាតហិរញ្ញប្បទានសរុបមានប្រហែល ៣២៨ ពាន់លានរៀល ( ៨២ លានដុល្លារអាមេរិក) ។

ដើម្បីធានាការព្យាករណ៍ហិរញ្ញប្បទានពីខាងក្រៅ ក្រសួងអប់រំ យុវជន និងកីឡាបាន លើកវិធានការមួយចំនួនរួមមាន ៖

- ការអះអាងនិងការដាក់បញ្ចូលរួមគ្នាថវិការបស់ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យអប់រំ ដើម្បីផ្តល់ថវិកាសម្រាប់អនុវត្តកម្មវិធីក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣។
- ការពិនិត្យឡើងវិញលទ្ធភាពធនធានប្រចាំឆ្នាំ តា មរយៈ ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងតាមរយៈសន្និបាតអប់រំប្រចាំឆ្នាំ។
- ការអនុវត្តភាពទន់ភ្លន់នៃបែបបទជំនួយពីខាងក្រៅ តាមរយៈការអនុវត្តគោលការណ៍ភាពជាដៃគូ និងប្រសិទ្ធភាពហិរញ្ញប្បទានសហាប្រតិបត្តិការ។

## ៦.៣ ការកែលម្អប្រព័ន្ធគ្រប់គ្រងនិងពិនិត្យតាមដានហិរញ្ញវត្ថុ

ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ ត្រូវផ្តោតជាពិសេសលើការកែលម្អនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ កិច្ចបញ្ជិការគណនេយ្យ និងសវនកម្មផ្ទៃក្នុង ស្របតាមប្រព័ន្ធហិរញ្ញវត្ថុដែលមានស្រាប់។ ក្រសួងអប់រំ យុវជន និងកីឡានឹង ត្រូវធានាតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវលើការគាំទ្រហិរញ្ញវត្ថុសម្រាប់វិស័យអប់រំ រួមទាំងធនធានជំនួយពីខាងក្រៅ និងត្រូវពិនិត្យតាមដាន និងធ្វើរបាយការណ៍នៃការចំណាយ ឲ្យកាន់តែច្បាស់លាស់ ព្រមទាំងការបើកផ្តល់ និងការបញ្ចេញសាច់ប្រាក់ឲ្យបានទាន់ពេលវេលា ។

ក្រសួងអប់រំ យុវជន និងកីឡាបានស្នើឡើងនូវយន្តការគ្រប់គ្រងនិងកសាងផែនការថវិកាចរន្តដូចខាងក្រោមនេះ៖

- កម្មវិធីកែទម្រង់ការចំណាយក្នុងវិស័យអប់រំដោយផ្តោតលើការសម្រេចលទ្ធផល និងតម្រង់ទៅសម្រេចគោលនយោបាយរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣។
- កែលម្អសេចក្តីណែនាំស្តីពីការប្រើប្រាស់និងពិនិត្យតាមដានការអនុវត្តថវិកា សម្រាប់អង្គភាពនៅគ្រប់កម្រិត
- អង្គភាព ឬនាយកដ្ឋាន និងគ្រឹះស្ថានអប់រំក្រោយមធ្យមសិក្សានីមួយៗ របស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវគ្រប់គ្រង ចំណែកថវិកាជាក់លាក់ និងចំណែកថវិកាដែលផ្ទេរ ឲ្យសម្រាប់រដ្ឋបាលកណ្តាល ។
- ការបែងចែកថវិកាទៅឲ្យរាជធានី ខេត្ត និងតាមគ្រឹះស្ថានសិក្សា សម្រាប់អនុវត្ត ថវិកាកម្មវិធីសំខាន់ៗមួយចំនួន។

ក្រសួងនឹងពង្រីកការកសាងសមត្ថភាពក្នុងប្រព័ន្ធពិនិត្យតាមដានហិរញ្ញវត្ថុ និងនីតិវិធីនានាដែលជាផ្នែកមួយនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ ។ ការកសាងសមត្ថភាពត្រូវផ្តោតទៅលើការពង្រឹងប្រព័ន្ធរបាយការណ៍ និងកិច្ចបញ្ជិការគណនេយ្យរបស់ថ្នាក់រាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ តាមរយៈប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុរាជធានី ខេត្ត ការកែលម្អការសម្រប សម្រួល និងរបាយការណ៍ ហិរញ្ញវត្ថុរបស់អនុកម្មវិធី និងកម្មវិធីនៅតាមអគ្គនាយកដ្ឋាន និង នាយកដ្ឋាននានានៅរដ្ឋបាលកណ្តាលរបស់ក្រសួងអប់រំ យុវជន និងកីឡា និងពង្រីកប្រតិបត្តិការសវនកម្មផ្ទៃក្នុង នៅតាមអង្គភាពអនុវត្តថវិកា និងកម្មវិធីនានា។



# ការពិនិត្យតាមដាន និងការពិនិត្យឡើងវិញ
# ការបំពេញការងារផ្តោតលើលទ្ធផល

# ៧. ការពិនិត្យតាមដាន និងការពិនិត្យឡើងវិញការបំពេញការងារផ្អែកលើលទ្ធផល

## ៧.១ ការកែលម្អការពិនិត្យតាមដានងស័យផ្អែកលើលទ្ធផល

ការពិនិត្យតាមដាន និងពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ ត្រូវធ្វើឡើងស្របគ្នាជាមួយនឹងក្របខណ្ឌនៃការពិនិត្យតាមដាន និងពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣។ ដូច្នេះសូចនាករសំខាន់ៗសម្រាប់ពិនិត្យតាមដានវឌ្ឍនភាពរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក៏អាចបង្ហាញផងដែរអំពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្នុងវិស័យអប់រំ។ សូចនាករ របស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ ត្រូវបានពិនិត្យឡើងវិញ តាមរយៈការរក្សាទុកសូចនាករមួយចំនួន និងបន្ថែមសូចនាករសំខាន់ៗដទៃទៀត។ ជារួម សូចនាករចំនួន ២៤ ត្រូវបានកំណត់យក ក្នុងនោះ គោលនយោបាយទី ១ មានសូចនាករចំនួន ០៧ គោលនយោបាយទី ២ មានសូចនាករចំនួន ១១ និងគោលនយោបាយទី ៣ មានសូចនាករចំនួន ០៦។

សូចនាករដែលបានកំណត់ក្នុងគោលនយោបាយទី ១ បានផ្តោតការយកចិត្តទុកដាក់ទៅលើការបង្កើនសមធម៌ក្នុងការសម្រេចបានការចូលរៀន ទៅតាមលក្ខណសម្បត្តិខុសៗគ្នាដូចជា ចំនួនសាលារៀនគ្រប់កម្រិតដែលសម្រេចបានអត្រាពិតចូលរៀនថ្មី និងអត្រាពិតនៃការសិក្សាធំជាង ៩៥%។ ដោយឡែកនៅមធ្យមសិក្សា អត្រារួមនៃការ សិក្សានៅមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិត្រូវបានបញ្ចូលបន្ថែម។ ដូចគ្នានេះដែរ អត្រាអក្ខរភាពអាយុពី ១៥-២៤ ឆ្នាំត្រូវបានកំណត់ ទោះបីជាប្រភពទិន្នន័យនៃសូចនាករមួយនេះ ពឹងផ្អែកទៅលើ លទ្ធផលនៃការអង្កេតរបស់ក្រសួងផែនការក៏ដោយ។

សូចនាករផលធៀបសិស្ស-គ្រូ ត្រូវបានជំ នួសដោយ ផលធៀបសិស្ស- ថ្នាក់ និងផលធៀប គ្រូ-ថ្នាក់ ដើម្បីឆ្លុះបញ្ចាំង ពីការប្រើប្រាស់គ្រូជាក់ស្តែងនៅកម្រិតមូលដ្ឋាន។ សូចនាករអត្រាត្រួតថ្នាក់ អត្រាបោះបង់ការសិក្សា និងអត្រាបញ្ចប់ការសិក្សានៅរក្សាទុក ដើម្បីវាស់វែងអំពីប្រសិទ្ធភាពផ្ទៃក្នុងនៃការអប់រំ។ សូចនាករផលធៀបសិស្ស- សៀវភៅសិក្សា និង ភាគរយសិស្សសម្រេចបានតាមស្តង់ដាការសិក្សាលើមុខវិជ្ជា ភាសាខ្មែរ និងគណិតវិទ្យាដោយផ្អែកលើតែសនៅថ្នាក់ទី ៣ និងទី ៦ ត្រូវបានកំណត់ដើម្បីជាមូលដ្ឋាន អាចវាស់វែងអំពីគុណភាពនៃសេវាអប់រំ។

សូចនាករក្នុងគោលនយោបាយទី ៣ ត្រូវរក្សាទុកតាមលទ្ធផលនៃការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-២០១០។ សូចនាករទាំងនោះផ្តោតចំណែកថវិកាចរន្តសម្រាប់វិស័យអប់រំ និងការប្រើប្រាស់ថវិកាកម្មវិធី រួមទាំងការធ្វើសវនកម្មអង្គភាពដែលកំពុងអនុវត្តថវិកាកម្មវិធីផងដែរ។

តារាងទី ៩ ៖ សូចនាករសំខាន់ៗរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣

| | |
|---|---|
| **គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌** | |
| 1 | ចំនួនកុមារអាយុ ៥ ឆ្នាំក្នុងកម្មវិធី អប់រំកុមារ តូចតាមគ្រប់រូបភាព - សរុប - ស្រី |
| 2 | អត្រាពិតចូលរៀនថ្មី - ទូទាំងប្រទេស - សរុប - ស្រី - ចំនួនសាលារៀនគ្រប់កម្រិតដែលសម្រេចបាន > 95% |
| 3 | អត្រាពិតនៃការសិក្សានៅបឋមសិក្សា - ទូទាំងប្រទេស - ចំនួនសាលារៀនគ្រប់កម្រិតដែលសម្រេចបាន > 95% |
| 4 | អត្រារួម និងអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ - ទូទាំងប្រទេស - សរុប - ស្រី |
| 5 | អត្រារួម និងអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ - ទូទាំងប្រទេស - សរុប - ស្រី |
| 6 | ចំនួននិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណ: និងឯកជន - សរុប - ស្រី |
| 7 | អត្រាអក្ខរភាព អាយុពី 15-24 ឆ្នាំ |
| **គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ** | |
| 8 | ផលធៀប សិស្ស-ថ្នាក់ នៅបឋមសិក្សា |
| 9 | ផលធៀប គ្រូ-ថ្នាក់ នៅបឋមសិក្សា |
| 10 | អត្រាត្រួតថ្នាក់ - បឋមសិក្សា - មធ្យមសិក្សាបឋមភូមិ - មធ្យមសិក្សាទុតិយភូមិ - សរុប - ស្រី |
| 11 | អត្រាបោះបង់ការសិក្សា - បឋមសិក្សា - មធ្យមសិក្សាបឋមភូមិ - មធ្យមសិក្សាទុតិយភូមិ - សរុប - ស្រី |
| 12 | អត្រាបញ្ចប់ការសិក្សា - បឋមសិក្សា - មធ្យមសិក្សាបឋមភូមិ - មធ្យមសិក្សាទុតិយភូមិ - សរុប - ស្រី |
| 13 | ចំនួនសិស្សចូលរៀនឡើងវិញ នៅថ្នាក់ទី ៣ ដល់ ទី ៩ |
| 14 | ចំនួនសាលារៀនបឋមសិក្សាមិនគ្រប់កម្រិត |
| 15 | ផលធៀបសៀវភៅសិក្សា-សិស្សនៅបឋមសិក្សា ( ១ សម្រាប់ មាន ៥ ក្បាល) |
| 16 | ភាគរយសិស្សសម្រេចបានតាមស្តង់ដាការសិក្សាលើមុខវិជ្ជា ភាសាខ្មែរ ដោយផ្អែកលើតែសនៅថ្នាក់ទី ៣ និងទី ៦ |
| 17 | ភាគរយសិស្សសម្រេចបានតាមស្តង់ដាការសិក្សាលើមុខវិជ្ជាគណិតវិទ្យាដោយផ្អែកលើតែសនៅថ្នាក់ទី៣ និងទី ៦ |
| 18 | ភាគរយគ្រឹះស្ថានឧត្តមសិក្សា សាធារណ:និងឯកជន គោរពតាមលក្ខខណ្ឌនៃការបង្កើត |
| **គោលនយោបាយទី ៣ ៖ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ** | |
| 19 | ចំណែកថវិកាជាតិចរន្តសម្រាប់វិស័យអប់រំ |
| 20 | ភាគរយចំណាយថវិកាកម្មវិធីជាក់ស្តែងធៀបនឹងថវិកាកម្មវិធីសរុប |
| 21 | ភាគរយ អង្គភាពអនុវត្តថវិកា ដែលត្រូវធ្វើសវនកម្មផ្ទៃក្នុង ក្នុង ១ ឆ្នាំ |
| 22 | ភាគរយសាលារៀននិងគ្រឹះស្ថានសិក្សាដែលត្រូវធ្វើសវនកម្មផ្ទៃក្នុង ក្នុង ១ ឆ្នាំ |
| 23 | ជំនួយការបច្ចេកទេស (Person-month) ថ្នាក់ជាតិ និងអន្តរជាតិ |
| 24 | ភាគរយមន្ត្រីអប់រំជាស្ត្រី - បុគ្គលិកបង្រៀន - មន្ត្រីគ្រប់គ្រងថ្នាក់មធ្យម - ថ្នាក់ដឹកនាំ |

សូចនាករទាំងអស់ខាងលើនឹងត្រូវពិនិត្យតាមដានវឌ្ឍនភាព តាមរយ: សន្និបាតអប់រំប្រចាំឆ្នាំ។

## ៧.២ ការពង្រឹងដំណើរការពិនិត្យឡើងវិញការបំពេញការងារប្រចាំឆ្នាំរួមគ្នា

### ៧.២.១ លទ្ធផលរំពឹងទុករបស់អនុកម្មវិធី និងផែនការប្រតិបត្តិប្រចាំឆ្នាំ

នាពេលបច្ចុប្បន្ន សូចនាករនិងចំណុចដៅរបស់អនុកម្មវិធី ដែលស្ថិតក្រោមកម្មវិធីចរន្តភាគច្រើនជាលទ្ធផលរំពឹងទុករបស់អនុកម្មវិធីនីមួយៗ។ វាមិ នមែនជាលទ្ធផលរំពឹងទុកដែលអាចវាស់វែងពីវឌ្ឍនភាពរបស់សកម្មភាពចម្បងៗនោះទេ។ កត្តានេះធ្វើឱ្យមានការលំបាកក្នុងការពិនិត្យលើ សកម្មភាពចម្បងៗឱ្យបានជាក់លាក់។ ហេតុដូចនេះ លទ្ធផលរំពឹងទុករបស់សកម្មភាពចម្បងនីមួយៗត្រូវបានបង្ហាញនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ដែលជាផែនការបីឆ្នាំរំកិល និងផែនការប្រតិបត្តិប្រចាំឆ្នាំ។

ក្នុងរយៈពេលពីរឆ្នាំកន្លះកន្លងមក ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួ ងមានបញ្ចូលរាល់ផែនការសកម្មភាពប្រចាំឆ្នាំរបស់អនុកម្មវិធីនីមួយៗ និងផែនការសកម្មភាពរបស់ដៃគូអភិវឌ្ឍ។ ផែនការប្រតិបត្តិប្រចាំឆ្នាំនឹងត្រូវរៀបចំឡើងជារៀងរាល់ឆ្នាំ។

### ៧.២.២ អង្គភាពពិនិត្យតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-២០១៣

ការរៀបចំប្រព័ន្ធរាយការណ៍ និងការពិនិត្យតាមដានវាយតម្លៃមិនទាន់បានច្បាស់លាស់ល្អទាក់ទងនឹងរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ។ រចនាសម្ព័ន្ធពិនិត្យតាមដាននឹងធ្វើការរក្សានូវតួនាទី និងការទទួលខុសត្រូវរបស់ការិយាល័យ និងនាយកដ្ឋាននៅដដែល ប៉ុន្តែធ្វើយ៉ាងណាកំណត់ឱ្យបានច្បាស់ជាងមុន។

#### ក) ការពិនិត្យតាមដានកម្មវិធីនៅថ្នាក់ក្រុង ស្រុក ខណ្ឌ

ការពិនិត្យតាមដាន ត្រូវធ្វើឡើងដើម្បីគាំទ្រនៅកម្រិតសាលារៀន ស្តីពីការអនុវត្តសកម្មភាពគោលនយោបាយក៏ដូចជា សកម្មភាពនានារបស់អនុកម្មវិធី ត្រូវបានអនុវត្តជាទៀងទាត់។ ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌទទួលខុសត្រូវលើការពិនិត្យតាមដានប្រភេទនេះ ដោយសហការជាមួយគណៈកម្មការទ្រទ្រង់សាលារៀន និង គណៈកម្មការ អប់រំសម្រាប់ទាំងអស់គ្នានៅថ្នាក់ឃុំ-សង្កាត់។

#### ខ) ការពិនិត្យតាមដានកម្មវិធីនៅថ្នាក់រាជធានី ខេត្ត

ការពិនិត្យតាមដានវឌ្ឍនភាពនៃលទ្ធផលរបស់កម្មវិធីនីមួយៗនៅថ្នាក់រាជធានី ខេត្ត រួមបញ្ចូលទាំងការតាមដានលំហូរថវិកាពីសាលារៀន និងការផ្តល់ការគាំទ្រទៅការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ត្រូវបានអនុវត្តដោយគិតពីប្រសិទ្ធភាព និ ងភាពស័ក្តិសិទ្ធិរបស់កម្មវិធី។ មន្ទីរ អប់រំ យុវជន និងកីឡារាជធានី ខេត្តទទួលខុសត្រូវលើការពិនិត្យតាមដានប្រភេទនេះ ដោយសហការជាមួយមន្ទីរហិរញ្ញវត្ថុរាជធានី ខេត្ត និងនាយកដ្ឋានជំនាញផ្សេងៗទៀតនៅថ្នា ក់កណ្តាល។ របាយការណ៍វឌ្ឍនភាពរបស់អនុកម្មវិធីនីមួយៗទាំងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ ព្រមទាំងការវិភាគលើ ការ

សម្រេចបានតាមចំណុចដៅត្រូវបានរៀបចំឡើង តាមរយៈ សន្និបាតអប់រំប្រចាំឆ្នាំរបស់ រាជធានី ខេត្ត។ របាយការណ៍នេះត្រូវបញ្ជូនមកដល់នាយកដ្ឋានជំនាញនៅថ្នាក់កណ្តាល ដើម្បីជាទុនបញ្ចូលទៅក្នុងរបាយការណ៍សន្និបាតអប់រំប្រចាំឆ្នាំថ្នាក់ជាតិ។

**គ) ការពិនិត្យតាមដានកម្មវិធីនៅថ្នាក់ជាតិ**

ការពិនិត្យតាមដានការរីកចម្រើននៃផលសម្រេច និងលទ្ធផលរបស់កម្មវិធីនីមួយៗនៅថ្នាក់ជាតិ រួមបញ្ចូលទាំង ការតាមដានលំហូរថវិកាពីថ្នាក់កណ្តាលទៅថ្នាក់សាលារៀន គ្រឹះស្ថានសិក្សា និងការផ្តល់ការគាំទ្រដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដោយគិតគូរពីប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិរបស់កម្មវិធី។ ការពិនិត្យឡើងវិញលទ្ធផលសម្រេចបាន ធៀបនឹងចំណុចដៅថ្នាក់ជាតិត្រូវបានអនុវត្តឡើង។

ការពិនិត្យឡើងវិញប្រចាំឆ្នាំតាមរយៈសន្និបាតអប់រំថ្នាក់ជាតិ ត្រូវបានប្រារព្ធ ឡើងដោយពិនិត្យលើចំណុចដៅបំពេញការងារ និងផែនការហិរញ្ញវត្ថុ នៃផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួង រួមបញ្ចូលទាំងសកម្មភាពនានាអនុវត្តដោយដៃគូអភិវឌ្ឍ។ នាយកដ្ឋានជំនាញនីមួយៗទទួលខុសត្រូវលើការពិនិត្យតាមដានប្រភេទនេះ ជាពិសេសអនុកម្មវិធីដែលស្ថិតក្រោមការសម្របសម្រួលពីអគ្គនាយកដ្ឋា ន ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍ។

នាយកដ្ឋាននៅថ្នាក់កណ្តាលដែលមានថវិកាសម្រាប់ការពិនិត្យតាមដាន និង ត្រូវបែងចែកថវិកាទៅឱ្យអង្គភាព ថ្នាក់បន្តបន្ទាប់ ដើម្បីធានាថារាល់ទិដ្ឋភាពនៃការពិនិត្យតាមដានកម្មវិធីត្រូវបានគ្របដណ្តប់យ៉ាងមានប្រសិទ្ធភាព។ ផែនការការងារសម្រាប់ពិនិត្យតាមដាន នឹងបញ្ចូលនូវការបែងចែកថវិកាដល់អគ្គាធិការដ្ឋាន នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានផែនការ។

**ឃ) ការពិនិត្យតាមដាន និងអធិការកិច្ចគុណភាព និងប្រសិទ្ធភាពអប់រំ**

ការពិនិត្យតាមដានគុណភាព និងប្រសិទ្ធភាពអប់រំ ត្រូវបានអនុវត្តឡើងនៅលើគ្រប់សកម្មភាពដែលទាក់ទងនឹងគុណភាពអប់រំ និងការកែ លម្អប្រសិទ្ធភាពនៃអ្នកសិក្សា បរិស្ថានសិក្សា ខ្លឹមសារកម្មវិធីសិក្សា ឯកសារ វិធីសាស្ត្ររៀននិង បង្រៀន សម្ភារឧបទេស និងការគ្រប់គ្រងសាលារៀន ដោយមានការចូលរួមពីសហគមន៍។ នាយកដ្ឋានធានាគុណភាពអប់រំទទួលខុសត្រូវការពិនិត្យតាមដានប្រភេទនេះ។

**ង) ការធ្វើសវនកម្មលើការបំពេញការងាររបស់ប្រព័ន្ធ**

ប្រព័ន្ធរដ្ឋបាល និងហិរញ្ញវត្ថុត្រូវបានអធិការកិច្ច និងធ្វើសវនកម្មនៅក្នុងការពិនិត្យតាមដានប្រភេទនេះ។ អធិការដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងក្រុមសវនកម្មរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាជ្ញាធរជាតិសវនកម្ម ជាអង្គភាពពាក់ព័ន្ធលើការងារនេះ។

### ច) ការពិនិត្យតាមដានវឌ្ឍនភាពនិងផលប៉ះពាល់នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ

វឌ្ឍនភាពទូទៅនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ រួមបញ្ចូលទាំងវឌ្ឍនភាពនៃតារាងម៉ាទ្រិកសកម្មភាពគោលនយោបាយ សូចនាករបំពេញការងារនៅថ្នាក់ជាតិ និងផែនការហិរញ្ញវត្ថុត្រូវបានពិនិត្យតាមដានជាទៀងទាត់ដោយនាយកដ្ឋានផែនការ។ របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ត្រូវរៀបចំជារៀងរាល់ឆ្នាំ ដោយធ្វើការវិភាគលើលទ្ធផលនៃជំរឿនស្ថិតិសាលារៀន របាយការណ៍វឌ្ឍនភាពរបស់អនុកម្មវិធីនីមួយៗ របាយការណ៍វឌ្ឍនភាពរបស់រាជធានី ខេត្ត របាយការណ៍ពិនិត្យតាមដាននិងអធិការកិច្ចលើផ្នែកគុណភាពនិងប្រសិទ្ធភាព និងរបាយការណ៍សវនកម្មនិងអធិការកិច្ចលើប្រព័ន្ធ។ ការវិភាគលើប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការក្នុងវិស័យអប់រំក៏ត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍ផងដែរ ដោយមាន កិច្ចសហការជាមួយដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល។ ការអង្កេតលើភាពពេញចិត្តរបស់មាតាបិតាសិស្ស បញ្ហាឆ្លងវិស័យ និងផលប៉ះពាល់របស់កម្មវិធីសាកល្បងផ្សេងៗ ក៏ត្រូវបានធ្វើឡើងផងដែរ។

### ឆ) សន្និបាតអប់រំថ្នាក់ជាតិ

ការបំពេញការងារវិស័យអប់រំទូទៅត្រូវបានពិនិត្យឡើងវិញក្នុងសន្និបាតអប់រំថ្នាក់ជាតិ ដោយមានការចូលរួមពីថ្នាក់ក្រសួង ថ្នាក់ រាជធានី ខេត្ត ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល។ របាយការណ៍សន្និបាតអប់រំត្រូវបានរៀបចំដោយធ្វើការប្រមូលបញ្ចូលគ្នានូវរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ របាយការណ៍វឌ្ឍនភាពនៃអនុកម្មវិធីនីមួយៗ របាយការណ៍វឌ្ឍនភាពរបស់រាជធានី ខេត្ត របាយការណ៍អធិការកិច្ចលើគុណភាព និងប្រសិទ្ធភាពអប់រំ របាយការណ៍អធិការកិច្ចរដ្ឋបាលនិងហិរញ្ញវត្ថុ។ គណៈកម្មាធិការជាតិអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ជាតិ ពិនិត្យតាមដានលើវឌ្ឍនភាពឆ្ពោះទៅសម្រេចការអប់រំសម្រាប់ទាំងអស់គ្នា និងរាយការណ៍ក្នុងសន្និបាតអប់រំ។ គណៈកម្មការរៀបចំសន្និបាតអប់រំ ដែលរួមមានតំណាងរបស់ក្រសួង អប់រំ យុវជន និងកីឡា និងក្រុមការងារវិស័យអប់រំ ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងដំណើរការសន្និបាតអប់រំ និងទទួលខុសត្រូវលើការពិនិត្យតាមដាននៅកម្រិតនេះ។

របាយការណ៍បំពេញការងាររបស់ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល នឹងត្រូវប្រមូលបញ្ចូលទៅក្នុងរបាយការណ៍វឌ្ឍនភាពនៃអនុកម្មវិធីនីមួយៗ និងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រតែម្តង ដោយមិនត្រូវបានរៀបចំ ដាច់ដោយឡែកទៀតឡើយ។ ដៃគូអភិវឌ្ឍ តម្រូវឱ្យជួយគាំទ្រដល់នាយកដ្ឋានជំនាញ ក្នុងការរៀបចំរបាយការណ៍តាមនាយកដ្ឋានជំនាញ នីមួយៗ។

ការកែលម្អរចនាសម្ព័ន្ធ ពិនិត្យតាមដាន មានបង្ហាញជូនដូចខាងក្រោម៖

រូបភាពទី ៤ ៖ រចនាសម្ព័ន្ធពិនិត្យតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣



## ៧.៣. ការលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ

### សាវតារ

វិស័យអប់រំកម្ពុជាបានទទួលការគាំទ្រពីសំណាក់ប្រទេសផ្តល់ជំនួយ ជាលើកដំបូងនៅឆ្នាំ ១៩៩៥ ដោយបានបង្កើតជាក្របខណ្ឌវិនិយោគវិស័យអប់រំឆ្នាំ១៩៩៥-១៩៩៩។ ឆ្លងតាមវឌ្ឍនភាពជាច្រើនក្នុងកិច្ចសម្របសម្រួលនេះ បានធ្វើការប្រែខ្លួនពីការសម្របសម្រួលជាមួយប្រទេសផ្តល់ជំនួយទៅជាប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ សម្រេចបានមុនពេលកំណត់ពីបីទៅបួនឆ្នាំ ពោលគឺមុនសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការកាលពីឆ្នាំ ២០០៥ មានដូចជា គោលការណ៍ភាពជាដៃគូរវាងក្រសួងអប់រំ យុវជននិងកីឡា និងដៃគូអភិវឌ្ឍត្រូវបានចុះហត្ថលេខានៅឆ្នាំ២០០០ ក្រុមការងារវិស័យអប់រំ ឬវេទិកាផ្លូវការរបស់ដៃគូអភិវឌ្ឍត្រូវបានបង្កើតឡើងនៅឆ្នាំ២០០១ និងស្ថាប័នតំណាងរបស់ភាពជាដៃគូវិស័យអប់រំអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០២។ តម្រុយនៃការវិវឌ្ឍទៅមុខរបស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការគាំទ្រវត្ថុបំណងចុងក្រោយនៃប្រសិទ្ធភាពអភិវឌ្ឍវិស័យអប់រំ ក៏មានវឌ្ឍនភាពរហ័សដែរ ដោយសារតែមានការរួមបញ្ចូលគ្នានៃកិច្ចពិភាក្សាគោលនយោបាយ ផែនការអប់រំទូទាំងវិស័យ និងការកើនឡើងការប្រើប្រាស់បែបបទហិរញ្ញប្បទានសហប្រតិបត្តិការថ្មីដែលឆ្លុះបញ្ចាំង ពីការឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលបានលើកឡើងក្នុងសេចក្តីថ្លែងការទីក្រុងប៉ារីស ស្តីពីភាពជាម្ចាស់ ការតម្រឹមសុខដុមនីយកម្ម ការគ្រប់គ្រងផ្តោតលើលទ្ធផល និងគណនេយ្យភាពទ្វេទិស។

សមិទ្ធផលសំខាន់ៗមួយចំនួនទៀតមានដូចជា៖ ការបង្កើតឡើងនូវក្រុមការងារបច្ចេកទេសចម្រុះក្នុងវិស័យអប់រំនៅឆ្នាំ ២០០៤ ក្នុងនោះមានវេទិកាកិច្ចពិភាក្សាគោលនយោបាយ ភាពជាដៃគូរវាងសមាជិកថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ក្រសួងពាក់ព័ន្ធនានា ដៃគូអភិវឌ្ឍ និងអ្នកតំណាងអង្គការមិនមែនរដ្ឋាភិបាល សន្និបាតអប់រំប្រចាំឆ្នាំដែលបានដាក់បញ្ចូលការពិនិត្យឡើងវិញការបំពេញការងារវិស័យអប់រំប្រចាំឆ្នាំនៅឆ្នាំ ២០០៦ និងការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រវិស័យអប់រំប្រចាំឆ្នាំនៅឆ្នាំ ២០០៩ ព្រមទាំងការបង្កើតជាលើកដំបូងនូវផែនការប្រតិបត្តិប្រចាំឆ្នាំនៅឆ្នាំ ២០០៩ ដែលជាការបូកសរុបបញ្ចូលគ្នានូវការវិនិយោគរបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍក្នុងវិស័យអប់រំ។

### ការគ្រប់គ្រងកម្មវិធី

ដោយផ្អែកលើទំនាក់ទំនងជាវិជ្ជមានដែលបានវិវឌ្ឍជាងមួយទសវត្សកន្លងមកនេះ រវាងក្រសួងអប់រំ យុវជននិងកីឡា និងដៃគូអភិវឌ្ឍ គោលការណ៍ភាពជាដៃគូដែលបានកែសម្រួលឡើងវិញគឺមានគោលបំណងដើម្បីធានាថា បញ្ហាប្រឈមក្នុងវិស័យអប់រំដែលនៅសេសសល់ត្រូវបានគេដោះស្រាយក្នុងស្មារតីភាពជាដៃគូ និងគណនេយ្យភាពទ្វេទិសដើម្បីលទ្ធផល។ របៀបវារៈប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការគឺជាការងារអន្តរនាយកដ្ឋាន និងមានការចូលរួមពីគ្រប់លំដាប់ថ្នាក់នៅក្នុងវិស័យ

អប់រំទាំងមូល។ ដើម្បីបង្កើតការគ្រប់គ្រងកម្មវិធីមួយដែលល្អ ក្រុមការងារគ្រប់គ្រងជាន់ខ្ពស់អន្តរនាយកដ្ឋាន នឹងត្រូវបានគេបង្កើត ជាមួយនឹងការគាំទ្រពីដៃគូអភិវឌ្ឍក្នុងការធ្វើឲ្យសម្រេចបាននូវរបៀបវារៈ ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិលើគ្រប់វិស័យ ដែលដៃគូអភិវឌ្ឍបានគាំទ្រ។ ក្រុមការងារបច្ចេកទេសថ្នាក់ខេត្ត ក៏នឹងដាក់បញ្ចូលនូវរបៀបវារៈប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការជាផ្នែកមួយ នៃការទទួលខុសត្រូវរបស់ពួកគេដែរ។

## កាលានុវត្តភាព និងជំហានបន្ទាប់

### *ភាពជាម្ចាស់*

- ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងភាពជាម្ចាស់របស់ខ្លួននៃដំណើរការកំណែទម្រង់វិស័យអប់រំ និងភាពជាដៃគូអភិវឌ្ឍនឹងត្រូវបានគេពង្រឹងបន្ថែមទៀតតាមរយៈកិច្ចពិភាក្សាទាក់ទិននឹងការបង្កើត ការអនុវត្ត និងការពិនិត្យតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣ ដែលផែនការយុទ្ធសាស្ត្រនេះបានទទួលការគាំទ្រពីគ្រប់សមាសភាគដៃគូអភិវឌ្ឍទាំងអស់។
- គោលការណ៍ភាពជាដៃគូវិស័យអប់រំ និងសូចនាករប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការដែលបានកែសម្រួល និងបានធ្វើសេចក្តីព្រាងឡើងវិញនិងលម្អិត ជាពិសេសលើគោលដៅប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ក្នុងការគាំទ្រប្រសិទ្ធភាពការអភិវឌ្ឍវិស័យអប់រំដែលអាចឲ្យយើងដឹងបានពីការកើនឡើងនូវការប្តេជ្ញាចិត្តរបស់ដៃគូអភិវឌ្ឍ និងក្រសួងអប់រំ យុវជន និងកីឡាក្នុងការលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ។ ក្រសួងអប់រំ យុវជន និងកីឡានឹងធ្វើការសម្របសម្រួល និងដឹកនាំផែនការអភិវឌ្ឍសមត្ថភាពរយៈពេលមធ្យមជាមួយនឹងការគាំទ្រពីដៃគូអភិវឌ្ឍ ហើយដៃគូអភិវឌ្ឍនឹងតម្រឹមសកម្មភាពរបស់ពួកគេទៅតាមផែនការអភិវឌ្ឍសមត្ថភាពរយៈពេលមធ្យមនោះ។
- ក្រសួងអប់រំ យុវជន និងកីឡានឹងសម្របសម្រួលសកម្មភាពវិនិយោគ (ការអភិវឌ្ឍសមត្ថភាព និងសម្ភារូបវន្ត) តាមរយៈយុទ្ធសាស្ត្រវិនិយោគក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ខ្លួន និងអាទិភាពវិនិយោគសាធារណៈដែលដឹកនាំក្រសួងអប់រំ យុវជន និងកីឡា។
- ដើម្បីពង្រឹងការរៀបចំភាពជាដៃគូវិស័យអប់រំ ជំហានបន្ទាប់សំខាន់ៗរួមមាន៖ (១) ត្រូវធានាថាដៃគូទាំងអស់ជឿជាក់លើគោលការណ៍ភាពជាដៃគូដែលបានកែសម្រួលឡើងវិញ និងការពិនិត្យតាមដាន (២)ត្រូវធានាថាគម្រោងដៃគូអភិវឌ្ឍទាំងអស់មានចុះអនុសារណៈនៃការយោគយល់គ្នាជាមួយក្រសួងអប់រំ យុវជន និងកីឡា (៣)ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្ម (បើសិនជាត្រូវការ) លក្ខខណ្ឌយោងជាមូលដ្ឋានសម្រាប់ក្រុមការងារបច្ចេកទេសរួមគ្នាក្រុមការងារវិស័យអប់រំនិងគណៈកម្មការគ្រប់គ្រងកម្មវិធី និង(៤)បន្តលើកកម្ពស់កិច្ចពិភាក្សា

ការយោគយល់គ្នាទៅវិញទៅមក និងសកម្មភាពអនុវត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍតាមរយៈយន្តការផ្សេងៗដូចជា កិច្ចប្រជុំរួមគ្នា និង សិក្ខាសាលាជាដើម។

*ការតម្រឹម*

- ភាពប្រសើរឡើងនូវការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍផ្លូវការ នឹងត្រូវបានធ្វើឡើងតាមរយៈការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងសមត្ថភាពសវនកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡាសម្រាប់បង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ថវិកាកម្មវិធីនៅគ្រប់កម្រិត។ ផ្ទុយទៅវិញដៃគូអភិវឌ្ឍនឹងប្រើប្រាស់ប្រព័ន្ធពិនិត្យតាមដាន សវនកម្ម លទ្ធកម្ម និងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ហើយបើសិនជាមិនអាចធ្វើបែបនេះបានទេ ដៃគូអភិវឌ្ឍនឹងកំណត់លក្ខខណ្ឌមូលដ្ឋានក្នុងការប្រើប្រាស់ប្រព័ន្ធទាំងនេះ និងធានាថាប្រព័ន្ធផ្សេងទៀតដែលដៃគូអភិវឌ្ឍប្រើប្រាស់នោះនឹងមិនធ្វើឲ្យចុះខ្សោយប្រព័ន្ធរបស់រដ្ឋាភិបាលទេ ផ្ទុយទៅវិញគឺជួយគាំទ្រដល់ប្រព័ន្ធរបស់រាជរដ្ឋាភិបាលវិញ។ ដៃគូអភិវឌ្ឍនឹងភ្ជាប់ការរកឃើញរបស់ពួកគេជាមួយក្របខណ្ឌលក្ខខណ្ឌរួមគ្នា ដែលបានមកពីផែនការយុទ្ធសាស្ត្រវិស័យអប់រំ។
- ដៃគូអភិវឌ្ឍនឹងកាត់បន្ថយចំនួនគម្រោង និងកម្មវិធីរបស់ខ្លួន ហើយគាំទ្រផែនការយុទ្ធសាស្ត្រវិស័យអប់រំតាមរយៈគោលវិធីផ្តោតលើកម្មវិធី ដែលនឹងជួយក្រសួងអប់រំ យុវជន និងកីឡាក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការវិភាជន៍ធនធានឲ្យកាន់តែច្រើនជាងមុន។
- ភាពប្រសើរឡើងនូវការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍផ្លូវការ ជាមួយផែនការប្រតិបត្តិប្រចាំឆ្នាំនៅថ្នាក់ជាតិ និងថ្នាក់ខេត្តនឹងត្រូវសម្រេចបាននៅឆ្នាំ២០១១។

*សុខុដុមនីយកម្ម*

- សុខុដុមនីយកម្មហិរញ្ញប្បទានសហប្រតិបត្តិការនឹងត្រូវបានពង្រឹង តាមរយៈដំណើរការផែនការប្រតិបត្តិប្រចាំឆ្នាំក្នុងគោលបំណងប្រែក្លាយផែនការប្រតិបត្តិប្រចាំឆ្នាំ ពីយន្តការពិនិត្យតាមដានសម្របសម្រួលប្រទេសផ្តល់ជំនួយ ទៅជាដំណើរការផែនការ និងថវិកាជាក់ស្តែង។
- ថ្នាក់ដឹកនាំរបស់ក្រសួងអប់រំ យុវជន និងកីឡានឹងផ្តល់នូវចក្ខុវិស័យ និងផែនទីចង្អុលផ្លូវមួយសម្រាប់អាទិភាពអភិវឌ្ឍសមត្ថភាពមន្ត្រីរបស់ខ្លួន ការអនុវត្តកំណែទម្រង់វិស័យអប់រំជំហានបន្ទាប់ដើម្បីលទ្ធផល និងគណនេយ្យភាពទ្វេទិស។ ការគាំទ្ររបស់ដៃគូអភិវឌ្ឍដែលបែកខ្ញែកគ្នានាពេលបច្ចុប្បន្ននេះ នឹងធ្វើឲ្យមានការគាំទ្រលើការអភិវឌ្ឍសមត្ថភាពដែលបានធ្វើសុខុដុមនីយកម្មតាមផែនទីចង្អុលផ្លូវនេះ។
- ដើម្បីពង្រឹងផែនការអភិវឌ្ឍសមត្ថភាព និងការអនុវត្តជាជំហានគន្លឹះបន្ទាប់គឺ៖ (១)ការបង្កើតផែនការយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពរយៈពេលមធ្យមពិស្តារមួយ ដែលមានបញ្ចូល

ការវាយតម្លៃតម្រូវការជំនាញក្នុងការឆ្លើយតបទៅនឹងការផ្គត់ផ្គង់ និងតម្រូវការ (២)ធានាថាដៃគូអភិវឌ្ឍតម្រឹមសកម្មភាពអភិវឌ្ឍសមត្ថភាពទាំងអស់របស់ពួកគេ ជាមួយនឹងផែនការអភិវឌ្ឍសមត្ថភាពរបស់ក្រសួងអប់រំ យុវជន និងកីឡានិង(៣)ពង្រឹងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងគាំទ្រការងារប្រចាំថ្ងៃរបស់បុគ្គលិកដោយគិតពីចីរភាព។

### *គណនេយ្យភាពទ្វេទិសនិងការគ្រប់គ្រងផ្តោតលើលទ្ធផល*

- អាទិភាពត្រូវបានផ្តល់លើការពង្រឹងប្រព័ន្ធគ្រប់គ្រងវិមជ្ឈការ ជាពិសេសថ្នាក់ស្រុក និងសាលារៀន និងគោលវិធីផ្តោតលើលទ្ធផលដែលប្រសើរជាងមុនក្នុងការគ្រប់គ្រងវិស័យអប់រំ។ ការពង្រឹងដំណើរការសន្និបាតអប់រំ និងផែនការប្រតិបត្តិប្រចាំឆ្នាំឲ្យមានលក្ខណៈវិភាគ និងផ្តោតលើលទ្ធផល ហើយដោយរួមជាមួយផែនការយុទ្ធសាស្ត្រវិស័យអប់រំនេះ នឹងផ្តល់មូលដ្ឋានដល់វិធីសាស្ត្រការផ្តោតលើលទ្ធផលដែលប្រសើរជាងមុននេះ។ នៅថ្នាក់សាលារៀននឹងមានការពង្រឹងសមត្ថភាព និងសិទ្ធិអំណាចគណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីលើកកម្ពស់គណនេយ្យភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាអប់រំដល់សិស្សានុសិស្ស។ ការបង្កើនសិទ្ធិអំណាចដល់ថ្នាក់សាលារៀន នឹងត្រូវធ្វើឡើងលើសពីការវិភាជន៍ថវិកាដល់សាលារៀន។ វគ្គបំប៉នស្តីពីការគ្រប់គ្រងសាលារៀន នឹងត្រូវបានគេផ្តល់ជូននាយកសាលាទាំងអស់។ ព្រមជាមួយគ្នានោះដែរនឹងមានការចុះអធិការកិច្ចពីការអនុវត្ត និងការបំពេញការងារនៅសាលារៀនមួយ ចំនួនផងដែរ។
- នៅថ្នាក់ក្រុង ស្រុក ខណ្ឌ នឹងមានការកំណត់កាន់តែច្បាស់ជាងមុននូវតួនាទី និងការទទួលខុសត្រូវសម្រាប់ការគាំទ្រការរៀន និងបង្រៀន និងសម្រាប់ការទទួលខុសត្រូវលើការងារគ្រប់គ្រង និងរដ្ឋបាល។ លើសពីនេះទៅទៀត គេនឹងផ្តល់សិទ្ធិអំណាចកាន់តែច្រើនជាងមុនដល់ថ្នាក់ស្រុកក្នុងការធ្វើសេចក្តីសម្រេចចិត្ត ជាជាងផ្តល់ការទទួលខុសត្រូវដល់ថ្នាក់ស្រុក ប៉ុន្តែមិនផ្តល់សិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ យើងនឹងអាចមើលឃើញបានដោយងាយពីការវិវឌ្ឍការគ្រប់គ្រងសកម្មភាពទៅជាការគ្រប់គ្រងលើលទ្ធផល។
- ការធ្វើវិមជ្ឈការ និងការផ្តល់សិទ្ធិអំណាចមានច្រើនជាងមុនក្នុងការកសាងផែនការចាប់ពីថ្នាក់សាលារៀនឡើងទៅ ដើម្បីធានាឲ្យបានថាយុទ្ធសាស្ត្រប្រតិបត្តិការ និងចំណុចដៅ ឆ្លើយតបទៅនឹងស្ថានភាពក្នុងតំបន់ ប៉ុន្តែត្រូវតែមានការតម្រឹមជាមួយគោលដៅថ្នាក់ជាតិ។ ចំណុចដៅវិស័យអប់រំមួយចំនួននៅថ្នាក់ខេត្តនឹងត្រូវបានបង្កើតឡើង ដោយមានការអភិវឌ្ឍរចនាសម្ព័ន្ធគណនេយ្យភាពជាមួយនឹងក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។
- ការពិនិត្យតាមដានសូចនាកររួមក្នុងគោលការណ៍ភាពជាដៃគូ ដែលបានកែសម្រួលនឹងរួមចំណែកដល់របាយការណ៍សន្និបាតអប់រំប្រចាំឆ្នាំ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី ១ ៖ ចំណោលតម្រូវការអប់រំ

## តារាង ក ៖ ចំណោលសិស្ស តម្រូវការគ្រូ និងបន្ទប់រៀន

| ចំណោលចំនួនសិស្សតាមកម្រិតសិក្សា | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | *2008* | *2009* | *2010* | *2011* | *2012* | *2013* | *2014* | *2015* |
| អប់រំកុមារតូច | 152,026 | 186,086 | 206,763 | 230,786 | 254,809 | 278,832 | 302,855 | 326,878 |
| បឋមសិក្សា | 2,262,834 | 2,210,841 | 2,167,694 | 2,128,993 | 2,086,693 | 2,044,927 | 1,984,432 | 1,947,491 |
| មធ្យមសិក្សាបឋមភូមិ | 605,707 | 576,824 | 564,142 | 572,946 | 597,396 | 620,442 | 654,305 | 682,231 |
| *ការអប់រំមូលដ្ឋាន* | *2,868,541* | *2,787,665* | *2,731,836* | *2,701,938* | *2,684,088* | *2,665,369* | *2,638,737* | *2,629,723* |
| ការអប់រំក្រៅប្រព័ន្ធ | 67,222 | 83,425 | 87,426 | 88,326 | 90,905 | 92,900 | 94,795 | 96,690 |
| ការបណ្តុះបណ្តាលគ្រូ | 10,000 | 10,000 | 10,000 | 10,000 | 10,000 | 10,000 | 10,000 | 10,000 |
| មធ្យមសិក្សាទុតិយភូមិ | 292,423 | 322,721 | 340,300 | 343,244 | 344,935 | 354,105 | 377,106 | 412,613 |
| ឧត្តមសិក្សា(សាធារណ:) | 55,987 | 67,262 | 74,664 | 83,447 | 87,437 | 91,458 | 91,274 | 89,952 |
| ឧត្តមសិក្សា (ឯកជន) | 81,266 | 94,254 | 100,249 | 107,960 | 111,569 | 114,745 | 113,154 | 108,518 |
| *ថ្នាក់ក្រោយមូលដ្ឋានសាធារណ:(មិនរាប់បញ្ចូលអប់រំក្រៅប្រព័ន្ធ)* | *358,410* | *399,983* | *424,964* | *436,691* | *442,372* | *455,563* | *478,379* | *512,565* |
| *ថ្នាក់ក្រោយមធ្យមសិក្សាសាធារណ:(មិនរាប់បញ្ចូលអប់រំក្រៅប្រព័ន្ធ)* | *65,987* | *77,262* | *84,664* | *93,447* | *97,437* | *101,458* | *101,274* | *99,952* |
| *ចំនួនគ្រូបង្រៀនដែលត្រូវការ* | | | | | | | | |
| | *2008* | *2009* | *2010* | *2011* | *2012* | *2013* | *2014* | *2015* |
| គ្រូបឋមសិក្សា | 45,511 | 45,540 | 45,628 | 45,705 | 45,611 | 45,443 | 44,098 | 43,278 |
| *ផលធៀបគ្រូ ថ្នាក់* | *0.76* | *0.80* | *0.85* | *0.90* | *0.95* | *1.00* | *1.00* | *1.00* |
| *ផលធៀបសិស្ស គ្រូ* | *49.7* | *48.5* | *47.5* | *46.6* | *45.8* | *45.0* | *45.0* | *45.0* |
| គ្រូមធ្យមសិក្សាបឋមភូមិ | 23,576 | 22,321 | 21,702 | 21,909 | 22,707 | 23,439 | 24,718 | 25,773 |
